**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**(គ.ជ.អ.ប)**

# ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦
# របស់ គ.ជ.អ.ប នៃអាណត្តិទី២

**ខែមករា ឆ្នាំ២០១៦**

# អារម្ភកថា

ការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ខែឧសភា ឆ្នាំ២០០៨) ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌសម្រាប់ពីរអាណត្តិចាប់ពីឆ្នាំ២០០៩មក ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់បីអាណត្តិចាប់ពីឆ្នាំ២០០២រហូតមកដល់ពេលនេះ ការរៀបចំនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ (២០១០-២០១៩) ការអនុម័តនូវផែនការអនុវត្តដំណាក់កាលទី១ (២០១១-២០១៤) និងផែនការអនុវត្តដំណាក់កាលទី២ (២០១៥-២០១៧)នៃកម្មវិធីជាតិបានបង្ហាញឱ្យឃើញនូវឆន្ទៈដ៏ច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជាអំពីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងអំឡុងពេលនៃឆ្នាំ២០១៥ ការអនុវត្តផែនការអនុវត្តដំណាក់កាលទី២ (**ផអ៣ទី២**) សម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនគួរជាទីមោទនៈ។ ក្រសួងមួយចំនួនបានធ្វើការសម្រេចចិត្តក្នុងការផ្ទេរមុខងារសំខាន់ៗមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាក់ស្តែង ក្រសួងបរិស្ថានបានផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរាជធានី ក្រុង និងស្រុកទាំងអស់ទូទាំងប្រទេស។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានធ្វើប្រតិភូកម្មការគ្រប់គ្រង និងការត្រួតពិនិត្យមណ្ឌលថែទាំកុមារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅមួយចំនួន។ ក្រសួងអប់រំ យុវជន និងកីឡាក៏បានសម្រេចចិត្តផ្ទេរការគ្រប់គ្រងការអប់រំកម្រិតបឋមសិក្សា ការអប់រំកុមារតូច និងការអប់រំក្រៅប្រព័ន្ធទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅមួយចំនួន។ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាលបាន និងកំពុងសាកល្បងនូវការធ្វើប្រតិភូកម្មមុខងារពាក់ព័ន្ធនឹងការថែទាំប្រព័ន្ធទឹកស្អាតជនបទ ការគ្រប់គ្រងសេវាអនាម័យជនបទ និងការគ្រប់គ្រងមណ្ឌលសុខភាពនៅក្នុងស្រុកមួយចំនួន។ ផ្អែកលើបទពិសោធន៍នៃការសាកល្បងនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានសម្រេចចិត្តផ្ទេរមុខងារថែទាំផ្លូវលំជនបទមានលក្ខណៈជាប្រចាំ ហើយក្រសួងសុខាភិបាលក៏បានសម្រេចចិត្តផ្ទេរមុខងារផ្តល់សេវាគាំពារសុខភាពបឋមទៅឱ្យរដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌគោលដៅមួយចំនួនផងដែរ។

ក្នុងឆ្នាំ២០១៦ យើងនឹងផ្តោតការយកចិត្តទុកដាក់ទៅលើការផ្តល់សេវាជាបន្តទៀតដោយសារកិច្ចការនេះជាតម្រូវការចាំបាច់បំផុតរបស់ប្រជាពលរដ្ឋ។ ដើម្បីធានាដល់ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវា ការផ្ទេរមុខងារត្រូវតែផ្សារភ្ជាប់ជាមួយនឹងការផ្ទេរទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្សផងដែរ។ ក្នុងឆ្នាំ២០១៦នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តរៀបចំ និងដាក់ឱ្យអនុវត្តនូវយន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ ដើម្បីផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តនូវមុខងារដែលបានផ្ទេរ។ សេចក្តីព្រាងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានអនុម័តដោយ គ.ជ.អ.ប ក្នុងកិច្ចប្រជុំលើកទី១១ នាថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ គឺជាមូលដ្ឋានសម្រាប់បង្កើតនូវប្រព័ន្ធគ្រប់គ្រងបុគ្គលិកបែបវិមជ្ឈការក្នុងក្របខ័ណ្ឌនៃគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។ លក្ខន្តិកៈដោយឡែកនេះមានគោលបំណងសំខាន់ក្នុងការពង្រឹងសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់ខ្លួនប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព មានការលើកទឹកចិត្ត និងធានាអព្យាក្រឹត្យភាពក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់មន្ត្រីរាជការ ព្រមទាំងសម្របសម្រួលដល់ការផ្ទេរបុគ្គលិកស្របជាមួយនឹង

ការផ្ទេរមុខងារ។ យើងនឹងបន្តលើកកម្ពស់ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋតាមរយៈការពង្រឹង និងពង្រីកការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងបង្កើតឱ្យមានយន្តការផ្តល់សេវាតាមលក្ខណៈច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត។

ក្នុងឆ្នាំ២០១៥ មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបានបង្កើតនៅគ្រប់រាជធានី ខេត្តទាំងអស់។ មណ្ឌលនេះមានតួនាទីសំខាន់ក្នុងការសម្របសម្រួលជាមួយស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា ដើម្បីផ្តល់ការអភិវឌ្ឍសមត្ថភាព និងផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាការផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបាននូវការគាំទ្រកិច្ចអភិវឌ្ឍសមត្ថភាពផ្អែកតាមតម្រូវការរបស់ខ្លួន។

ចំណុចចុងក្រោយ គឺការបន្តពង្រឹងអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បច្ចុប្បន្ន ក្រុង ស្រុកទាំងអស់បាននិងកំពុងដំណើរការរៀបចំ និងអនុម័តនូវវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួនដែលនឹងផ្តល់នូវការតម្រង់ទិសជាយុទ្ធសាស្ត្រ និងការបែងចែកច្បាស់លាស់នូវការទទួលខុសត្រូវរវាងគណៈអភិបាល និងក្រុមប្រឹក្សា។ ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនឹងត្រូវបន្តអនុវត្តដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។ កិច្ចការនេះកំពុងត្រូវបានអនុវត្តសាកល្បងនៅក្នុងឃុំជាច្រើនក្នុងគោលបំណងលើកកម្ពស់ការផ្តល់ជូនប្រជាពលរដ្ឋនូវព័ត៌មានសំខាន់ៗអំពីការប្រើប្រាស់ថវិកា និងការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន និងអ្នកផ្តល់សេវានានានៅមូលដ្ឋាន។ កិច្ចដំណើរការនេះក៏នឹងលើកកម្ពស់ទាំងការចូលរួម និងការតាមដានត្រួតពិនិត្យរបស់ប្រជាពលរដ្ឋផងដែរ។ យើងសង្ឃឹមថា កិច្ចដំណើរការនេះនឹងនាំមកនូវការកែលម្អគុណភាព ប្រសិទ្ធភព តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវានានានៅថ្នាក់មូលដ្ឋាន។

ដូចខ្ញុំបានគូសបញ្ជាក់ក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ នៅក្នុងខេត្តព្រះសីហនុថា រាល់ការធ្វើកំណែទម្រង់ ជាពិសេសកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតែងតែជួបប្រទះនូវឧបសគ្គ។ ប៉ុន្តែយើងត្រូវមានភាពជឿជាក់ថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺជាយុទ្ធសាស្ត្រដ៏ចាំបាច់ និងសមស្របបំផុតក្នុងការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈ និងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដែលជាការចូលរួមចំណែកដ៏សំខាន់ក្នុងការអភិវឌ្ឍជាតិលើគ្រប់វិស័យ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព។ ក្នុងន័យនេះ យើងត្រូវតែបន្តខិតខំប្រឹងប្រែងជំនះរាល់ឧបសគ្គទាំងឡាយ ដើម្បីធានាដល់ការសម្រេចបាននូវគោលបំណងនៃកំណែទម្រង់របស់យើង។

ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦នេះ កំណត់នូវចំណុចដៅជាអាទិភាពចំនួន១៥ដែលត្រូវសម្រេចឱ្យបាន។ ឆ្នាំ២០១៦នេះ យើងត្រូវផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការផ្ទេរមុខងារក្នុងវិស័យអប់រំ សុខាភិបាល សង្គមកិច្ច អភិវឌ្ឍន៍ជនបទ និងបរិស្ថាន។ ជាការពិតណាស់ ការផ្ទេរមុខងារ គឺជាចំណុចស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ អាស្រ័យហេតុនេះ យើងត្រូវខិតខំប្រឹងប្រែងអនុវត្តកិច្ចការនេះប្រកបដោយការតាំងចិត្ត និងមានភាពច្បាស់លាស់ក្នុងការផ្ទេរសិទ្ធិអំណាចផ្ទេរមុខងារ និងធនធានយ៉ាងពិតប្រាកដទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយឡែក ការរៀបចំ និងដាក់ឱ្យអនុវត្តជាបន្ទាន់នូវមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្តល់សិទ្ធិអំណាចបន្ថែមទៅ

ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកៀរគរមូលនិធិឆន្ទានុសិទ្ធិតាមរយៈការប្រមូលធនធានពីប្រភពចំណូលផ្ទាល់នៅមូលដ្ឋាន ការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដើម្បីលើកកម្ពស់ស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងធនធានរបស់ខ្លួន ព្រមទាំងការបង្កើត និងអនុវត្តនូវយន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌប្រកបដោយតម្លាភាព សមធម៌ និងមានប្រសិទ្ធភាពក៏ជាកិច្ចការអាទិភាពក្នុងឆ្នាំ២០១៦ផងដែរ។ កិច្ចការសំខាន់មួយទៀត គឺក្នុងឆ្នាំ២០១៦ យើងត្រូវធ្វើវិមជ្ឈការនៃការគ្រប់គ្រងធនធានមនុស្សទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយកិច្ចការនេះក៏ត្រូវអនុវត្តដោយយកចិត្តទុកដាក់ដល់ការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំផងដែរ។ យើងក៏ត្រូវធានាថា បញ្ហាបរិយាប័ន្ន និងសមធម៌សង្គមត្រូវបានដោះស្រាយ និងលើកកម្ពស់នៅក្នុងគោលនយោបាយ នីតិវិធី និងសេចក្តីសម្រេចនានា។ ក្នុងឆ្នាំ២០១៦ ការអនុវត្តការងារគណនេយ្យភាពសង្គមនឹងត្រូវបានពង្រីកបន្ថែមទៅក្នុងតំបន់គោលដៅផ្សេងទៀត អាស្រ័យហេតុនេះ យើងត្រូវបន្តកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាដើម្បីធានាថា ប្រជាពលរដ្ឋចូលរួមយ៉ាងសកម្ម ប្រកបដោយការស្ថាបនាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាមូលដ្ឋាននានាក្នុងគោលបំណងកែលម្អការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការលើកកម្ពស់ការចូលរួមរបស់សហគមន៍។

ភាពជោគជ័យក្នុងការអនុវត្ត ផ.ស.ថ ឆ្នាំ២០១៦ អាស្រ័យលើកិច្ចខិតខំប្រឹងប្រែង ការប្រឹក្សាយោបល់ និងកិច្ចសហការយ៉ាងសកម្មជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិតទាំងអស់។ លើសពីនេះ ភាពជោគជ័យនេះក៏អាស្រ័យទៅលើសមត្ថភាពរបស់ថ្នាក់ដឹកនាំនានាក្នុងការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ការតាមដាននិងការវាយតម្លៃ ការប្រាស្រ័យទាក់ទង ការអភិវឌ្ឍគោលនយោបាយ និងកិច្ចដំណើរការកសាងផែនការនានាសម្រាប់កម្មវិធីផងដែរ។ ជាមួយគ្នានេះដែរ ភាពជោគជ័យនៃការអនុវត្តផែនការនេះក៏អាស្រ័យទៅលើការសម្របសម្រួល និងកិច្ចសហការជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល និងកម្មវិធីកំណែទម្រង់ផ្សេងទៀតដូចជា កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ កំណែទម្រង់ទាំងនេះ គឺជាកត្តាដ៏មានសារសំខាន់ដើម្បីទទួលបានជោគជ័យក្នុងការលើកកម្ពស់កិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ជារួម រាល់កិច្ចខិតខំប្រឹងប្រែងត្រូវតែធានាថា កំណែទម្រង់ទាំងនេះនឹងផ្តល់ផលប្រយោជន៍ពិតប្រាកដជូនប្រជាពលរដ្ឋ ពិសេសប្រជាពលរដ្ឋក្រីក្រ និងក្រុមជនងាយរងគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មករា ឆ្នាំ២០១៦

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
និងជាប្រធាន គ.ជ.អ.ប

សម្តេចក្រឡាហោម ស ខេង

# មាតិកា


បញ្ជីរូបភាព ........ vi

បញ្ជីតារាង ........ vi

បញ្ជីអក្សរកាត់ ........ vii

វាក្យសព្ទ និងនិយមន័យ ........ ix

## I. សេចក្តីផ្តើម ........ ០១

ក. ចំណុចដៅជាអាទិភាពក្នុងឆ្នាំ២០១៦ ........ ០២

ខ. ថវិកានៃ ផ.ស.ថ ឆ្នាំ២០១៦ ........ ០៨

ខ.១. ផែនការចំណាយ ........ ០៨

ខ.២. ជំនួយបច្ចេកទេស ........ ០៩

ខ.៣. ថវិការាជរដ្ឋាភិបាល ........ ១០

ខ.៤. មូលនិធិកញ្ចប់រួម ........ ១២

ខ.៥. មូលនិធិពីប្រភពផ្សេងទៀត ........ ១២

ខ.៦. សេចក្តីសង្ខេប ........ ១៣

## II. សមិទ្ធផលរំពឹងទុកនានានៃ ផ.ស.ថ ឆ្នាំ២០១៦ ........ ១៥

**១. សមិទ្ធផលរំពឹងទុកទីមួយ ÷ ការគ្រប់គ្រងការចារកំណែទម្រង់** ........ **១៦**

១.១. សេចក្តីផ្តើម និងចំណុចដៅ ........ ១៦

១.២. លទ្ធផលរំពឹងទុក ........ ១៧

១.៣. គម្រោងថវិកា ........ ២១

**២. សមិទ្ធផលរំពឹងទុកទីពីរ ÷ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ** ........ **២៣**

២.១. សេចក្តីផ្តើម និងចំណុចដៅ ........ ២៣

២.២. លទ្ធផលរំពឹងទុក ........ ២៤

២.៣. គម្រោងថវិកា ........ ២៧

**៣. សមិទ្ធផលរំពឹងទុកទីបី ÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** ........ **២៩**

៣.១. សេចក្តីផ្តើម និងចំណុចដៅ ........ ២៩

៣.២. លទ្ធផលរំពឹងទុក ........ ៣០

៣.៣. គម្រោងថវិកា ........ ៣៣

**៤. សមិទ្ធផលរំពឹងទុកទីបួន ៖ ការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ...................... ៣៥**
៤.១. សេចក្តីផ្តើម និងចំណុចដៅ......................................................................................................៣៥
៤.២. លទ្ធផលរំពឹងទុក.......................................................................................................................៣៦
៤.៣. គម្រោងថវិកា.............................................................................................................................៤២
**៥. សមិទ្ធផលរំពឹងទុកទីប្រាំ ៖ វិមជ្ឈការហិរញ្ញវត្ថុ...................................................................... ៤៥**
៥.១. សេចក្តីផ្តើម និងចំណុចដៅ...................................................................................................... ៤៥
៥.២. លទ្ធផលរំពឹងទុក...................................................................................................................... ៤៦
៥.៣. គម្រោងថវិកា............................................................................................................................ ៤៩

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី១ ៖ សុន្ទរកថាបើករបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់** ឧបនាយករដ្ឋមន្ត្រី ប្រចាំការក្នុងពិធីបើកសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និង ថវិកាឆ្នាំ២០១៦ របស់ គ.ជ.អ.ប.

ឧបសម្ព័ន្ធទី២ ៖ សុន្ទរកថាបិទរបស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃក្នុងពិធីបិទសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ របស់ គ.ជ.អ.ប.

ឧបសម្ព័ន្ធទី៣ ៖ ផែនការជំនួយបច្ចេកទេស

ឧបសម្ព័ន្ធទី៤៖ តារាងសកម្មភាព និងថវិកាលម្អិត

ឧបសម្ព័ន្ធទី៥ ៖ សូចនាករ និងចំណុចដៅ

## បញ្ជីរូបភាព


រូបភាពទី១ ៖ និន្នាការស្តីពីជំនួយបច្ចេកទេស.......... ១០
រូបភាពទី២ ៖ និន្នាការស្តីពីការផ្ទេរថវិការបស់រដ្ឋ.......... ១១
រូបភាពទី៣ ៖ និន្នាការស្តីពីថវិកាកញ្ចប់រួម .......... ១២


## បញ្ជីតារាង


តារាងទី១ ៖ លទ្ធផលរំពឹងទុកមួយចំនួន និងឯកសារលម្អិតពាក់ព័ន្ធ.......... ០១
តារាងទី២ ៖ ផែនការចំណាយសម្រាប់ឆ្នាំ២០១៦.......... ០៩
តារាងទី៣ ៖ ការផ្ទេរថវិកាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ .......... ១១
តារាងទី៤ ៖ ព័ត៌មានលម្អិតអំពីមូលនិធិតាមប្រភព .......... ១៤
តារាងទី៥ ៖ ចំណុចដៅរបស់សមិទ្ធផលរំពឹងទុកទី១ .......... ១៦
តារាងទី៦ ៖ គម្រោងថវិកា និងប្រភពមូលនិធិរបស់សមិទ្ធផលរំពឹងទុកទី១.......... ២២
តារាងទី៧ ៖ ចំណុចដៅរបស់សមិទ្ធផលរំពឹងទុកទី២.......... ២៣
តារាងទី៨ ៖ គម្រោងថវិកា និងប្រភពមូលនិធិរបស់សមិទ្ធផលរំពឹងទុកទី២ .......... ២៧
តារាងទី៩ ៖ ចំណុចដៅរបស់សមិទ្ធផលរំពឹងទុកទី៣.......... ២៩
តារាងទី១០ ៖ គម្រោងថវិកា និងប្រភពមូលនិធិរបស់សមិទ្ធផលរំពឹងទុកទី៣.......... ៣៤
តារាងទី១១ ៖ ចំណុចដៅរបស់សមិទ្ធផលរំពឹងទុកទី៤.......... ៣៥
តារាងទី១២ ៖ គម្រោងថវិកា និងប្រភពមូលនិធិរបស់សមិទ្ធផលរំពឹងទុកទី៤.......... ៤៣
តារាងទី១៣ ៖ ចំណុចដៅរបស់សមិទ្ធផលរំពឹងទុកទី៥ .......... ៤៥
តារាងទី១៤ ៖ គម្រោងថវិកា និងប្រភពមូលនិធិរបស់សមិទ្ធផលរំពឹងទុកទី៥.......... ៤៩

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ផអ៣ទី១ | ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី១ (២០១១-២០១៤) នៃកម្មវិធីជាតិ |
| ផអ៣ទី២ | ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី២ (២០១៥-២០១៧) នៃកម្មវិធីជាតិ |
| ផ.ស.ថ. | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| គ.ក.ស.ក. | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក. | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| Basket | មូលនិធិកញ្ចប់រួមគាំទ្រដោយ Sida, SDC និង EU |
| I4C | ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ |
| Sida | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែដ |
| EU | សហភាពអឺរ៉ុប |
| EU/SPACE | កម្មវិធីគាំទ្រដោយសហភាពអឺរ៉ុបដើម្បីគាំទ្រការចូលរួមរបស់សង្គមស៊ីវិល |
| GIZ/RED III | គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ដំណាក់កាលទី៣ |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB/PPTA | គម្រោងជំនួយបច្ចេកទេសសម្រាប់ការរៀបចំកម្មវិធី គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB/DPFSM | កម្មវិធីស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវាសាធារណៈបែបវិមជ្ឈការ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB/TS-PRSDP | គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB/RWS | គម្រោងប្រតិបត្តិ និងថែទាំការផ្គត់ផ្គង់ទឹកជនបទគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| IFAD/ASPIRE | គម្រោងសេវាកសិកម្មសម្រាប់ការផ្តួចផ្តើម ភាពធន និងការផ្សព្វផ្សាយ គាំទ្រដោយមូលនិធិអន្តរជាតិសម្រាប់កិច្ចអភិវឌ្ឍកសិកម្ម |
| SDC | ទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់កិច្ចអភិវឌ្ឍន៍របស់ប្រទេសស្វីស |
| UNCDF | មូលនិធិសម្រាប់អភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ |
| UNCDF/LDDPHS | គម្រោងកិច្ចអភិវឌ្ឍមូលដ្ឋានតាមរយៈសេវាសុខភាពសាធារណៈបែបវិមជ្ឈការ |
| UNCDF/LGCCII | គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ គាំទ្រដោយមូលនិធិសម្រាប់អភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ |
| UNICEF/ Seth Koma | កម្មវិធីសិទ្ធិកុមារនៃមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |
| UNDP-EU/ACES | គម្រោងលើកកម្ពស់សេវារបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិគាំទ្រដោយយូអិនឌីភី និងសហភាពអឺរ៉ុប |
| UNFPA | មូលនិធិប្រជាពលរដ្ឋរបស់អង្គការសហប្រជាជាតិ |

| អក្សរកាត់ | ពាក្យពេញ |
| --- | --- |
| WB | ធនាគារពិភពលោក |
| WB/CTPMCH | គម្រោងសង្គហទានសង្គមសម្រាប់សុខភាព និងអាហារូបត្ថម្ភស្ត្រី និងកុមារ គាំទ្រដោយធនាគារពិភពលោក |
| USAID | ទីភ្នាក់ងារសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក |
| JSDF | មូលនិធិសម្រាប់កិច្ចអភិវឌ្ឍសង្គមរបស់ប្រទេសជប៉ុន |
| RACHA | អង្គការសម្ព័ន្ធភាពកុមារ និងសុខភាពបន្តពូជ |

# វាក្យស័ព្ទ និងនិយមន័យសំខាន់ៗ

**គណនេយ្យភាព** — កាតព្វកិច្ចនៃអ្នកអនុវត្តសិទ្ធិអំណាចក្នុងការឆ្លើយបំភ្លឺអំពីសកម្មភាពនានារបស់ខ្លួនចំពោះអាជ្ញាធរមានសមត្ថកិច្ចណាមួយ ដែលអាចដាក់នូវការពិន័យទោសក្នុងករណីខកខានមិនបានអនុវត្ត។

**ការគ្រប់គ្រងផ្អែកលើលទ្ធផល** — វិធីសាស្ត្រវិលជុំសម្រាប់ការគ្រប់គ្រងដែលធ្វើសមាហរណកម្មនៃយុទ្ធសាស្ត្រ មនុស្ស ធនធាន កិច្ចដំណើរការ និងវិធានការនានា ដើម្បីលើកកម្ពស់ការសម្រេចចិត្ត តម្លាភាព និងគណនេយ្យភាព។ វិធីសាស្ត្រនេះផ្តោតលើការសម្រេចបាននូវសមិទ្ធផល ការអនុវត្តនូវការវាស់វែងនៃការអនុវត្តការងារ ការសិក្សារៀនសូត្រ និងការសម្របសម្រួល ក៏ដូចជាការរៀបចំរបាយការណ៍យ៉ាងច្បាស់លាស់។

**តម្លាភាព** — ការផ្តល់នូវព័ត៌មានទាន់ពេលវេលា និងអាចជឿទុកចិត្តបាន ហើយព័ត៌មាននេះអាចទទួលបានការប្រើប្រាស់ដោយអ្នកពាក់ព័ន្ធទាំងអស់។

**ការអភិវឌ្ឍសមត្ថភាព** — ជាដំណើរការមួយដែលនាំមកនូវការលើកកម្ពស់ជំនាញ (ទាំងជំនាញទូទៅ និងជំនាញជាក់លាក់) ដែលធ្វើឱ្យប្រសើរឡើងនូវនីតិវិធី និងការពង្រឹងស្ថាប័ន។ ការកសាងសមត្ថភាពសំដៅលើការវិនិយោគលើមនុស្ស ស្ថាប័ន និងបែបផែននៃការអនុវត្តនានា។

**ការចូលរួមរបស់សង្គមស៊ីវិល** — ជាដំណើរការនៅក្នុងសហគមន៍ដែលប្រជាពលរដ្ឋប្រមូលផ្តុំគ្នាបង្កើតឡើងដើម្បីសម្រេចគោលដៅរួមនានារបស់ខ្លួននៅមូលដ្ឋាន និងធ្វើការងារជាបុគ្គល ឬរួមគ្នាតាមរយៈអង្គការសហគមន៍មិនមែនរដ្ឋាភិបាលដើម្បីមានឥទ្ធិពលទៅលើដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

**អង្គការសហគមន៍ ឬអង្គការសង្គមស៊ីវិល** — ជាអង្គការមិនមែនរដ្ឋាភិបាល និងមិនរកប្រាក់ចំណេញដែលមានវត្តមានក្នុងសង្គមដែលតំណាងឱ្យផលប្រយោជន៍ និងគុណតម្លៃរបស់សមាជិកខ្លួន ឬអ្នកដទៃ ដោយផ្អែកលើការយកចិត្តទុកដាក់នានាដែលមានលក្ខណៈជាក្រមសីលធម៌ វប្បធម៌ នយោបាយ វិទ្យាសាស្ត្រ សាសនា ឬសប្បុរសធម៌។

**ការវាយតម្លៃ** — ជាការវិនិច្ឆ័យទៅលើគុណតម្លៃ ផលប្រយោជន៍ និងតម្លៃនៃការងារអ្វីមួយ ជាការសិក្សាវាយតម្លៃអំពីភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព ផលប៉ះពាល់ និរន្តរភាព និងភាពពាក់ព័ន្ធនៃគម្រោងមួយ ស្របតាមគោលបំណងនានាដែលបានកំណត់។

**អភិបាលកិច្ច** — ជាប្រពៃណី និងការរៀបចំនូវស្ថាប័ននានាដែលអាជ្ញាធរនៃប្រទេសមួយបានប្រើប្រាស់។ ជាមធ្យោបាយនៃការអនុវត្តសិទ្ធិអំណាចដែលជះឥទ្ធិពលទៅលើជីវភាពសាធារណៈ ជាពិសេស ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច។

**ផលប៉ះពាល់** — ការជះឥទ្ធិពលជាវិជ្ជមាន និងជាអវិជ្ជមានចំពោះមុខ និងយូរអង្វែង ដែលផ្តើមចេញពីកិច្ចអន្តរាគមន៍នៃការអភិវឌ្ឍមួយមានលក្ខណៈដោយផ្ទាល់ ឬដោយប្រយោល ដោយចេតនា ឬដោយអចេតនា។

**សូចនាករ** កត្តា ឬអញ្ញតជាបរិមាណ ឬជាគុណភាពដែលផ្តល់ជាមធ្យោបាយមួយ មានលក្ខណៈសាមញ្ញ និងអាចជឿទុកចិត្តបានសម្រាប់វាស់វែងសមិទ្ធផល ឬឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនានាដែលកើតចេញពីអន្តរាគមន៍ណាមួយ ឬក៏ជួយក្នុងការវាយតម្លៃពីការបំពេញការងាររបស់តួអង្គអភិវឌ្ឍន៍ណាមួយ។

**ធាតុចូល** ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ធនធានសម្ភារៈ ឯកសារ របាយការណ៍នានា ដែលបានប្រើប្រាស់សម្រាប់កិច្ចអន្តរាគមន៍ដល់ការអភិវឌ្ឍនានា។

**លទ្ធផលជាគន្លឹះ** ជាសកម្មភាពសំខាន់ ឬជាគន្លឹះដែលបានកំណត់ ឬដៅទុកសម្រាប់ការត្រួតពិនិត្យ ជាពិសេសពាក់ព័ន្ធនឹងវឌ្ឍនភាពនៃការសម្រេចបាន។

**ការត្រួតពិនិត្យ** ជាការប្រមូល ការវិភាគ និងការប្រើប្រាស់មានលក្ខណៈជាប្រព័ន្ធ និងជាប្រចាំនូវព័ត៌មាននានាក្នុងគោលបំណងត្រួតពិនិត្យការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចចិត្ត។

**សមិទ្ធផលរំពឹងទុក** ជាការផ្លាស់ប្តូរ ឬការធ្វើឱ្យប្រសើរឡើងដោយផ្ទាល់នូវសុខមាលភាពនៃអ្នកទទួលផល ឬអតិថិជន ដែលជាលទ្ធផលនៃការប្រើប្រាស់សេវាមួយ (ឬលទ្ធផលរំពឹងទុក)។

**លទ្ធផលរំពឹងទុក** ផលិតផល ឧបករណ៍ សម្ភារៈ និងសេវាទាំងឡាយដែលទទួលបានពីអន្តរាគមន៍អភិវឌ្ឍន៍មួយ ហើយវាក៏អាចរួមបញ្ចូលទាំងការផ្លាស់ប្តូរនានាផ្តើមចេញពីអន្តរាគមន៍ដែលពាក់ព័ន្ធនឹងការសម្រេចនូវសមិទ្ធផលរំពឹងទុកនានា។ ស្ថាប័ននានាត្រូវមានគណនេយ្យភាពក្នុងការសម្រេចលទ្ធផលរំពឹងទុកឱ្យបានទាន់ពេលវេលា មានគុណភាព និងបរិមាណសមស្រប។

**សកម្មភាព** ទង្វើដែលប្រកាន់យក ឬកិច្ចការដែលបានបំពេញដោយប្រើប្រាស់នូវធាតុចូលនានាដូចជាមូលនិធិ ជំនួយបច្ចេកទេស និងធនធានផ្សេងទៀតដែលបានគៀរគរ ដើម្បីបង្កើតចេញជាលទ្ធផលរំពឹងទុកជាក់លាក់នានា។

**គោលនយោបាយ (គោលនយោបាយសាធារណៈមួយ)** សកម្មភាព គោលការណ៍ ឬសំណុំនៃការធ្វើសេចក្តីសម្រេចចិត្តដែលមានគោលបំណង និងភាពស៊ីសង្វាក់គ្នាមួយ ដើម្បី (១)រៀបចំឆ្លើយតបនឹងបញ្ហាមួយ (២)រៀបចំដោយកិច្ចដំណើរការនយោបាយជាក់លាក់ណាមួយ និង(៣)អនុម័ត អនុវត្ត និងពង្រឹងការអនុវត្តដោយស្ថាប័នមួយ។

**កម្មវិធី** ជាអន្តរាគមន៍មួយដែលមានកំណត់ពេលវេលាជាក់លាក់ ដែលមានលក្ខណៈខុសគ្នាពីគម្រោង ពីព្រោះជាទូទៅ កម្មវិធី គឺមានលក្ខណៈអន្តរវិស័យ គ្របដណ្តប់លើប្រធានបទផ្សេងៗ និងឬមានតំបន់គោលដៅច្រើន ប្រើប្រាស់វិធីសាស្ត្រចំរុះ ពាក់ព័ន្ធនឹងស្ថាប័នច្រើនជាងស្ថាប័នអនុវត្តគម្រោង និងអាចគាំទ្រដោយប្រភពទុនផ្សេងៗ។

**បរិយាប័ន្ន** ជាការលើកកម្ពស់ស្ថានភាពរបស់បុគ្គល និងក្រុមនានាក្នុងការចូលរួម និងទទួលផលពីសកម្មភាពនានារបស់សង្គមដោយមិនរើសអើង។ គោលបំណងនៃបរិយាប័ន្ន គឺការផ្តល់នូវសិទ្ធិឱ្យក្រុមផ្សេងគ្នាៗ ជាពិសេសប្រជាពលរដ្ឋក្រីក្រ ក្រុមជនងាយរងគ្រោះទទួលបាននូវឱកាសសមស្រប ព្រមទាំងធានាថាមតិយោបល់ និងការយល់ឃើញនានារបស់ក្រុមទាំងនោះត្រូវបានយកមកពិចារណាសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត ដែលប៉ះពាល់ដល់

ជីវភាពរស់នៅរបស់ពួកគាត់ ក៏ដូចជាដើម្បីធានាឱ្យពួកគេទទួលបាន និងប្រើប្រាស់ដោយស្មើភាពនូវផលប្រយោជន៍ពីការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងលក្ខខណ្ឌនានាផ្នែកសង្គម នយោបាយ និងរូបវន្ត។

**សមធម៌សង្គម** ការលើកកម្ពស់សិទ្ធិក្នុងការទទួលបាន និងការប្រើប្រាស់ដោយយុត្តិធម៌នូវផលប្រយោជន៍ពីការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងលក្ខខណ្ឌនានាផ្នែកសង្គម នយោបាយ និងរូបវន្តសម្រាប់ការរស់នៅ និងការចូលរួមយ៉ាងពេញលេញក្នុងការងារនយោបាយ និងវប្បធម៌នៅក្នុងសង្គម ក៏ដូចជាសិទ្ធិក្នុងការកំណត់ដោយខ្លួនឯងដើម្បីសម្រេចបាននូវសេចក្តីត្រូវការជាមូលដ្ឋាននានារបស់ខ្លួន។ ក្នុងការងាររដ្ឋបាលសាធារណៈ សមធម៌សង្គមសំដៅលើការគ្រប់គ្រងស្ថាប័ននានាដែលបម្រើផលប្រយោជន៍សាធារណៈ ការផ្តល់សេវាសាធារណៈ និងការរៀបចំ និងការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋាននានាប្រកបដោយយុត្តិធម៌ និងសមធម៌។

# I. សេចក្តីផ្តើម

ផែនការអនុវត្តបីឆ្នាំដំណាក់កាលទី២(ផអ៣ទី២) ពីឆ្នាំ២០១៥ដល់ឆ្នាំ២០១៧នៃកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានអនុម័តដោយ គ.ជ.អ.ប នៅខែធ្នូ ឆ្នាំ២០១៤។ ផែនការនេះត្រូវបានរៀបចំឡើងដោយផ្អែកលើភាពជោគជ័យនៃការអនុវត្តផអ៣ទី១ និងផ្តោតលើទិដ្ឋភាពសំខាន់ៗមួយចំនួនដូចជា ការផ្ទេរមុខងារពីក្រសួង ស្ថាប័នឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការលើកកម្ពស់ការផ្តល់សេវា និងកិច្ចអភិវឌ្ឍមូលដ្ឋាន ការលើកកម្ពស់ការគ្រប់គ្រងកំណែទម្រង់ និងការអនុវត្តនូវវិធីសាស្ត្រថ្មីសម្រាប់ការអភិវឌ្ឍសមត្ថភាព ព្រមទាំងការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិល។ ឯកសារនេះ គឺជាផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៦ (ផ.ស.ថ) ដែលជាផែនការអនុវត្តឆ្នាំទី២នៃផអ៣ទី២។

ផ.ស.ថ ឆ្នាំ២០១៦ កំណត់អំពីចំណុចដៅជាអាទិភាព លទ្ធផលរំពឹងទុក និងសកម្មភាពនានា ព្រមទាំងផែនការថវិកាសម្រាប់ការអនុវត្តកម្មវិធីជាតិក្នុងឆ្នាំទី៦ និងជាក្របខ័ណ្ឌមួយសម្រាប់ការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំផងដែរ។ ផែនការនេះបានរៀបចំឡើងចាប់ពីត្រីមាសទី៤ ឆ្នាំ២០១៥ ដោយមានការពិគ្រោះយោបល់ជាច្រើនលើកច្រើនសារជាមួយស្ថាប័នអនុវត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។ ចំណុចដៅជាអាទិភាព និងការវិភាជថវិកានានាក៏ត្រូវបានបង្ហាញ និងពិភាក្សាក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ ដែលបានរៀបចំឡើងនាថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០១៥ ដោយមានអ្នកចូលរួមប្រមាណជាង៥០០នាក់ រួមមានថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិករបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សា អភិបាលរាជធានី ខេត្តទាំង២៥ និងក្រុង ស្រុក ខណ្ឌមួយចំនួន ប្រធាន គ.ក.ស.ក រាជធានី ខេត្ត នាយករដ្ឋបាលរាជធានី ខេត្ត ប្រធានមន្ទីរជំនាញ និងនាយកទីចាត់ការមួយចំនួននៃសាលារាជធានី ខេត្ត តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលមួយចំនួន ព្រមទាំងមន្ត្រី បុគ្គលិករបស់លេខាធិការដ្ឋាន គ.ជ.អ.ប។

ឯកសារ ផ.ស.ថ ឆ្នាំ២០១៦នេះ បរិយាយអំពីលទ្ធផលរំពឹងទុកជាអាទិភាពចំនួន**៣៥**ដែលត្រូវសម្រេចនៅក្នុងឆ្នាំ២០១៦។ យុទ្ធសាស្ត្រ និងសកម្មភាពលម្អិតសម្រាប់ការអនុវត្តលទ្ធផលរំពឹងទុកមួយចំនួនមានបរិយាយបន្ថែមនៅក្នុងឯកសារដោយឡែកដូចមានគូសបញ្ជាក់នៅក្នុងតារាងខាងក្រោម ៖

**តារាងទី១៖ លទ្ធផលរំពឹងទុកមួយចំនួន និងឯកសារពាក់ព័ន្ធ**

| លទ្ធផលរំពឹងទុក | ឯកសារលម្អិត |
|---|---|
| លទ្ធផលរំពឹងទុកទី៣នៃសមិទ្ធផលរំពឹងទុកទី១ | យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងរបស់ គ.ជ.អ.ប |
| លទ្ធផលរំពឹងទុកទី៦នៃសមិទ្ធផលរំពឹងទុកទី១ | ផែនការយុទ្ធសាស្ត្រ និងផែនការប្រចាំឆ្នាំនៃគម្រោងលើកកម្ពស់សេវាសមាគមក្រុមប្រឹក្សា |
| លទ្ធផលរំពឹងទុកទី២នៃសមិទ្ធផលរំពឹង | ផែនការអនុវត្តរយៈពេល៣ឆ្នាំនៃផែនការយុទ្ធសាស្ត្រស្តីពី |

| លទ្ធផលរំពឹងទុក | ឯកសារលម្អិត |
|---|---|
| ទុកទី២ | ការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| លទ្ធផលរំពឹងទុកទី៥នៃសមិទ្ធផលរំពឹងទុកទី២ | សេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក |
| លទ្ធផលរំពឹងទុកទី៤នៃសមិទ្ធផលរំពឹងទុកទី៣ | ឯកសារទស្សនទានរបស់គម្រោងគាំទ្រជំនួយបច្ចេកទេសសម្រាប់ការរៀបចំគម្រោង គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| លទ្ធផលរំពឹងទុកទី៥នៃសមិទ្ធផលរំពឹងទុកទី៣ | ឯកសារគម្រោងស្តីពីកិច្ចអភិវឌ្ឍវិស័យគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវា សាធារណៈបែបវិមជ្ឈការ គាំទ្រមូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| លទ្ធផលរំពឹកទុកទី២នៃសមិទ្ធផលរំពឹងទុកទី៤ | ឯកសារគម្រោងនានាដូចជា ADB/TS-PRSDP, UNCDF/LGCCII, IFAD/ ASPIRE... |
| លទ្ធផលរំពឹងទុកទី៣នៃសមិទ្ធផលរំពឹងទុកទី៤ | សេចក្តីព្រាងផែនការសកម្មភាពស្តីពីការផ្ទេរមុខងាររបស់ក្រសួងអប់រំ យុវជន និងកីឡា |
| លទ្ធផលរំពឹងទុកទី១១នៃសមិទ្ធផលរំពឹងទុកទី៤ | លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធយន្តការផ្តល់សេវារដ្ឋបាល |

**គ. ចំណុចដៅជាអាទិភាពសម្រាប់ឆ្នាំ២០១៦**

ក្នុងឆ្នាំ២០១៦ ចំណុចដៅជាអាទិភាពដែលត្រូវសម្រេចឱ្យបានមានចំនួន**១៥**។ ចំណុចដៅទាំងនេះត្រូវបានបង្ហាញ និងពិភាក្សាក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦របស់ គ.ជ.អ.ប. ដែលបានរៀបចំឡើងកាលពីថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០១៥។ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប បានគូសបញ្ជាក់នៅក្នុងសុន្ទរកថាបិទសិក្ខាសាលាអំពីសារសំខាន់នៃការផ្ទេរមុខងារសំខាន់ៗមួយចំនួន ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ការធានាដល់ការរៀបចំឱ្យបានទាន់ពេលវេលានូវយន្តការនៃការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌដើម្បីជៀសវាងការពន្យារពេលការផ្ទេរមុខងារ ការផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុកាន់តែច្រើន ពិសេសចំណូលផ្ទាល់ ការដាក់ឱ្យអនុវត្តនូវនីតិវិធីនានាសម្រាប់ការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាព ការផ្តល់ស្វ័យភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន ការលើកកម្ពស់គណនេយ្យភាពសង្គម និងការបញ្ជ្រាបយេនឌ័រ។

ចំណុចដៅជាអាទិភាពទាំង១៥នេះបង្ហាញពីការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតរបស់ផអ៣ទី២ទៅលើការលើកកម្ពស់ការផ្តល់សេវា។ ជាក់ស្តែង ចំណុចដៅជាអាទិភាពចំនួន៧នៃចំណុច

ដៅជាអាទិភាពទាំង១៥ផ្តោតជាសំខាន់លើការផ្ទេរមុខងារ និងការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌចាំបាច់នានាសម្រាប់គាំទ្រការផ្តល់សេវាទាំងនេះ។ ចំណុចដៅចំនួន៤ផ្សេងទៀតរួមចំណែកក្នុងការសម្រេចនូវគោលដៅរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ដែលពាក់ព័ន្ធនឹងគណនេយ្យភាពសង្គម ការបង្កើតមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការគ្រប់គ្រងធនធាន មនុស្សតាមបែបវិមជ្ឈការ និងការបង្កើតប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។[1]

គួរកត់សម្គាល់ថា ការកំណត់ចំណុចដៅជាអាទិភាពទាំងនេះមិនពាក់ព័ន្ធនឹងទំហំថវិកាចំណាយរបស់លទ្ធផលរំពឹងទុកនីមួយៗនោះឡើយ។ លទ្ធផលរំពឹងទុកមួយចំនួនមានទំហំថវិកាចំណាយតិច ប៉ុន្តែត្រូវបានកំណត់ជាចំណុចដៅជាអាទិភាព ចំណែកឯលទ្ធផលរំពឹងទុកមួយចំនួនទៀតមានថវិកាចំណាយច្រើន ប៉ុន្តែពុំត្រូវបានកំណត់ជាចំណុចដៅជាអាទិភាពនោះឡើយ។ ចំណាយរបស់លទ្ធផលរំពឹងទុកភាគច្រើន គឺជាចំណាយផ្ទាល់របស់លទ្ធផលរំពឹងទុកនោះ ដោយមិនរួមបញ្ចូលនូវចំណាយពាក់ព័ន្ធមួយចំនួនទៀតដូចជា ចំណាយជំនួយបច្ចេកទេស ចំណាយប្រតិបត្តិការទូទៅរបស់កម្មវិធី (ដែលចំណាយទាំងនេះបានដាក់បញ្ចូលក្នុងលទ្ធផលរំពឹងទុកទី២នៃសមិទ្ធផលរំពឹងទុកទី១) និងចំណាយនៃការអភិវឌ្ឍសមត្ថភាព និងការផ្សព្វផ្សាយនោះឡើយ (ដែលចំណាយទាំងនេះបានដាក់បញ្ចូលក្នុងលទ្ធផលរំពឹងទុកទី៣ នៃសមិទ្ធផលរំពឹងទុកទី៣)។ អាស្រ័យហេតុនេះ លទ្ធផលរំពឹងទុកណាដែលបានបញ្ចូលនូវប្រភេទចំណាយទាំងនេះ នោះនឹងធ្វើឱ្យថវិកាចំណាយសម្រាប់លទ្ធផលរំពឹងទុកនោះមានទំហំធំ។

ចំណុចដៅជាអាទិភាពទាំង១៥ដែលត្រូវសម្រេចឱ្យបានក្នុងឆ្នាំ២០១៦រួមមាន ៖

**១. ការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ដោយរួមបញ្ចូលទាំងការប្រឹក្សាយោបល់ និងការផ្លាស់ប្តូរព័ត៌មានជាប្រចាំ និងបើកចំហនៅក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុកទី៣នៃសមិទ្ធផលរំពឹងទុកទី១)**

- ត្រីមាសទី១ ៖ រៀបចំផលិតប័ណ្ណផ្សព្វផ្សាយព័ត៌មានអំពីកំណែទម្រង់នានា ដោយប្រើប្រាស់នូវពាក្យពេចន៍សាមញ្ញ និងងាយយល់។
- ត្រីមាសទី២ ៖ រៀបចំ និងសាកល្បងនូវការផ្សព្វផ្សាយផ្ទាំងរូបភាពដែលផ្តល់ព័ត៌មាននានាអំពីកំណែទម្រង់។
- ត្រីមាសទី៣ ៖ អនុវត្តវិធីសាស្ត្រនានានៃការលើកកម្ពស់ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្សព្វផ្សាយព័ត៌មាននានានៅក្នុងតំបន់គោលដៅស្តីពីកំណែទម្រង់ ដើម្បីលើកកម្ពស់ការយល់ដឹងឱ្យបានទូលំទូលាយអំពីការងារកំណែទម្រង់។

---

[1] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានកំណត់ ៖ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវក្របខ័ណ្ឌគតិយុត្តស្តីពីការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០១៦។ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០១៥ និងការគាំទ្រថវិកាតាមរយៈមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនយ៉ាងតិច១០លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨។ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០១៥ ហើយបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ (លើកលែងគណៈអភិបាល និងនាយករដ្ឋបាលរាជធានី ខេត្ត) នឹងត្រូវស្ថិតក្រោមការគ្រប់គ្រង បំពេញការងារ និងមានគណនេយ្យភាពចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ។

ត្រីមាសទី៤ ៖ រៀបចំ និងអនុវត្តបណ្តាញទំនាក់ទំនងសង្គម ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ មន្ត្រីរាជការ និងអ្នកពាក់ព័ន្ធនានាក្នុងកិច្ចដំណើរការកំណែទម្រង់នានា។

**២. ការប្រឹក្សាយោបល់ជាប្រចាំអំពីកំណែទម្រង់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយក្រសួង ស្ថាប័នអនុវត្តនានា (លទ្ធផលរំពឹងទុកទី៤នៃសមិទ្ធផលរំពឹងទុកទី១)**

ត្រីមាសទី១ ៖ ការរៀបចំបង្កើតក្រុមការងារអន្តរក្រសួងនានា សម្រាប់គាំទ្រដល់ការផ្ទេរមុខងាររបស់ក្រសួង ស្ថាប័ននានាដែលបាន និងកំពុងរៀបចំផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ត្រីមាសទី២-៤ ៖ លេខាធិការដ្ឋាន គ.ជ.អ.ប រៀបចំកិច្ចប្រជុំយ៉ាងតិចចំនួន២ដងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់ការយល់ដឹងអំពីចក្ខុវិស័យ គោលនយោបាយ និងគោលដៅនានានៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**៣. ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម និងការរៀបចំផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមរបស់ឃុំគោលដៅចំនួន៣០០ ក្នុងស្រុកគោលដៅយ៉ាងតិចចំនួន៥១ ដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាននានា (លទ្ធផលរំពឹងទុកទី២នៃសមិទ្ធផលរំពឹងទុកទី២)**

ត្រីមាសទី១ ៖ ការផ្សព្វផ្សាយអំពីការងារគណនេយ្យភាពសង្គមរបស់ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការបានអនុវត្តចប់នៅឃុំគោលដៅទាំងអស់។

ត្រីមាសទី២ ៖ ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4C) ត្រូវបានបិតផ្សាយនៅគ្រប់ស្រុក និងឃុំគោលដៅទាំងអស់។

ត្រីមាសទី៣ ៖ ប័ណ្ណដាក់ពិន្ទុរបស់ប្រជាពលរដ្ឋត្រូវបានអនុវត្តចប់នៅក្នុងឃុំគោលដៅទាំងអស់។

ត្រីមាសទី៣ ៖ ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមរបស់ឃុំគោលដៅនីមួយៗត្រូវបានរៀបចំរួចរាល់។

**៤. ការពិនិត្យ ការកែសម្រួល និងការអនុវត្តនូវយន្តការដោះស្រាយពាក្យបណ្តឹងមានលក្ខណៈជាប្រព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់នូវយន្តការនេះ (លទ្ធផលរំពឹងទុកទី៣នៃសមិទ្ធផលរំពឹងទុកទី២)**

ត្រីមាសទី១ ៖ រៀបចំលិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំបច្ចេកទេសពាក់ព័ន្ធនឹងការរៀបចំយន្តការដោះស្រាយពាក្យបណ្តឹង ដែលមានលក្ខណៈជា

ប្រព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ត្រីមាសទី៣ ៖ ផ្សព្វផ្សាយ និងអនុវត្តនូវយន្តការដោះស្រាយពាក្យបណ្តឹងដែលមានលក្ខណៈជាប្រព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៥. ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុកទី១នៃសមិទ្ធផលរំពឹងទុកទី៣)**

ត្រីមាសទី១ ៖ រៀបចំ និងអនុម័តលិខិតបទដ្ឋាន សេចក្តីណែនាំ និងសៀវភៅណែនាំនានាអំពីកិច្ចដំណើរការ និងនីតិវិធីនានានៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ត្រីមាសទី២ ៖ ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋាន និងសេចក្តីណែនាំនានា

ត្រីមាសទី២ ៖ រៀបចំ និងអនុម័តនូវយុទ្ធសាស្ត្រស្តីពីការបង្កើនភាគរយស្ត្រីនៅក្នុងមុខតំណែងដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ត្រីមាសទី៣ ៖ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការត្រូវបានអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់។

**៦. ការផ្ទេរមុខងារគ្រប់គ្រងការអប់រំបឋមសិក្សា ការអប់រំកុមារតូច និងការអប់រំក្រៅប្រព័ន្ធទៅឱ្យក្រុង ស្រុកទាំងអស់នៅក្នុងខេត្តគោលដៅចំនួនមួយ (លទ្ធផលរំពឹងទុកទី៣នៃសមិទ្ធផលរំពឹងទុកទី៤)**

ត្រីមាសទី១- ២៖ រៀបចំ និងអនុម័តលិខិតបទដ្ឋាននានាសម្រាប់ផ្ទេរមុខងារ និងធនធានហិរញ្ញវត្ថុ និងធនធានមុនុស្សទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង។

ត្រីមាសទី២ ៖ ផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តនូវមុខងារដែលបានផ្ទេរ

ត្រីមាសទី៤ ៖ សិក្សាវាយតម្លៃ ប្រមូលចងក្រងបទពិសោធន៍នៃការអនុវត្តនូវមុខងារដែលបានផ្ទេរដើម្បីពង្រីកការផ្ទេរមុខងារនេះទៅក្រុង ស្រុកក្នុងខេត្តគោលដៅមួយចំនួនថែមទៀតក្នុងឆ្នាំ២០១៧។

**៧. រដ្ឋបាលរាជធានី រដ្ឋបាលក្រុង ស្រុកទាំងអស់អនុវត្តនូវមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព (លទ្ធផលរំពឹងទុកទី៤នៃសមិទ្ធផលរំពឹងទុកទី៤)**

ត្រីមាសទី១ ៖ រៀបចំ ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាស្តីពីការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

ត្រីមាសទី៤ ៖ សិក្សាវាយតម្លៃអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

៨. **ការផ្ទេរមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល និងការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ក្នុងខេត្តគោលដៅចំនួនមួយ (លទ្ធផលរំពឹងទុកទី៥នៃសមិទ្ធផលរំពឹងទុកទី៤)**

ត្រីមាសទី១-២៖ បុគ្គលិក និងធនធាននានាត្រូវបានផ្ទេរជាបណ្តោះអាសន្ន ដើម្បីអនុវត្តមុខងារដែលបានផ្ទេរ។

ត្រីមាសទី៤ ៖ សិក្សាវាយតម្លៃ ប្រមូលចងក្រងបទពិសោធន៍នៃការអនុវត្តនូវមុខងារដែលបានផ្ទេរ ដើម្បីពង្រីកការផ្ទេរមុខងារនេះទៅក្រុង ស្រុកក្នុងខេត្តគោលដៅមួយចំនួនថែមទៀតក្នុងឆ្នាំ២០១៧។

៩. **ការផ្ទេរមុខងារគាំពារសុខភាពបឋមទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន (លទ្ធផលរំពឹងទុកទី៦នៃសមិទ្ធផលរំពឹងទុកទី៤)**

ត្រីមាសទី១ ៖ ឯកភាពលើមុខងារសំខាន់ៗ ដែលត្រូវផ្ទេរ រួមបញ្ចូលទាំងយុទ្ធសាស្ត្ររយៈពេលវែង សម្រាប់ការផ្ទេរមុខងារគ្រប់គ្រងសំណុំសកម្មភាពអប្បបរមានៃសេវាសុខាភិបាល។

ត្រីមាសទី២ ៖ រៀបចំ ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាននានា ដើម្បីផ្ទេរមុខងារ និងធនធានទៅឱ្យក្រុង ស្រុក ខណ្ឌមួយចំនួន។

ត្រីមាសទី៤ ៖ សិក្សាវាយតម្លៃ ប្រមូលចងក្រងបទពិសោធន៍នៃការអនុវត្តនូវមុខងារដែលបានផ្ទេរដើម្បីពង្រីកការផ្ទេរមុខងារនេះទៅក្រុង ស្រុកក្នុងខេត្តគោលដៅមួយចំនួនថែមទៀតក្នុងឆ្នាំ២០១៧។

១០. **បន្តគាំទ្រការអនុវត្តសាកល្បងនៃការផ្ទេរមុខងារគ្រប់គ្រងអនាម័យជនបទ និងការគ្រប់គ្រងការថែទាំ និងការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទៅ ស្រុកគោលដៅមួយចំនួន (លទ្ធផលរំពឹងទុកទី៨នៃសមិទ្ធផលរំពឹងទុកទី៤)**

ត្រីមាសទី១ ដាក់ឱ្យអនុវត្តឱ្យបានពេញលេញនូវមុខងារគ្រប់គ្រងអនាម័យជនបទ និងការគ្រប់គ្រង ការថែទាំ និងការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទៅស្រុកគោលដៅមួយចំនួន

ត្រីមាសទី៣ ៖ សិក្សាវាយតម្លៃការសាកល្បង ដើម្បីពិនិត្យលទ្ធភាពពង្រីកការផ្ទេរមុខងារទៅស្រុកដទៃទៀត។

**១១. ការផ្ទេរមុខងារការថែទាំផ្លូវលំជនបទមានលក្ខណៈជាប្រចាំទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅមួយចំនួន (លទ្ធផលរំពឹងទុកទី៧នៃសមិទ្ធផលរំពឹងទុកទី៤)**

ត្រីមាសទី១ ៖ ការឯកភាពជាគោលការណ៍អំពីប្រភេទផ្លូវលំជនបទ និងមុខងារថែទាំផ្លូវទាំងនោះដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលរដ្ឋបាលថ្នាក់ក្រោមជាតិ។

ត្រីមាសទី២ ៖ រៀបចំ ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាននានា ដើម្បីផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ត្រីមាសទី៤ សិក្សាវាយតម្លៃ ប្រមូលចងក្រងបទពិសោធន៍នៃការអនុវត្តនូវមុខងារដែលបានផ្ទេរ ដើម្បីពង្រីកការផ្ទេរមុខងារនេះទៅក្រុង ស្រុកក្នុងខេត្តគោលដៅមួយចំនួនថែមទៀតក្នុងឆ្នាំ២០១៧។

**១២. ការព្រមព្រៀងទៅលើមុខងារសេវាទីប្រជុំជនសមស្របមួយចំនួនរបស់រដ្ឋបាលខេត្ត ដើម្បីផ្ទេរទៅឱ្យរដ្ឋបាលក្រុងនៅឆ្នាំ២០១៧ (លទ្ធផលរំពឹងទុកទី១០នៃសមិទ្ធផលរំពឹងទុកទី៤)**

ត្រីមាសទី១-២ ៖ សិក្សាវាយតម្លៃ និងឯកភាពអំពីមុខងារនានាដែលត្រូវផ្ទេរ។

ត្រីមាសទី៣ ៖ រៀបចំលិខិតបទដ្ឋាន និងសេចក្តីណែនាំចាំបាច់នានា ដើម្បីធានាការចាប់ផ្តើមផ្ទេរមុខងារក្នុងឆ្នាំ២០១៧។

**១៣. ការរៀបចំ និងដាក់ឱ្យអនុវត្តនូវយន្តការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌ ដើម្បីគាំទ្រដល់ការផ្ទេរមុខងារ (លទ្ធផលរំពឹងទុកទី២នៃសមិទ្ធផលរំពឹងទុកទី៥)**

ត្រីមាសទី១ ៖ អនុក្រឹត្យស្តីពីយន្តការនៃការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌ ត្រូវបានអនុម័ត។

ត្រីមាសទី២ ៖ រៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំពាក់ព័ន្ធនានាសម្រាប់អនុវត្តអនុក្រឹត្យស្តីពីការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌ

ត្រីមាសទី២ ៖ ធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌនានាត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរ ស្របតាមអនុក្រឹត្យនេះ

**១៤. ការរៀបចំ និងអនុម័តគោលនយោបាយ និងលិខិតបទដ្ឋាននានាស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុកទី៣នៃសមិទ្ធផលរំពឹងទុកទី៥)**

ត្រីមាសទី១ ៖ ការសិក្សា ការវិភាគ និងការឯកភាពអំពីប្រភពចំណូលត្រូវបានបញ្ចប់។

ត្រីមាសទី២ ៖ ការរៀបចំ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំចាំបាច់នានាសម្រាប់អនុវត្តចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ត្រីមាសទី២ ៖ ការរៀបចំវគ្គបណ្តុះបណ្តាលនានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការប្រមូលចំណូលផ្ទាល់។

**១៥. ការរៀបចំ និងការអនុម័តនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំនានា សម្រាប់ការរៀបចំ និងការអនុវត្តគម្រោងគាំទ្រដោយមូលនិធិវិនិយោគថ្នាក់ក្រោមជាតិ ដើម្បីជានាការអនុវត្តនៅឆ្នាំ២០១៧ (លទ្ធផលរំពឹងទុកទី៤នៃសមិទ្ធផលរំពឹងទុកទី៥)**

ត្រីមាសទី១ ៖ អនុក្រឹត្យស្តីពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័ត

ត្រីមាសទី១ ៖ លេខាធិការដ្ឋាននៃមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្កើត និងដំណើរការ។

ត្រីមាសទី២ ៖ ការរៀបចំលិខិតបទដ្ឋាន និងសេចក្តីណែនាំនានា។

ត្រីមាសទី៣ ៖ ធនធានឆ្នាំ២០១៧ត្រូវបានជូនព័ត៌មានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

ត្រីមាសទី៤ ៖ សំណើគម្រោងវិនិយោគនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានវាយតម្លៃ និងអនុម័តដោយគណៈកម្មាធិការ ដើម្បីចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០១៧។

## ២. ថវិកានៃផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ (ផ.ស.ថ)

### ២.១. ផែនការចំណាយ

ថវិការបស់ ផ.ស.ថ បែងចែកជាពីរផ្នែក ពោលគឺថវិកាសម្រាប់គាំទ្រការងារកំណែទម្រង់ ដូចជាសកម្មភាពពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធគាំទ្រ ការអភិវឌ្ឍស្ថាប័ន និងការពង្រឹងសមត្ថភាពបុគ្គល និងថវិកាសម្រាប់ការផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ចំណាយទៅលើការផ្តល់សេវានានា និងការគាំទ្រកិច្ចការរដ្ឋបាលទូទៅ។ ចំណាយនានាពាក់ព័ន្ធនឹង ការគាំទ្រកំណែទម្រង់បែងចែកជា៣ផ្នែកធំៗគឺ ៖

1. **ចំណាយសម្រាប់សកម្មភាព** ៖ គឺជាចំណាយសម្រាប់លទ្ធផលរំពឹងទុកនានានៃការងារកំណែទម្រង់ និងត្រូវបានគណនាដោយផ្អែកជាមូលដ្ឋានលើធាតុចូលនានាដែលត្រូវការ ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកទាំងនោះ។ ចំណាយទាំងនេះរួមមាន ការរៀបចំសិក្ខាសាលា កិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលនានា ក៏ដូចជាចំណាយសម្រាប់ការគ្រប់គ្រងប្រព័ន្ធនានា និងចំណាយសម្រាប់ការត្រួតពិនិត្យតាមដានការអនុវត្តកម្មវិធី។
2. **ចំណាយសម្រាប់ជំនួយបច្ចេកទេស** ៖ រួមមានចំណាយសម្រាប់ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យានានាដែលបានជ្រើសរើស និងផ្តល់កិច្ចសន្យា ដើម្បីគាំទ្រដល់ការសម្រេចនូវលទ្ធផលរំពឹងទុកជាក់លាក់នានា។
3. **ចំណាយសម្រាប់ប្រតិបត្តិការ** ៖ ចំណាយនេះត្រូវបានវិភាជឱ្យទៅស្ថាប័នអនុវត្តថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីរ៉ាប់រងចំណាយនានាដូចជា ការថែទាំរថយន្ត ការផ្គត់ផ្គង់សម្ភារ បរិក្ខារការិយាល័យ និងការប្រាស្រ័យទាក់ទងនានា សម្រាប់ការគាំទ្រ និងការសម្របសម្រួល ដើម្បីសម្រេចបាននូវសកម្មភាព ឬព្រឹត្តិការណ៍សំខាន់ៗ និងលទ្ធផលរំពឹងទុកនីមួយៗ។

សេចក្តីសង្ខេបអំពីគម្រោងចំណាយខាងលើមានរៀបរាប់ក្នុងតារាងខាងក្រោម ៖

### តារាងទី២ ៖ ផែនការចំណាយសម្រាប់ឆ្នាំ២០១៦ (គិតជាដុល្លារ)

| ប្រភេទសកម្មភាព | រាជរដ្ឋាភិបាល | កញ្ចប់រួមរបស់ដៃគូ | គម្រោងនានារបស់ដៃគូ | សរុប | |
|---|---|---|---|---|---|
| **១. ការងារកំណែទម្រង់** | **200,000** | **11,249,000** | **17,507,060** | **28,956,060** | **7.63%** |
| **ក. សកម្មភាព** | **200,000** | **4,392,364** | **17,507,060** | **22,099,425** | **5.82%** |
| សមិទ្ធផលទី១ ៖ ការគ្រប់គ្រងការងារកំណែទម្រង់ | 200,000 | 1,424,922 | 2,000,000 | 3,624,922 | 0.96% |
| សមិទ្ធផលទី២ ៖ គណនេយ្យភាពបែបប្រជាធិបតេយ្យ | 0 | 563,742 | 3,000,000 | 3,563,742 | 0.94% |
| សមិទ្ធផលទី៣ ៖ ការគ្រប់គ្រងធនធានមនុស្ស | 0 | 1,269,365 | 6,749,124 | 8,018,489 | 2.11% |
| សមិទ្ធផលទី៤ ៖ ការផ្តល់សេវា និងមុខងារ | 0 | 811,025 | 4,417,596 | 5,228,621 | 1.38% |
| សមិទ្ធផលទី៥ ៖ វិមជ្ឈការហិរញ្ញវត្ថុ | 0 | 323,310 | 1,340,340 | 1,663,650 | 0.44% |
| **ខ. ចំណាយប្រតិបត្តិការ** | **0** | **1,829,200** | **0** | **1,829,200** | **0.48%** |
| **គ. ជំនួយបច្ចេកទេស** | **0** | **5,027,436** | **0** | **5,027,436** | **1.33%** |
| **២. ការផ្ទេរថវិកា (ការផ្តល់សេវា)** | **343,119,000** | **500,000** | **6,825,360** | **350,444,360** | **92.37%** |
| **៣. សរុបរួម ( ១+២ )** | **343,319,000** | **11,749,000** | **24,332,420** | **379,400,420** | **100.00%** |
| **ភាគរយ** | **90.49%** | **3.10%** | **6.41%** | **100.00%** | |

### ខ.២. ជំនួយបច្ចេកទេស

ក្នុងឆ្នាំ២០១៦ មានទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាសរុបចំនួន៦៧៥នាក់ ដែលត្រូវការសម្រាប់គាំទ្រការអនុវត្ត ផ.ស.ថ ឆ្នាំ២០១៦ ដែលមានថវិកាសរុបចំនួនជិត៥លានដុល្លារ។ ការបែងចែកតួនាទី និងការទទួលខុសត្រូវរវាងទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យា គឺជាកិច្ចការដ៏ចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការគាំទ្របច្ចេកទេស។ ទីប្រឹក្សាត្រូវបានជ្រើសរើស និងផ្តល់កិច្ចសន្យាការងារដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងគម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍន៍ក្នុងកម្រិតប្រាក់បៀវត្សមួយដែលមានលក្ខណៈប្រកួតប្រជែងជាមួយអង្គការអន្តរជាតិនានាក្នុងគោលបំណង ១). ការអភិវឌ្ឍសមត្ថភាព និង ២). ការបំពេញកិច្ចការនានារបស់កម្មវិធីដែលផ្តល់ហិរញ្ញប្បទានពីខាងក្រៅ។ បុគ្គលិកកិច្ចសន្យាត្រូវបានជ្រើសរើសជាបឋមដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានកម្រិតប្រាក់បៀវត្សប្រហាក់ប្រហែលនឹងកម្រិតប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល ដើម្បីជួយពង្រឹងសមត្ថភាពមន្ត្រីរាជការដែលនៅខ្វះចន្លោះក្នុងការបំពេញការងារចាំបាច់មួយចំនួន។

ផអ៣ដំណាក់កាលទី២ មានគោលដៅកាត់បន្ថយចំនួនជំនួយបច្ចេកទេស ដើម្បីធានាភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់មន្ត្រីរាជការ និងបង្កើនការវិនិយោគធនធានបន្ថែមទៀតក្នុងការអនុវត្តសកម្មភាពនានា។ រូបភាពទី១ខាងក្រោមនេះបង្ហាញអំពីកម្រិតជំនួយបច្ចេកទេស ដែលត្រូវបានកាត់បន្ថយតាមឆ្នាំនីមួយៗ (ពីឆ្នាំ២០១២ដល់ឆ្នាំ២០១៧)។ អាស្រ័យហេតុនេះ ការកាត់បន្ថយចំនួនជំនួយបច្ចេកទេសដែលជាចំណុចដៅជាអាទិភាពមួយនៃផអ៣ទី២ បាន និងកំពុងអនុវត្តយ៉ាងត្រឹមត្រូវ ស្របតាមផែនការដែលបានគ្រោងទុក។ ព័ត៌មានលម្អិតស្តីពីផែនការជំនួយបច្ចេកទេសសម្រាប់ឆ្នាំ២០១៦ មានរៀបរាប់នៅក្នុងឧបសម្ព័ន្ធទី៣។

**រូបភាពទី១ ៖ និន្នាការស្តីពីថវិកាជំនួយបច្ចេកទេស (គិតជាលានដុល្លារ)**




### ២.៣. ថវិការាជរដ្ឋាភិបាល

ថវិការបស់រាជរដ្ឋាភិបាល តាមរយៈការផ្ទេរថវិការដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមបានកើនឡើងក្នុងអត្រាប្រមាណ១៧%ក្នុងមួយឆ្នាំ (រូបភាពទី២)។ ក្នុងឆ្នាំ២០១៦ ថវិការបស់រាជរដ្ឋាភិបាលដែលបានផ្ទេរទៅឱ្យមូលនិធិឃុំ សង្កាត់កើនដល់៧៦,២លានដុល្លារអាមេរិក មូលនិធិក្រុង ស្រុកកើនដល់ចំនួន ២៤,៥ លានដុល្លារអាមេរិក និងថវិការាជធានី ខេត្តកើនដល់ចំនួន២២៥,៨លានដុល្លារអាមេរិក (តារាងទី៣)។ ក្នុងឆ្នាំ២០១៦ មូលនិធិគាំទ្ររបស់រដ្ឋាភិបាលសម្រាប់ក្រុង ស្រុកផ្នែកអភិវឌ្ឍន៍មានចំនួនប្រមាណ៦,២ លានដុល្លារអាមេរិក ដែលជាមធ្យមស្មើនឹង៣៣.៧២០ដុល្លារសម្រាប់ក្រុង ស្រុកនីមួយៗ ឬស្មើនឹង ០,២៣%នៃចំណូលចរន្តសរុបប្រចាំឆ្នាំ២០១៥របស់រដ្ឋ។

ផ្អែកលើលទ្ធផលនៃការផ្ទេរមុខងារ រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុកនឹងទទួលបានមូលនិធិចំនួនប្រមាណជាង១៦លានដុល្លារអាមេរិកពីរាជរដ្ឋាភិបាល ដែលជាមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ។ តួលេខទាំងនេះ គឺជាការប៉ាន់ស្មានបឋមដែលរួមបញ្ចូលប្រាក់បៀវត្ស ចំណាយប្រតិបត្តិការ និងការវិនិយោគនានា។ ការប៉ាន់ប្រមាណនេះមិនគិតបញ្ចូលនូវការគាំទ្រពុំមែនជាថវិកានានា ដូចជាថ្លៃឱសថ និងសៀវភៅសិក្សានោះឡើយ។ នៅពេលដែលវិសាលភាពនៃការផ្ទេរមុខងារត្រូវបានពង្រីក (ភាគច្រើននឹងអនុវត្តសាកល្បងក្នុងខេត្តគោលដៅចំនួនមួយក្នុងឆ្នាំ២០១៦) នោះចំណុចដៅក្នុងការបង្កើនការវិភាជថវិការដ្ឋទៅឱ្យឃុំ សង្កាត់ និងក្រុង ស្រុកនឹងកើនឡើងរហូតដល់៧,២%ក្នុងឆ្នាំ២០១៧[2]។

ក្រៅពីមូលនិធិគាំទ្រខាងលើ នៅមានប្រភពមូលនិធិផ្សេងទៀតដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ តាមរយៈគម្រោង កម្មវិធីនានាបានផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ដល់មូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក។ ការចូលរួមចំណែកពីគម្រោង កម្មវិធីទាំងនេះ[3]មានចំនួនប្រមាណ១,១លានដុល្លារ។

[2] ដូចបានកំណត់ក្នុងក្របខ័ណ្ឌលទ្ធផលនៃផអ៣ទី២ គោលបំណងសំខាន់គឺការបង្កើនការទទួលខុសត្រូវរបស់ឃុំ សង្កាត់ និងក្រុង ស្រុក ហើយការវិភាជថវិកាត្រូវបានប្រើប្រាស់ជាសូចនាករនៃការទទួលខុសត្រូវនេះ។ ក្នុងករណីការគ្រប់គ្រងកាកសំណល់រឹង ការគាំទ្រថវិកាភាគច្រើននឹងធ្វើឡើង តាមរយៈការបង់ថ្លៃប្រើប្រាស់ ដូច្នេះ ការវិភាជថវិកាមិនទាន់បានបញ្ចូលនូវកម្រិតនៃមុខងារដែលនឹងត្រូវផ្ទេរនៅឡើយទេ។

[3] ជាធម្មតាមូលនិធិទាំងនេះត្រូវបានផ្ទេរចូលទៅក្នុងមូលនិធិឃុំសង្កាត់ និងក្រុង ស្រុក ដែលមូលនិធិទាំងនេះត្រូវបានរៀបចំឡើងជាយន្តការមូលនិធិដោយគ្មានភ្ជាប់លក្ខខណ្ឌ។ អនុក្រឹត្យស្តីពីការផ្តល់មូលនិធិមានភ្ជាប់លក្ខខណ្ឌត្រូវបានរំពឹងថានឹងអធិប្បាយបញ្ហានេះ។

## រូបភាពទី២ ៖ និន្នាការស្តីពីការផ្ទេរថវិការដ្ឋ (គិតជាលានដុល្លារ)




## តារាងទី៣៖ ការផ្ទេរថវិកាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (គិតជាដុល្លារ)

| ល.រ | ប្រភេទថវិកា | ថវិកា | ភាគរយ | សម្គាល់ |
|---|---|---|---|---|
| ១ | ថវិការាជធានី ខេត្ត | 225,840,000 | 64.44% | ៩លានជាមធ្យមក្នុងមួយខេត្ត |
| ២ | មូលនិធិក្រុង ស្រុក | 24,480,000 | 6.99% | ១៣០.០០០ជាមធ្យមក្នុងមួយស្រុក |
| ៣ | មូលនិធិឃុំ សង្កាត់ | 76,150,000 | 21.73% | ៤៦.០០០ជាមធ្យមក្នុងមួយឃុំ |
| ៤ | មូលនិធិមានភ្ជាប់លក្ខខណ្ឌរបស់ រាជរដ្ឋាភិបាល | **16,649,000** | **4.75%** | ការផ្ទេរមុខងារនានា |
| | ៤.១. ការអប់រំ | 12,000,000 | 3.42% | ការប៉ាន់ស្មានសម្រាប់ខេត្តចំនួនមួយ គឺខេត្តបាត់ដំបងដែលមានក្រុង ស្រុកចំនួន១៤[4]។ ចំណាយសរុបរបស់បុគ្គលិកគឺ៤.៩៨៥នាក់x១៦២ដុល្លារក្នុងមួយខែ។ ចំណាយកិច្ចប្រតិបត្តិការ៣.០០០គឺដុល្លារក្នុងមួយស្រុក។ មូលនិធិសម្រាប់កែលម្អគុណភាពអប់រំ គឺ១.៥៣៦ ដុល្លារx៦២៣/សាលា និងការគាំទ្រមិនមែនជាថវិកា/ ការវិយោគនានា មានចំនួនប្រមាណ១,៥លានដុល្លារ ។ |
| | ៤.២. សុខភាពបឋម | 960,000 | 0.27% | ការផ្ទេរមុខងារគ្រប់គ្រងមណ្ឌលសុខភាពក្នុងការិយាល័យស្រុកប្រតិបត្តិសុខាភិបាលចំនួន៤។ ការប៉ាន់ស្មាន ៤ការិយាល័យx៤០.០០០ដុល្លារ x មណ្ឌលសុខភាពចំនួន៦ជាមធ្យមក្នុងមួយស្រុក។ |
| | ៤.៣. ការគ្រប់គ្រងសំរាម សំណល់រឹង | 2,000,000 | 0.57% | ការប៉ាន់ស្មានសម្រាប់ក្រុង ស្រុកទាំងអស់ |
| | ៤.៤. ការអភិរក្សធនធានធម្មជាតិ | 62,500 | 0.02% | ការប៉ាន់ស្មានសម្រាប់ក្រុង ស្រុកទាំងអស់ |
| | ៤.៥. ការងារសង្គមកិច្ច | 250,000 | 0.07% | ការប៉ាន់ស្មានផ្អែកលើថវិកាឆ្នាំ២០១៦ |
| | ៤.៦. អនាម័យជនបទ | 26,500 | 0.01% | ការប៉ាន់ស្មានតំបន់គោលដៅសាកល្បង |
| | ៤.៧. ការគ្រប់គ្រងផ្លូវលំជនបទ | 850,000 | 0.24% | ការប៉ាន់ស្មានផ្អែកលើថវិកាឆ្នាំ២០១៦ |
| | ៤.៨. ការិយាល័យច្រកចេញចូលតែ | 500,000 | 0.14% | ចំណាយសម្រាប់ការពង្រីក OWSO |

[4] ថវិកាប៉ាន់ស្មានសម្រាប់មួយស្រុកមានចំនួនប្រមាណ១លានដុល្លារអាមេរិក ដែលរួមបញ្ចូលចំណាយសរុបសម្រាប់ការអប់រំកម្រិតបឋមសិក្សា មត្តេយ្យសិក្សា និងការអប់រំក្រៅប្រព័ន្ធនៃក្រុង ស្រុក ខណ្ឌសរុបចំនួន១៩៧។ ថវិកាសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡាមានចំនួនប្រមាណ៤៩៧លានដុល្លារអាមេរិក។ តួលេខប្រាក់បៀវត្សយកចេញពីវែបសាយ http://www.phnompenhpost.com/teachers-get-wage-hike។

| ល.រ | ប្រភេទថវិកា | ថវិកា | ភាគរយ | សម្គាល់ |
|---|---|---|---|---|
| | មួយ | | | |
| ៥ | មូលនិធិគម្រោង កម្មវិធី គាំទ្រដោយដៃគូអភិវឌ្ឍន៍ | **1,125,360** | **0.32%** | |
| | ៥.១. ការប្រែប្រួលអាកាសធាតុ | 400,000 | 0.11% | IFAD/ ASPIRE |
| | ៥.២. សេវាសង្គម | 631,360 | 0.18% | SDC, UNICEF, UNFPA, UNCDF |
| | ៥.៣. កិច្ចគាំពារផ្នែកសង្គមកិច្ច | 94,000 | 0.03% | WB/CTPMCH |
| ៦ | ថវិកាកម្ចីពីដៃគូអភិវឌ្ឍន៍ | **6,200,000** | **1.77%** | Loan ADB/TS-PRSDP |
| | **សរុប** | **350,444,360** | **100%** | |

### ២.៤. ថវិកាគាំទ្រកញ្ចប់រួម

ជារៀងរាល់ឆ្នាំ យើងត្រូវការថវិកាគាំទ្រពីសហភាពអឺរ៉ុបប្រមាណពី៥ទៅ៦លានដុល្លារអាមេរិក ដើម្បីចូលរួមក្នុងថវិកាកញ្ចប់រួម។ ដោយហេតុថា គម្រោងគាំទ្រដំណាក់កាលបន្ទាប់របស់សហភាពអឺរ៉ុប នឹងចាប់ផ្តើមពីឆ្នាំ២០១៧តទៅ អាស្រ័យហេតុនេះ ការផ្តល់មូលនិធិគាំទ្រពីសហភាពអឺរ៉ុបសម្រាប់ឆ្នាំ ២០១៦នឹងមានចំនួនប្រមាណ១,៧លានដុល្លារអាមេរិកប៉ុណ្ណោះ។ ដើម្បីដោះស្រាយកង្វះខាតនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ដោយមានកិច្ចសហការ និងភាពបត់បែនប្រកបដោយការយោគយល់របស់ ដៃគូអភិវឌ្ឍន៍នានាបានរៀបចំនិងអនុវត្តដោយជោគជ័យ និងប្រកបដោយប្រសិទ្ធភាពនូវផែនការចំណាយ ក្នុងឆ្នាំ២០១៥ និងការសន្សំថវិកាសម្រាប់ឆ្នាំ២០១៦។ ដូច្នេះ ក្នុងឆ្នាំ២០១៦ថវិកាកញ្ចប់រួមសម្រាប់គាំទ្រ ផ.ស.ថ. ឆ្នាំ២០១៦ មានប្រមាណជា១១,២លានដុល្លារអាមេរិកដែលជាតួលេខមួយមានលក្ខណៈសមស្រប ផ្អែកលើបទពិសោធន៍នៃការចំណាយសម្រាប់ការងារកំណែទម្រង់នាពេលកន្លងមក (រូបភាពទី៣)។

**រូបភាពទី៣ ៖ និន្នាការស្តីពីថវិកាកញ្ចប់រួម (គិតជាលានដុល្លារ)**




### ២.៥. ការផ្តល់មូលនិធិពីប្រភពផ្សេងទៀត

ផ.ស.ថ ២០១៦ ក៏ទទួលបាននូវគាំទ្រថវិកាពីគម្រោង និងកម្មវិធីជាច្រើនរបស់ដៃគូអភិវឌ្ឍន៍នានា។ ជារួម ថវិកាគាំទ្រសរុបរាប់បញ្ចូលទាំងថវិកាសម្រាប់សកម្មភាពនានានៃការងារគណនេយ្យភាពសង្គមដែលអនុវត្តដោយអង្គការសង្គមស៊ីវិលនានា មានចំនួនប្រមាណជាង២១លានដុល្លារអាមេរិក ឬស្មើនឹង៥,៦%នៃថវិកាសរុបរបស់ ផ.ស.ថ ឆ្នាំ២០១៦។ ការចូលរួមគាំទ្រនេះ បង្ហាញពីការខិតខំបន្សុីគ្នានូវគម្រោង និងកម្មវិធីទាំងនោះជាមួយផអ៣ទី២ និងការធ្វើសមាហរណកម្មទៅក្នុង ផ.ស.ថ ប្រចាំឆ្នាំ។

## ២.៦. សេចក្តីសន្និដ្ឋាន

ជារួម ការផ្តល់មូលនិធិគាំទ្រសរុប (តារាងទី៤) សម្រាប់ការអនុវត្ត ផ.ស.ថ ឆ្នាំ២០១៦មានចំនួនប្រមាណជាង៣៧៩លានដុល្លារអាមេរិក ដែលក្នុងនោះមួយភាគធំជាថវិការបស់រាជរដ្ឋាភិបាល មានចំនួនសរុបប្រមាណជាង៣៤៣លានដុល្លារអាមេរិក ឬស្មើនឹង៩០,៥% ដែលគាំទ្រសម្រាប់ការផ្តល់សេវាសាធារណៈ និងសកម្មភាពនានានៃការងារកំណែទម្រង់។ ថវិកាគាំទ្ររបស់រាជរដ្ឋាភិបាលពុំរាប់បញ្ចូលនូវកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ីដែលមានចំនួនប្រមាណ១៥លានដុល្លារអាមេរិក ឬស្មើនឹង៤%។ ព័ត៌មានលម្អិតអំពីការផ្តល់មូលនិធិគាំទ្រ ផ.ស.ថ. ឆ្នាំ២០១៦ មានបរិយាយនៅក្នុងទំព័របន្ទាប់។

ផ្នែកបន្ទាប់នៃឯកសារ ផ.ស.ថ នេះ គឺជាផ្នែកដ៏សំខាន់ដែលចែងអំពីចំណុចដៅ លទ្ធផលរំពឹងទុក និងគម្រោងថវិកានានាដែលត្រូវអនុវត្តក្នុងគោលបំណងឈានទៅសម្រេចឱ្យបាននូវសមិទ្ធផលរំពឹងទុកទាំង៥របស់ផអ៣ទី២។

ជាមួយគ្នានេះដែរ ឯកសារ ផ.ស.ថ. ឆ្នាំ២០១៦នេះក៏មានភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធចំនួន៥ដូចមានខាងក្រោម ៖

- ឧបសម្ព័ន្ធទី១៖ សុន្ទរកថាបើកសិក្ខាសាលាជាតិស្តីពីការរៀបចំ ផ.ស.ថ ឆ្នាំ២០១៦
- ឧបសម្ព័ន្ធទី២៖ សុន្ទរកថាបិទសិក្ខាសាលាជាតិស្តីពីការរៀបចំ ផ.ស.ថ ឆ្នាំ២០១៦
- ឧបសម្ព័ន្ធទី៣៖ ផែនការជំនួយបច្ចេកទេសឆ្នាំ២០១៦
- ឧបសម្ព័ន្ធទី៤៖ តារាងសកម្មភាព និងថវិកាលម្អិត
- ឧបសម្ព័ន្ធទី៥៖ សូចនាករ និងចំណុចដៅ

បន្ទាប់ពី ផ.ស.ថ ឆ្នាំ២០១៦ត្រូវបានអនុម័តដោយ គ.ជ.អ.ប ស្ថាប័នអនុវត្តទាំងអស់ដែលរួមមានក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនឹងរៀបចំ ផ.ស.ថ លម្អិតរបស់ខ្លួន និងចុះហត្ថលេខាជាមួយ គ.ជ.អ.ប តាមរយៈសេចក្តីសម្រេចរួម។ តារាង ផ.ស.ថ លម្អិតរបស់ស្ថាប័នអនុវត្តនីមួយៗត្រូវបានរៀបចំក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់ការរៀបចំ ផ.ស.ថ (National Annual Workplan and Budget Database-NAD) ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការតាមដានការអនុវត្ត ការគ្រប់គ្រង និងការរៀបចំរបាយការណ៍។

## តារាងទី៤ ៖ ព័ត៌មានលម្អិតស្តីពីមូលនិធិតាមប្រភព (គិតជាដុល្លារ)

| ប្រភពមូលនិធិ | ការផ្ទេរឱ្យថ្នាក់ក្រោមជាតិ | ១.មូលនិធិកញ្ចប់រួម | ២.កំណត់គោលដៅប្រើប្រាស់ | ៣.បដិភាគពុំមែនថវិកា | ៤. កំណែទម្រង់ (១+២+៣) | % ថវិកាកំណែទម្រង់ | សរុប | % |
|---|---|---|---|---|---|---|---|---|
| **1. ថវិការាជរដ្ឋាភិបាល** [1] | **343,119,000** | **0** | **200,000** | **0** | **200,000** | **0.69%** | **343,319,000** | **90.49%** |
| **2. ថវិកាកម្ចី** | **6,200,000** | **0** | **8,829,464** | **0** | **8,829,464** | **30.49%** | **15,029,464** | **3.96%** |
| 2.1. ADB/DPSFM | 0 | 0 | 7,689,464 | 0 | 7,689,464 | 26.56% | 7,689,464 | 2.03% |
| 2.2. ADB-IFAD/TS-PRSDP | 6,200,000 | 0 | 1,140,000 | 0 | 1,140,000 | 3.94% | 7,340,000 | 1.93% |
| **3. មូលនិធិពីដៃគូអភិវឌ្ឍន៍** | **1,125,360** | **11,249,000** | **3,157,350** | **5,520,246** | **19,926,596** | **68.82%** | **21,051,956** | **5.55%** |
| 3.1. Sweden/SIDA | 0 | 4,425,987 | 0 | 0 | 4,425,987 | 15.29% | 4,425,987 | 1.17% |
| 3.2. EU | 0 | 1,718,073 | 0 | 0 | 1,718,073 | 5.93% | 1,718,073 | 0.45% |
| 3.3. Swiss/SDC [3] | 500,000 | 5,104,940 | 0 | 0 | 5,104,940 | 17.63% | 5,604,940 | 1.48% |
| 3.4. ADB/RWS O&M | 0 | 0 | 125,000 | 0 | 125,000 | 0.43% | 125,000 | 0.03% |
| 3.5. ADB/PPTA [2] | 0 | 0 | 0 | 400,000 | 400,000 | 1.38% | 400,000 | 0.11% |
| 3.6. GiZ EU-SPACE | 0 | 0 | 0 | 350,000 | 350,000 | 1.21% | 350,000 | 0.09% |
| 3.7. GiZ/ ARDP | 0 | 0 | 0 | 650,000 | 650,000 | 2.24% | 650,000 | 0.17% |
| 3.8. GZ RED III | 0 | 0 | 0 | 416,876 | 416,876 | 1.44% | 416,876 | 0.11% |
| 3.9. IFAD/ASPIRE | 400,000 | 0 | 177,000 | 0 | 177,000 | 0.61% | 577,000 | 0.15% |
| 3.10. Supply side social accountability [4] | 0 | 0 | 0 | 3,000,000 | 3,000,000 | 10.36% | 3,000,000 | 0.79% |
| 3.11. UNCDF/LDDPHS | 22,000 | 0 | 30,000 | 0 | 30,000 | 0.10% | 52,000 | 0.01% |
| 3.12. UNCDF/LGCC2 | 0 | 0 | 151,820 | 0 | 151,820 | 0.52% | 151,820 | 0.04% |
| 3.13. UNDP-EU/ACES | 0 | 0 | 1,000,000 | 0 | 1,000,000 | 3.45% | 1,000,000 | 0.26% |
| 3.14. UNFPA | 39,000 | 0 | 111,141 | 0 | 111,141 | 0.38% | 150,141 | 0.04% |
| 3.15. UNICEF/Seth Koma | 70,360 | 0 | 1,342,616 | 703,370 | 2,045,986 | 7.07% | 2,116,346 | 0.56% |
| 3.16. WB-CTPMCH | 94,000 | 0 | 119,773 | 0 | 119,773 | 0.41% | 213,773 | 0.06% |
| 3.17. WB-WSP | 0 | 0 | 100,000 | 0 | 100,000 | 0.35% | 100,000 | 0.03% |
| **4. សរុបរួម (1+2+3)** | **350,444,360** | **11,249,000** | **12,186,814** | **5,520,246** | **28,956,060** | **100.00%** | **379,400,420** | **100.00%** |
| % | **92.37%** | **2.96%** | **3.21%** | **1.45%** | **7.63%** | **0.00%** | **100.00%** | |

សម្គាល់ ៖ [1] ការផ្ទេរថវិការបស់រាជរដ្ឋាភិបាលរួមបញ្ចូលការផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌឱ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនិងឃុំ សង្កាត់ និងការផ្ទេរមានភ្ជាប់លក្ខខណ្ឌ (សូមមើលតារាងទី២)។ [2] ថវិកាសរុបមានចំនួន៨០០.០០០ដុល្លារអាមេរិកសម្រាប់រយៈពេល២ឆ្នាំ។ [3] SDC ផ្តល់មូលនិធិគាំទ្រសម្រាប់កញ្ចប់រួមមានចំនួន៥,១លានដុល្លារអាមេរិកសម្រាប់សកម្មភាពនានានៃកំណែទម្រង់ និងមូលនិធិចំនួន៥០០.០០០ដុល្លារអាមេរិកគាំទ្រមូលនិធិឃុំ សង្កាត់សម្រាប់លើកកម្ពស់សេវាសង្គម។ [4] ជាការប៉ាន់ស្មានសម្រាប់រយៈពេលមួយឆ្នាំនៃថវិកាសរុបសម្រាប់រយៈពេល៣ឆ្នាំរបស់ JSDF ចំនួន៥លានដុល្លារអាមេរិក ថវិកាគាំទ្រដោយ EU ចំនួន២លានអឺរ៉ូ ថវិកាគាំទ្រដោយ USAID ចំនួន១លានដុល្លារអាមេរិក និងថវិកាគាំទ្រដោយ NGOs ចំនួន១លានដុល្លារអាមេរិក។

# II. សមិទ្ធផលរំពឹងទុកនានានៃ ផ.ស.ថ ២០១៦

ផ្នែកទី២នេះ គឺជាផ្នែកមួយដ៏សំខាន់នៃឯកសារ ផ.ស.ថ ឆ្នាំ២០១៦ ដែលបរិយាយអំពីសមិទ្ធផលរំពឹងទុកទាំង៥របស់ផអ៣ទី២ និងលទ្ធផលរំពឹងទុកនានាក្នុងសមិទ្ធផលរំពឹងទុកនីមួយៗដែលត្រូវសម្រេចក្នុងឆ្នាំ២០១៦។ សមិទ្ធផលរំពឹងទុកទាំង៥រួមមាន ៖

**១. ការគ្រប់គ្រងការងារកំណែទម្រង់**

**២. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**

**៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស**

**៤. ការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

**៥. វិមជ្ឈការហិរញ្ញវត្ថុ**

ក្នុងសមិទ្ធផលរំពឹងទុកនីមួយៗមានបរិយាយអំពីសេចក្តីផ្តើមនិងចំណុចដៅ លទ្ធផលរំពឹងទុក និងគម្រោងថវិកា។ ក្នុងលទ្ធផលរំពឹងទុកនីមួយៗមានរៀបរាប់អំពីសកម្មភាពសំខាន់ៗ និងយុទ្ធសាស្ត្រដែលត្រូវអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកទាំងនោះ។

## ១. សមិទ្ធផលរំពឹងទុកទីមួយ ៖ ការគ្រប់គ្រងការងារកំណែទម្រង់

### ១.១. សេចក្តីផ្តើម និងចំណុចដៅ

ភាពជោគជ័យនៃផអ៣ដំណាក់កាលទី២ អាស្រ័យលើប្រសិទ្ធភាពនៃការគ្រប់គ្រងកិច្ចដំណើរការនានានៃកំណែទម្រង់។ សមិទ្ធផលទី១នេះនឹងដោះស្រាយនូវបញ្ហាប្រឈមជាគន្លឹះមួយចំនួន ដែលបានជួបប្រទះក្នុងផអ៣ដំណាក់កាលទី១ដោយចាប់ផ្តើមពី ៖ ១) ការសម្របសម្រួល ដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងទិដ្ឋភាពនយោបាយនៃកំណែទម្រង់ ២) ការពង្រឹងភាពជាម្ចាស់ ៣) ការលើកកម្ពស់ទំនាក់ទំនង និងតម្លាភាព ៤) ការគ្រប់គ្រងការផ្លាស់ប្តូរ និងលទ្ធផលប្រកបដោយប្រសិទ្ធភាព ៥) ការធ្វើឱ្យប្រសើរឡើងនូវការសិក្សារៀនសូត្រ និងការដកស្រង់ពិសោធន៍ និង៦) ការកែលម្អកិច្ចដំណើរការអភិវឌ្ឍន៍គោលនយោបាយ។

សមិទ្ធផលរំពឹងទុកដ៏សំខាន់ពាក់ព័ន្ធនឹងការគ្រប់គ្រងការងារកំណែទម្រង់ ដែលត្រូវសម្រេចឱ្យបាន គឺ**ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យសំដៅឈានឆ្ពោះទៅរកការគ្រប់គ្រងដែលធានាឱ្យមានការផ្លាស់ប្តូរ។**

តារាងទី៥ខាងក្រោមសង្ខេបអំពីសូចនាករ និងចំណុចដៅដែលកំណត់នៅក្នុងផអ៣ទី២។ ស្ថាប័នអនុវត្តទាំងអស់ទទួលខុសត្រូវក្នុងការសម្រេចឱ្យបានចំណុចដៅទាំងនេះ តាមរយៈការកំណត់នូវលទ្ធផលរំពឹងទុក និងសកម្មភាពនានាដែលពាក់ព័ន្ធនឹងសមិទ្ធផលរំពឹងទុកនេះ។ លទ្ធផលរំពឹងទុកនានាដែលត្រូវសម្រេច និងគម្រោងថវិកាមានចែងបន្ទាប់ពីតារាងនេះ។

**តារាងទី៥៖ សូចនាករ និងចំណុចដៅសម្រាប់សមិទ្ធផលរំពឹងទុកទី១**

| សូចនាករ និងចំណុចដៅ | 2016 |
|---|---|
| ១. គ.ជ.អ.ប រៀបចំកិច្ចប្រជុំចំនួន៣ដងក្នុង១ឆ្នាំ | អនុវត្ត |
| ២. ចំនួនថវិកាចំណាយសម្រាប់ជំនួយបច្ចេកទេស (គិតជាលានដុល្លារអាមេរិក) | 5,00 |
| ៣. ចំនួនប្រជាពលរដ្ឋដែលបានទទួលការផ្សព្វផ្សាយព័ត៌មានដើម្បីបង្កើនការយល់ដឹងជាសាធារណៈអំពីកំណែទម្រង់ និងការផ្លាស់ប្តូរឥរិយាបថ (គិតជានាក់ក្នុង១ឆ្នាំ) | 100.000 |
| ៤. ចំនួនភាគរយនៃស្ថាប័នអនុវត្តកម្មវិធីដែលពេញចិត្តចំពោះការរៀបចំផែនការសកម្មភាព និងថវិកា ការអភិវឌ្ឍគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ ដែលសម្របសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប | 60% |
| ៥. ចំនួនក្រសួងដែលបានរៀបចំផ្សព្វផ្សាយព័ត៌មានជាសាធារណៈក្នុងការគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់ | 2 |
| ៦. ចំនួនភាគរយនៃលទ្ធផលរំពឹងទុកជាអាទិភាព និងចំណុចដៅនៃផអ៣ទី២ ដែលបានសម្រេចតាមពេលវេលាដែលបានកំណត់ | 60% |

<u>សម្គាល់</u> ៖ ការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពធៀបនឹងសូចនាករ និងចំណុចដៅទាំងនេះ នឹងឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍ប្រចាំឆ្នាំ។

### ១.២. លទ្ធផលរំពឹងទុក

ផ្អែកតាមផអ៣ទី២ សមិទ្ធផលរំពឹងទុកទី១ស្តីពីការគ្រប់គ្រងការងារកំណែទម្រង់មានលទ្ធផលរំពឹងទុកចំនួន៥ ហើយលទ្ធផលទាំងនេះត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ចំនួន៦ សម្រាប់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៦ ដែលរួមមានដូចខាងក្រោម ៖

**លទ្ធផលរំពឹងទុកទី ១ ៖ ការលើកកម្ពស់ និងការអនុវត្តយន្តការសម្របសម្រួលនានា ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយស្តីពីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។**

គ.ជ.អ.ប មានតួនាទី និងការទទួលខុសត្រូវជាចម្បងលើការដឹកនាំ និងការសម្របសម្រួលលើការរៀបចំ និងការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងកម្មវិធីនានាពាក់ព័ន្ធនឹងកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្នុងឆ្នាំ២០១៥កន្លងមក ដោយមានអនុគណៈកម្មាធិការនានានិងលេខាធិការដ្ឋានជាសេនាធិការ គ.ជ.អ.ប បានដឹកនាំ សម្របសម្រួល និងផ្តល់ការគាំទ្រដល់ស្ថាប័នអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំនួន៤៦ស្ថាប័នក្នុងការរៀបចំ និងអនុវត្តនូវ ផ.ស.ថ ឆ្នាំ២០១៥ របស់ គ.ជ.អ.ប ប្រកបដោយភាពរលូន។ ជារួម បញ្ហាប្រឈមនានាដែលបានជួបប្រទះក្នុងពេលអនុវត្ត ត្រូវបានលើកយកមកពិនិត្យ ពិភាក្សាក្នុងចំណោមស្ថាប័នអនុវត្តពាក់ព័ន្ធនានា និងបានចាត់វិធានការដោះស្រាយបានទាន់ពេលវេលា។ ជាមួយគ្នានេះដែរ ដើម្បីធានាភាពប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នារវាងកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យន្តការសម្របសម្រួលរវាងកំណែទម្រង់សំខាន់ៗទាំង៣ខាងលើក៏ត្រូវបានរៀបចំបង្កើតឡើង និងប្រព្រឹត្តទៅប្រកបដោយភាពរលូនផងដែរ។

ក្នុងឆ្នាំ២០១៦ ផអ៣ទី២នឹងបន្តផ្តោតទៅលើការពង្រឹងនូវប្រសិទ្ធភាពនៃការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ គ.ជ.អ.ប បន្ថែមទៀត ជាពិសេសការពង្រឹងប្រសិទ្ធភាពនៃការដឹកនាំ ការសម្របសម្រួលស្ថាប័នអនុវត្តពាក់ព័ន្ធនានាក្នុងការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងផ្តល់ការគាំទ្រ តាមដាន និងត្រួតពិនិត្យលើការបំពេញការងាររបស់ស្ថាប័នអនុវត្តទាំងនោះផងដែរ។ សកម្មភាពជាអាទិភាពពាក់ព័ន្ធនឹងលទ្ធផលរំពឹងទុកនេះរួមមាន (១) ការជំរុញការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប ឱ្យបានយ៉ាងតិចចំនួន៣លើក ដែលក្នុងនោះក្រៅពីការពិនិត្យពិភាក្សាអំពីគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងត្រួតពិនិត្យលើការបំពេញការងាររបស់ស្ថាប័នអនុវត្ត កិច្ចប្រជុំរបស់ គ.ជ.អ.ប ក៏ត្រូវផ្តោតលើការពិភាក្សាបញ្ហានានាពាក់ព័ន្ធនឹងការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមផងដែរ (២) ការបន្តពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប. ជាពិសេសការជំរុញការរៀបចំកិច្ចប្រជុំរបស់អនុគណៈកម្មាធិការ និងការរៀបចំរបាយការណ៍សម្រាប់រាយការណ៍ជូន គ.ជ.អ.ប ឱ្យបានជាទៀងទាត់ (៣) លេខាធិការដ្ឋាន គ.ជ.អ.ប រៀបចំ និងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ ជូន គ.ជ.អ.ប ជាប្រចាំ និងទាន់ពេលវេលា (៤) ការ

ពិនិត្យឡើងវិញ និងកែសម្រួលយន្តការសម្របសម្រួល និងគាំទ្ររបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធានាដល់ការគាំទ្រ ការរៀបចំរបាយការណ៍ និងធ្វើបច្ចុប្បន្នភាពព័ត៌មានពាក់ព័ន្ធនានាជូន គ.ជ.អ.ប និងអនុគណៈកម្មាធិការនៃ គ.ជ.អ.ប សម្រាប់ជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចនានា និង (៥) ការបន្តជំរុញការអនុវត្តយន្តការសម្របសម្រួលរវាងកម្មវិធីកំណែទម្រង់ទាំង៣ របស់រាជរដ្ឋាភិបាល រួមមានកម្មវិធីកំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

លទ្ធផលរំពឹងទុកនេះនឹងត្រូវដឹកនាំអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប ដោយមានការចូលរួមពីក្រសួង ស្ថាប័ននានាដែលជាសមាជិករបស់ គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកទី ២ ៖ ការពង្រឹងរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី និងសមត្ថភាពរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការអភិវឌ្ឍគោលនយោបាយ និងការគ្រប់គ្រងកម្មវិធី។**

នៅក្នុងឆ្នាំ២០១៥ លេខាធិការដ្ឋាន គ.ជ.អ.ប បានពិនិត្យ និងកែសម្រួលកិច្ចដំណើរការនៃការរៀបចំគោលនយោបាយ និងនីតិវិធីនៃការគ្រប់គ្រងផ្អែកតាមលទ្ធផល ដូចជាការពិនិត្យ និងការកែសម្រួលនីតិវិធីការគ្រប់គ្រងហិរញ្ញវត្ថុ និងកិច្ចដំណើរការនៃការរៀបចំ ផ.ស.ថ ជាដើម។ លទ្ធផលរំពឹងទុកនេះរួមមានសកម្មភាពកំណែទម្រង់ផ្ទៃក្នុងជាច្រើន ដើម្បីអភិវឌ្ឍស្ថាប័ន និងពង្រឹងសមត្ថភាពបុគ្គលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ឱ្យបានប្រសើរឡើង។ កិច្ចការនេះរួមមាន ការពង្រឹងកិច្ចសហការ និងការសម្របសម្រួល តាមរយៈការរៀបចំកិច្ចប្រជុំរវាងអង្គភាពនានាចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប និងកិច្ចប្រជុំរវាងលេខាធិការដ្ឋានជាមួយស្ថាប័នអនុវត្តនានាជាប្រចាំ និងយ៉ាងទៀងទាត់។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងបន្តពិនិត្យ និងកែសម្រួលកិច្ចដំណើរការរៀបចំ ផ.ស.ថ. ក៏ដូចជាប្រព័ន្ធ និងនីតិវិធីសម្រាប់ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាព។ ក្រៅពីនេះ សមត្ថភាពនៃប្រព័ន្ធផ្ទុក និងថែរក្សាទិន្នន័យរបស់លេខាធិការដ្ឋាន គ.ជ.អ.ប នឹងត្រូវបានពង្រឹង ហើយការផ្តល់សេវាព័ត៌មានវិទ្យាក៏នឹងត្រូវបានកែលម្អឱ្យកាន់តែប្រសើរឡើងថែមទៀត។ ក្នុងឆ្នាំ២០១៥កន្លងមក លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ សម្រាប់ការរៀបចំគោលនយោបាយរបស់ផអ៣ក្នុងគោលបំណងពង្រឹងការវិភាគ ការប្រមូល និងការរៀបចំធាតុចូលជាយុទ្ធសាស្ត្រ និងការលើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធនានាឱ្យបានកាន់តែច្រើន។ ជាទូទៅ ការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានានឹងត្រូវអនុវត្តដោយក្រសួង ស្ថាប័នជំនាញ ដោយមានលេខាធិការដ្ឋាន គ.ជ.អ.ប ជាអ្នកផ្តល់ការគាំទ្រ និងពិនិត្យផ្តល់យោបល់ដើម្បីធានាថា គោលនយោបាយ និងលិខិតបទដ្ឋានទាំងនោះមានសង្គតិភាពជាមួយច្បាប់រៀបចំអង្គការ។ គម្រោងនានារបស់ដៃគូអភិវឌ្ឍន៍នឹងចូលរួមចំណែកគាំទ្រក្នុងការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាទាំងនេះ។

សំខាន់ជាងនេះទៀត លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏នឹងបន្តពង្រឹងកិច្ចសហការ និងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា តាមរយៈការរៀបចំកិច្ចប្រជុំឱ្យបានទៀង

ទាត់ជាមួយស្ថាប័នទាំងនោះ ការលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុ ការត្រួតពិនិត្យ ការវាយតម្លៃ និងការរៀបចំរបាយការណ៍។ កិច្ចដំណើរការតាមដាន ត្រួតពិនិត្យសមិទ្ធផលរំពឹងទុកសំខាន់ៗមួយចំនួនដូចជា ការអង្កេតអភិបាលកិច្ច និងការសិក្សាវាយតម្លៃអំពីសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវកែសម្រួល និងធ្វើលទ្ធកម្មសម្រាប់ការអនុវត្តនៅឆ្នាំ២០១៧[5]។ គម្រោង កម្មវិធីនានាដែលស្ថិតក្រោមការគ្រប់គ្រងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប នឹងត្រូវធ្វើការសម្របសម្រួល ដើម្បីធានាឱ្យមានភាពប្រទាក់ក្រឡាគ្នាជាមួយផអ៣ទី២ ផ.ស.ថ និងទីប្រឹក្សាបច្ចេកទេសដែលបានចាត់តាំងឱ្យគាំទ្រស្ថាប័នអនុវត្តនានានៅថ្នាក់ ជាតិ និងថ្នាក់ក្រោមជាតិ។ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តនានានឹងត្រូវបាន រៀបចំដោយមានការវិភាជមូលនិធិ សម្រាប់ការគាំទ្រសកម្មភាព និងចំណាយប្រតិបត្តិការពាក់ព័ន្ធនឹងកម្មវិធី។ ដូចគ្នានេះដែរ ក្នុងឆ្នាំ២០១៦ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងសម្របសម្រួលការពិនិត្យមើលឡើងវិញពាក់កណ្តាលកម្មវិធីនៃកម្មវិធីជាតិ និងការរៀបចំសេចក្តីព្រាងផអ៣ទី៣[6]។

លទ្ធផលរំពឹងទុកនេះនឹងដឹកនាំអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកទី ៣ ៖ ការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ដោយរួមបញ្ចូលទាំងការប្រឹក្សាយោបល់ និងការផ្លាស់ប្តូរព័ត៌មានជាប្រចាំ និងបើកចំហនៅក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។**

ក្នុងអំឡុងឆ្នាំ២០១៥ យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងរបស់ គ.ជ.អ.ប. ត្រូវបានរៀបចំជាសេចក្តីព្រាង។ យុទ្ធសាស្ត្រនេះរួមមានសមាសភាគចំនួន៥ និងលទ្ធផលរំពឹងទុកចំនួន១៣ដែលគ្រោងដាក់ឱ្យអនុវត្តពីឆ្នាំ២០១៦ដល់ឆ្នាំ២០១៨។ ដូច្នេះ សកម្មភាពសំខាន់ៗដែលលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវអនុវត្តក្នុងឆ្នាំ២០១៦រួមមានដូចខាងក្រោម ៖

- រៀបចំផ្ទាំងព័ត៌មាន និងខិតប័ណ្ណដែលជាឧបករណ៍នៃការប្រាស្រ័យទាក់ទងជាមូលដ្ឋានដែលផ្ទាំងនីមួយៗមានសញ្ញាសម្គាល់ដោយឡែក
- រៀបចំសេចក្តីណែនាំ សម្រាប់ការបញ្ជ្រាបយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងទៅក្នុងគ្រប់វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការរៀបចំកិច្ចដំណើរការកសាងផែនការ
- បង្កើតនូវសំណុំព័ត៌មាន រូបថត និងក្រាភិចដែលមានគុណភាពខ្ពស់
- ធ្វើបច្ចុប្បន្នភាពនិងធ្វើឱ្យប្រសើរឡើងនូវគេហទំព័ររបស់ គ.ជ.អ.ប ដើម្បីផ្តល់ភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់នានា
- ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធរបស់ការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប ដោយរួមបញ្ចូលការទទួលខុសត្រូវផ្នែកបណ្ណាល័យ និងពង្រឹងសមត្ថភាពបុគ្គលិក ដើម្បីទទួលបាននូវជំនាញដែលត្រូវការ

[5] កិច្ចការទាំងនេះត្រូវបានសម្រេចអនុវត្តនៅចុងបញ្ចប់នៃផអ៣ទី២ គឺនៅឆ្នាំ២០១៧ ពោលគឺត្រូវអនុវត្តនៅពេលបញ្ចប់ផអ៣នីមួយៗ។

[6] ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកម្មវិធីជាតិនឹងផ្តល់ថវិកាគាំទ្រ និងធ្វើលទ្ធកម្មដោយសហភាពអឺរ៉ុប។

- រៀបចំ និងអនុវត្តកម្មវិធីផ្សព្វផ្សាយ (សម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយសារព័ត៌មាន វិទ្យុ និងទូរទស្សន៍ជាដើម)
- រៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមបណ្ដាញសង្គមដែលបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីលើកកម្ពស់ការចូលរួមរបស់សាធារណជន
- លើកកម្ពស់ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវការយល់ដឹងស៊ីជម្រៅអំពីការងារកំណែទម្រង់
- រៀបចំ និងអនុវត្តវិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធនៃការចូលរួមរបស់ក្រសួង ស្ថាប័នជំនាញ ដើម្បីធានាឱ្យមានការយល់ដឹងស៊ីជម្រៅអំពីការងារកំណែទម្រង់
- អនុវត្តយុទ្ធនាការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ដោយគូសបញ្ជាក់អំពីសារសំខាន់នៃការផ្ទេរមុខងារនានា ដូចជាការអប់រំកម្រិតបឋមសិក្សា ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ល។
- រៀបចំសិក្ខាសាលានានាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីស្ដាប់មតិយោបល់ សិក្សារៀនសូត្រ និងដកស្រង់បទពិសោធន៍សម្រាប់កែលម្អការអនុវត្តកម្មវិធី។

**លទ្ធផលរំពឹងទុកទី ៤ ៖ ការប្រឹក្សាយោបល់ជាប្រចាំអំពីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរវាងលេខាធិការដ្ឋាន គ.ជ.អ.ប ជាមួយក្រសួង ស្ថាប័នអនុវត្តនានា។**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងលទ្ធផលរំពឹងទុកនេះ គឺការពង្រឹងសមត្ថភាព និងកិច្ចដំណើរការរបស់ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន ដោយដាក់បញ្ចូលផែនការសកម្មភាព និងថវិការបស់ក្រុមការងារនេះទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នសាមី (តាមរយៈការរៀបចំក្រុមការងារនេះឱ្យក្លាយជាអង្គភាពផ្លូវការ ឬប្រើប្រាស់រចនាសម្ព័ន្ធ ដែលមានស្រាប់របស់ក្រសួង ស្ថាប័នទាំងនោះ) និងការលើកកម្ពស់ការរៀបចំកិច្ចប្រជុំពិភាក្សារវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយក្រសួង ស្ថាប័ននានា ដើម្បីធានា និងលើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយ និងគោលដៅនានាពាក់ព័ន្ធនឹងការងារកំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងកិច្ចដំណើរការនៃការផ្ទេរមុខងារ ការគ្រប់គ្រងធនធានមនុស្ស និងការគ្រប់គ្រងហិរញ្ញវត្ថុ។ ក្រសួង ស្ថាប័ននឹងប្រើប្រាស់ថវិការបស់ខ្លួនជាបណ្ដើរៗ ដើម្បីគាំទ្រការអនុវត្តសកម្មភាពនានាពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដូចជា ការអនុវត្តកិច្ចដំណើរការនៃការផ្ទេរមុខងារជាដើម[7]។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប រួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា នឹងរៀបចំបង្កើតឱ្យមានក្រុមការងារជាក់លាក់តាមកិច្ចការ ឬ វិស័យនីមួយៗ ដើម្បីគាំទ្រ និងតាមដានរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងកិច្ចដំណើរការផ្ទេរមុខងារ ការគ្រប់ គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ និងកិច្ចការពាក់ព័ន្ធផ្សេងទៀត។

[7] យើងបានប៉ាន់ស្មានធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌ ប៉ុន្តែធនធាននេះមិនបានរាប់បញ្ចូលនូវថវិកាសម្រាប់ក្រសួងរៀបចំវគ្គបណ្តុះបណ្តាល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃនោះទេ។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

**លទ្ធផលរំពឹងទុកទី ៥ ៖ ការពិនិត្យឡើងវិញ និងការពង្រឹងរចនាសម្ព័ន្ធ ការទទួលខុសត្រូវ និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារនានាដែលបានផ្ទេរ។**

ឆ្នាំ២០១៦ គឺជាឆ្នាំដ៏មានសំខាន់មួយដើម្បីឈានឆ្ពោះទៅការកែទម្រង់កាន់តែស៊ីជំរៅថែមទៀត ជាពិសេស គឺការផ្ទេរមុខងារជាក់លាក់ពីក្រសួង ស្ថាប័នមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតំបន់គោលដៅដែលបានកំណត់ (លទ្ធផលរំពឹងទុកទី៣ និងលទ្ធផលរំពឹងទុកទី៩នៃសមិទ្ធផលរំពឹងទុកទី៤)។ ដូច្នេះ ក្រសួង ស្ថាប័នទាំងនោះនឹងមានកិច្ចការសំខាន់ៗជាច្រើនដែលត្រូវរៀបចំ និងអនុវត្តមានដូចជា ការរៀបចំគោលនយោបាយ ការរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ការកំណត់ស្តង់ដារសេវា ការអភិវឌ្ឍសមត្ថភាព និងកិច្ចការចាំបាច់ផ្សេងៗទៀត ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តមុខងារដែលបានផ្ទេរឱ្យប្រកបដោយប្រសិទ្ធភាព។ ដើម្បីអនុវត្តកិច្ចការនេះ ទាមទារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ តួនាទីភារកិច្ច និងសមត្ថភាពនានារបស់ខ្លួន។ អាស្រ័យហេតុនេះ រចនាសម្ព័ន្ធ និងទំនាក់ទំនងក្នុងការរាយការណ៍នឹងមានការផ្លាស់ប្តូរ ហើយល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិកក៏ត្រូវពិនិត្យ និងកែសម្រួលដោយបានសមស្រប ក៏ដូចជាការកំណត់អំពីតម្រូវការនៃវគ្គការបណ្តុះបណ្តាល និងការប្រឹក្សាយោបល់នានា[8]។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**លទ្ធផលរំពឹងទុកទី ៦ ៖ ការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាននៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រនិងផ្តល់សេវាដល់សមាជិករបស់ខ្លួន។**

កិច្ចការជាអាទិភាពក្នុងឆ្នាំ២០១៦ គឺការពង្រឹងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋាននៃសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសគឺការជ្រើសរើសបុគ្គលិក ដើម្បីបំពេញមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន និងការអភិវឌ្ឍសមត្ថភាពបុគ្គលិក។ ជាមួយគ្នានេះដែរ ផអ៣ទី២ គម្រោង UNDP-EU/ACES និងគម្រោងពាក់ព័ន្ធផ្សេងទៀតនឹងបន្តគាំទ្រការអភិវឌ្ឍសមត្ថភាពផ្នែកស្ថាប័នដល់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

លទ្ធផលរំពឹងទុកនេះ នឹងអនុវត្តដោយអគ្គលេខាធិការដ្ឋាននៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

### ១.៣. គម្រោងថវិកា

ថវិកាសរុបសម្រាប់សមិទ្ធផលរំពឹងទុកនេះក្នុងឆ្នាំ២០១៦ មានចំនួន៥,៤លានដុល្លារអាមេរិក ដូចមានលម្អិតនៅក្នុងតារាងខាងក្រោម។

[8] កិច្ចការនេះមានរៀបរាប់បន្ថែមក្នុងសមិទ្ធផលរំពឹងទុកទី៤ ដែលបានកំណត់ជាសកម្មភាព និងថវិកាពាក់ព័ន្ធ។

## តារាងទី៦៖ គម្រោងថវិកា និងប្រភពមូលនិធិរបស់សមិទ្ធផលរំពឹងទុកទី១ (គិតជាដុល្លារ)

| លទ្ធផលរំពឹងទុក | | កញ្ចប់រួម | ផ្សេងៗ | សរុប | សម្គាល់ |
|---|---|---|---|---|---|
| ១. | ការលើកកម្ពស់ និងការអនុវត្តយន្តការសម្របសម្រួលនានា ដើម្បីធានាដល់ប្រសិទ្ធភាពនៃការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយស្តីពីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | 33,200 | 0 | 33,200 | |
| ២. | ការពង្រឹងរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី និងសមត្ថភាពលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការអភិវឌ្ឍគោលនយោបាយ និងគ្រប់គ្រងកម្មវិធី | 2,981,018 | 1,200,000 | 4,181,018 | (1) |
| ៣. | ការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងដោយរួមបញ្ចូលទាំងការប្រឹក្សាយោបល់ និងការផ្លាស់ប្តូរព័ត៌មានជាប្រចាំ និងបើកចំហនៅក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | 113,900 | 0 | 113,900 | |
| ៤. | ការប្រឹក្សាយោបល់ជាប្រចាំអំពីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរវាងលេខាធិការដ្ឋាន គ.ប.អ.ជ. ជាមួយក្រសួងស្ថាប័នអនុវត្តនានា | 18,200 | 0 | 18,200 | |
| ៥. | ការពិនិត្យឡើងវិញ និងការពង្រឹងរចនាសម្ព័ន្ធការទទួលខុសត្រូវ និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តមុខងារនានាដែលបានផ្ទេរ | 0 | 0 | 0 | |
| ៦. | ការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាននៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រ និងផ្តល់សេវាដល់សមាជិករបស់ខ្លួន | 72,400 | 1,000,000 | 1,072,400 | (2) |
| **សរុប** | | **3,218,718** | **2,200,000** | **5,418,718** | |

<u>សម្គាល់</u> ៖ (1) រួមបញ្ចូលចំណាយសម្រាប់ជំនួយបច្ចេកទេស និងចំណាយប្រតិបត្តិការនៅថ្នាក់ជាតិដែលគ្រប់គ្រងដោយលេខាធិការដ្ឋាន គ.ជ.អ.ប.។ ថវិកាចំនួន២០០.០០០ដុល្លារផ្តល់ដោយរាជរដ្ឋាភិបាលសម្រាប់ការគាំទ្រ និងការសម្របសម្រួល ការអនុវត្ត ការគ្រប់គ្រង ការតាមដាន និងការរៀបចំរបាយការណ៍ ផ.ស.ថ. ២០១៦ ដោយលេខាធិការដ្ឋាន គ.ជ.អ.ប។ គម្រោង EU SPACE និង GiZ/ ARDP នឹងចូលរួមបដិភាគមិនមែនជាថវិកាសម្រាប់ការរៀបចំគោលនយោបាយមានចំនួនប្រមាណ១លានដុល្លារ។ (2) ថវិកាគាំទ្រដោយគម្រោង UNDP-EU/ACES មានចំនួនប្រមាណ១លានដុល្លារ។

## ២. សមិទ្ធផលរំពឹងទុកទីពីរ ៖ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

### ២.១. សេចក្តីផ្តើម និងចំណុចដៅ

ការអភិវឌ្ឍស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យក្លាយទៅជាស្ថាប័នតំណាងពិតប្រាកដរបស់ប្រជាពលរដ្ឋ និងឆ្លើយតបចំពោះសេចក្តីត្រូវការនានារបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព គឺជាគោលបំណងចម្បងមួយនៃ ផអ៣ទី២។ នៅក្នុងសមិទ្ធផលនេះ ទំនាក់ទំនងគណនេយ្យភាពរវាងគណៈអភិបាលជាមួយក្រុមប្រឹក្សាត្រូវបានកំណត់កាន់តែច្បាស់ គណនេយ្យភាពសង្គមនិងសកម្មភាពចូលរួមរបស់ប្រជាពលរដ្ឋនឹងត្រូវបានអនុវត្ត ការធ្វើអធិការកិច្ចលើការអនុវត្ត និងការធ្វើនីត្យានុកូលភាពលើលិខិតបទដ្ឋាននានានឹងត្រូវបានពង្រឹង ហើយប្រព័ន្ធប្រតិបត្តិការនានាដូចជា ប្រព័ន្ធគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យានឹងត្រូវបានដាក់ឱ្យអនុវត្តដើម្បីសម្របសម្រួលក្នុងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

សមិទ្ធផលរំពឹងទុកដ៏សំខាន់ពាក់ព័ន្ធនឹងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ដែលត្រូវសម្រេចឱ្យបានគឺ **រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារជាស្ថាប័នប្រជាធិបតេយ្យនៅមូលដ្ឋានដែលមានស្វ័យភាព និងមានគណនេយ្យភាព ដោយគណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគោរពតាមក្របខ័ណ្ឌច្បាប់ និងស្តង់ដារនានារបស់ជាតិ។**

តារាងទី៧ខាងក្រោមសង្ខេបអំពីសូចនាករ និងចំណុចដៅដែលកំណត់នៅក្នុងផអ៣ទី២។ ស្ថាប័នអនុវត្តទាំងអស់ទទួលខុសត្រូវក្នុងការសម្រេចឱ្យបានចំណុចដៅទាំងនេះ តាមរយៈការកំណត់នូវលទ្ធផលរំពឹងទុក និងសកម្មភាពនានាដែលពាក់ព័ន្ធនឹងសមិទ្ធផលរំពឹងទុកនេះ។ លទ្ធផលរំពឹងទុកនានាដែលត្រូវសម្រេច និងគម្រោងថវិកាមានចែងបន្ទាប់ពីតារាងនេះ។

**តារាងទី៧៖ សូចនាករ និងចំណុចដៅសម្រាប់សមិទ្ធផលរំពឹងទុកទី២**

| សូចនាករ និងចំណុចដៅ | 2016 |
|---|---|
| ១. ក្របខ័ណ្ឌគតិយុត្តត្រូវបានពង្រឹងដើម្បីធានាឱ្យក្រុមប្រឹក្សាមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព ពិសេសមានសិទ្ធិអំណាចក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធាន និងមានសិទ្ធិអំណាចក្នុងការត្រួតពិនិត្យទៅលើការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន | អនុវត្ត |
| ២. ចំនួនក្រុង ស្រុកបានអនុម័ត និងអនុវត្តវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួន | 185 |
| ៣. ៨០%នៃក្រុមប្រឹក្សាក្រុង ស្រុកយល់ឃើញថាសិទ្ធិអំណាចរបស់ខ្លួនជាមួយគណៈអភិបាលមានភាពរឹងមាំជាងពីមុន | 50% |
| ៤. ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុកប្រើប្រាស់ព័ត៌មាន ទទួលបានតាមរយៈប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ ប្រព័ន្ធគ្រប់គ្រងតាមព័ត៌មានវិទ្យា | 300 |
| ៥. ចំនួនស្រុកដែលគ្រប់ឃុំទាំងអស់បានបិទបង្ហាញព័ត៌មានដល់សាធារណជន (ស្របតាមការ | 70 |

| សូចនាករ និងចំណុចដៅ | 2016 |
|---|---|
| ណែនាំស្តីពីការបើកចំហរព័ត៌មាន) បានចូលរួមការតាមដានត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងបានរៀបចំផែនការសកម្មភាពគណនេយ្យភាពរួមគ្នា ដើម្បីកែលម្អការផ្តល់សេវា | |
| ៦. កម្មវិធីគណនេយ្យភាពសង្គមដំណាក់កាលទី២ ត្រូវបានរៀបចំដើម្បីបញ្ចូលនូវសេវាផ្សេងៗទៀត និងអនុវត្តនៅថ្នាក់រដ្ឋបាលដទៃទៀត។ | ពុំមាន |
| ៧. ចំនួនបណ្តឹងតវ៉ាដែលប្រមូលបាន និងដោះស្រាយដោយរដ្ឋបាល ឃុំ សង្កាត់ | 1,000 |
| ៨. ចំនួនបណ្តឹងតវ៉ាដែលប្រមូលបាន និងដោះស្រាយដោយរដ្ឋបាល ក្រុង ស្រុក ខណ្ឌ | 500 |
| ៩. ចំនួនប្រជាពលរដ្ឋចូលរួមក្នុងវេទិកាថ្នាក់ស្រុក | 7,000 |
| ១០. ចំនួនអង្គការសង្គមស៊ីវិលចូលរួមក្នុងវេទិកាថ្នាក់ស្រុក | 700 |
| ១១. ការចូលរួមបដិភាគជាថវិការបស់ឃុំទៅក្នុងផែនការសកម្មភាពគណនេយ្យភាពរួមគ្នា(គិតជាលានដុល្លា) | 0.25 |
| ១២. ការវាយតម្លៃពីផលប៉ះពាល់ត្រូវបានបញ្ចប់ដោយប្រៀបធៀបក្រុមប្រជាពលរដ្ឋទទួលផល និងក្រុមប្រជាពលរដ្ឋផ្សេងទៀត ព្រមទាំងបង្ហាញពីការកែលម្អនូវសូចនាករនៃផ្ទាំងព័ត៌មាន | ពុំមាន |
| ១៣. ចំនួនភាគរយនៃរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌដែលត្រូវបានធ្វើអធិការកិច្ចលើការអនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងបានទទួលនូវការពេញចិត្តតាមរយៈការវាយតម្លៃ | 30% |

សម្គាល់ ៖ ការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពធៀបនឹងសូចនាករ និងចំណុចដៅទាំងនេះនឹងឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍ប្រចាំឆ្នាំ។

### ២.២. លទ្ធផលរំពឹងទុក

ផ្អែកតាមផអ៣ទី២ សមិទ្ធផលរំពឹងទុកទី២ស្តីពីគណនេយ្យភាពតាមបែបប្រជាធិបតេយ្យមានលទ្ធផលរំពឹងទុកចំនួន៥ ហើយលទ្ធផលទាំងនេះត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ចំនួន៥ សម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ដែលរួមមានដូចខាងក្រោម ៖

**លទ្ធផលរំពឹងទុកទី ១ ៖ ការពិនិត្យ និងកែសម្រួលប្រព័ន្ធ និងនីតិវិធីនានានៃអភិបាលកិច្ចមូលដ្ឋាន ដើម្បីលើកកម្ពស់ខ្សែគណនេយ្យភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។**

នៅក្នុងឆ្នាំ២០១៥ វិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំ ដោយរដ្ឋបាលក្រុង ស្រុកនានា ហើយនីតិវិធី និងបែបផែននានាសម្រាប់កិច្ចប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការរៀបចំដីកា ការអនុវត្តមុខងារជាជម្រើស ទំនាក់ទំនងផ្ទៃក្នុង និងទំនាក់ទំនងអន្តររដ្ឋបាល និងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ត្រូវបានរៀបចំស្ទើររួចរាល់អស់ហើយ។ ឯកសារទាំងនេះនឹងត្រូវរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០១៦នៅថ្នាក់ក្រុង ស្រុក អាស្រ័យហេតុនេះ ចាប់ពីឆ្នាំ២០១៦ នឹងមានប្រព័ន្ធនិងនីតិវិធីជាច្រើនស្តីពីអភិបាលកិច្ចត្រូវបានដាក់ឱ្យអនុវត្តនៅថ្នាក់ក្រុង ស្រុក។ នៅចុងឆ្នាំ២០១៦ នឹងមានការរៀបចំការសិក្សាវាយតម្លៃមួយអំពីគុណភាព និងប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ

និងនីតិវិធីទាំងនោះ[9]។ លទ្ធផលនៃការសិក្សាវាយតម្លៃនេះនឹងយកមកប្រើប្រាស់សម្រាប់ការពិនិត្យ និង កែលម្អលិខិតបទដ្ឋាននានា និងពង្រឹងការអនុវត្តជាក់ស្តែងឱ្យបានកាន់តែល្អប្រសើរ។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងមហាផ្ទៃ។

**លទ្ធផលរំពឹងទុកទី២ ៖ ការអនុវត្តនូវសកម្មភាពគណនេយ្យភាពសង្គម និងការរៀបចំផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមរបស់ឃុំគោលដៅចំនួន៣០០ ក្នុងស្រុកគោលដៅយ៉ាងតិចចំនួន៥១ ដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាននានា។**

សៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ និងផែនការសកម្មភាពស្តីពីការងារគណនេយ្យភាពសង្គមមានរៀបរាប់អំពីសកម្មភាពសំខាន់ៗក្នុងលទ្ធផលរំពឹងទុកនេះ ដែលរួមមានដូចខាងក្រោម ៖

| **សកម្មភាព** | **ស្ថាប័នអនុវត្ត** |
|---|---|
| – ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីគណនេយ្យភាពសង្គម (កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម) | អង្គការសង្គមស៊ីវិល |
| – ជ្រើសរើស និងបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍អំពីគណនេយ្យភាពសង្គម | អង្គការសង្គមស៊ីវិល |
| – ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានាផ្នែកផ្គត់ផ្គង់នៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុកស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| – បង្កើតប្រព័ន្ធទិន្នន័យសម្រាប់ការត្រួតពិនិត្យ តាមដានការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម (ដើម្បីផលិតជាផ្ទាំងព័ត៌មាន សម្រាប់បិតលើកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ការតាមដានការអនុវត្តគណនេយ្យភាពសង្គមរបស់ផ្នែកផ្គត់ផ្គង់ការដាក់បញ្ចូលផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធទិន្នន័យ និងការតាមដានការបិតផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ) | លេខាធិការដ្ឋាន គ.ជ.អ.ប. ដោយ មានការគាំទ្រពី UNICEF |
| – បណ្តុះបណ្តាលមន្ត្រីមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តស្តីពីការងារគណនេយ្យភាពសង្គម និងបណ្តុះបណ្តាលមន្ត្រីបង្គោលថ្នាក់ស្រុកអំពីប្រព័ន្ធទិន្នន័យសម្រាប់ការត្រួតពិនិត្យ តាមដានការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| – បណ្តុះបណ្តាលមន្ត្រីទាំងបីវិស័យ (រដ្ឋបាលឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាព) ថ្នាក់ឃុំ និងថ្នាក់ស្រុកស្តីពីគណនេយ្យភាពសង្គម និងព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងបែងចែកក្រដាសផ្ទាំងព័ត៌មាន និងទម្រង់បំពេញព័ត៌មាន | មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស រាជធានី ខេត្ត |
| – អនុវត្តប័ណ្ណដាក់ពិន្ទុដោយប្រជាពលរដ្ឋ និងការតាមដានរបស់ប្រជាពលរដ្ឋ | អង្គការសង្គមស៊ីវិល |
| – រៀបចំកិច្ចប្រជុំរួមគ្នារវាងអ្នកផ្តល់សេវា និងអ្នកទទួលសេវា និងសម្របសម្រួលការរៀបចំផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម ដើម្បីកែលម្អសេវា | អង្គការសង្គមស៊ីវិល |
| – គាំទ្រ និងត្រួតពិនិត្យការអនុវត្តផ្នែកផ្គត់ផ្គង់ទាំងបីវិស័យ (រដ្ឋបាលឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាព) នៅថ្នាក់ឃុំ និងរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងនៅថ្នាក់ស្រុក | រដ្ឋបាលស្រុកគោលដៅ |

[9] ការពិនិត្យមើលឡើងនឹងផ្តោតការយកចិត្តទុកដាក់លើ ការរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា កិច្ចដំណើរការនៃការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការធ្វើសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា រចនាសម្ព័ន្ធ ការអនុវត្តតួនាទី និងការបែងចែកការទទួលខុសត្រូវរវាងគណៈអភិបាល និងក្រុមប្រឹក្សា (ពាក់ព័ន្ធនឹងការត្រួតពិនិត្យមើលពីលើ ភាពជាតំណាង និងការរៀបចំគោលនយោបាយ) ក៏ដូចជាទំនាក់ទំនងជាមួយប្រជាពលរដ្ឋ (ការរៀបចំវេទិកា ការផ្តល់ព័ត៌មាន។ល។)

| **សកម្មភាព** | **ស្ថាប័នអនុវត្ត** |
|---|---|
| – សកម្មភាពនានានៃការត្រួតពិនិត្យ និងការវាយតម្លៃដោយថ្នាក់ជាតិ (រួមបញ្ចូលទាំងការវាយតម្លៃការអនុវត្តផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម ដែលឆ្លុះបញ្ចាំងពីព័ត៌មានដែលបានបិតផ្សាយជូនប្រជាពលរដ្ឋ) | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| – ប្រមូលទិន្នន័យដើមគ្រា ដើម្បីវាយតម្លៃអំពីផលប៉ះពាល់នៃការអនុវត្តការងារគណនេយ្យភាពសង្គម | លេខាធិការដ្ឋាន និង WB |
| – រៀបចំ ការសិក្សារៀនសូត្រ និងការផ្តល់យោបល់ត្រឡប់អំពីការអនុវត្តការងារគណនេយ្យភាពសង្គម | លេខាធិការដ្ឋាន គ.ជ.អ.ប. និងអង្គការសង្គមស៊ីវិល |

<u>សម្គាល់</u> ៖ តារាងសកម្មភាពនេះគឺជាការផ្តួចផ្តើមដោយផ្នែកផ្គត់ផ្គង់។ សកម្មភាពផ្នែកតម្រូវការភាគច្រើននឹងអនុវត្តដោយអង្គការសង្គមស៊ីវិល។ សកម្មភាពនៃការសិក្សាវាយតម្លៃ ការសិក្សារៀនសូត្រ និងការប្រាស្រ័យទាក់ទងកំពុងពិភាក្សា និងរៀបចំ។

**លទ្ធផលរំពឹងទុកទី ៣ ៖ ការពិនិត្យ ការកែសម្រួល និងការអនុវត្តនូវយន្តការដោះស្រាយបណ្តឹងមានលក្ខណៈជាប្រព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់នូវយន្តការនេះ។**

ក្នុងឆ្នាំ២០១៥ ក្រសួងមហាផ្ទៃបានធ្វើការសិក្សាវាយតម្លៃនូវប្រព័ន្ធ យន្តការ និងនីតិវិធីនានាដែលមានស្រាប់ពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹង។ លទ្ធផលនៃការសិក្សាវាយតម្លៃនេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការពិនិត្យ កែសម្រួល និងរៀបចំប្រព័ន្ធថ្មីមួយ ក៏ដូចជាសេចក្តីណែនាំ និងឧបករណ៍នានាដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនានា។ ដើម្បីធានាដល់ការអនុវត្តនៅទូទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រព័ន្ធនេះនឹងត្រូវធ្វើការសាកល្បងមុននឹងត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់អ្នកពាក់ព័ន្ធនានា តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។

ប្រព័ន្ធថ្មីដែលត្រូវបានរៀបចំនឹងផ្តល់នូវមធ្យោបាយជាច្រើន និងបង្កលក្ខណៈងាយស្រួលក្នុងកិច្ចដំណើរការទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានកំណត់ក្នុងតារាងទី៧ខាងលើអំពីសូចនាករ និងចំណុចដៅដែលត្រូវសម្រេច។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**លទ្ធផលរំពឹងទុកទី ៤ ៖ ការរៀបចំតាក់តែង និងដាក់ឱ្យអនុវត្តសាកល្បងនូវយន្តការអធិការកិច្ចទៅលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យយន្តការនេះអាចអនុវត្តបានយ៉ាងពេញលេញនៅឆ្នាំ២០១៧។**

នៅក្នុងឆ្នាំ២០១៥ សេចក្តីព្រាងចុងក្រោយនៃគោលនយោបាយ និងសៀវភៅណែនាំស្តីពីយន្តការអធិការកិច្ចត្រូវបានរៀបចំបញ្ចប់ដែលរួមបញ្ចូលនូវខ្លឹមសារសំខាន់ៗដូចជា កិច្ចដំណើរការ បញ្ជីសំណួរ ប្រព័ន្ធសម្រាប់ដាក់ពិន្ទុ និងសូចនាករនានា។ សេចក្តីព្រាងនៃសៀវភៅណែនាំនេះ ត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំកិច្ចដំណើរការនៃការសិក្សា វាយតម្លៃលើល័ក្ខខ័ណ្ឌអប្បបរមារបស់មូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅពេលដែលសៀវភៅណែនាំស្តីពីអធិការកិច្ចត្រូវបានរៀបចំ

បញ្ចប់ សៀវភៅនេះនឹងត្រូវបានប្រើប្រាស់សម្រាប់ការធ្វើអធិការកិច្ចលើអភិបាលកិច្ច ធនធានមនុស្ស ការងារហិរញ្ញវត្ថុនិងកិច្ចលទ្ធកម្ម និងការងាររដ្ឋបាល ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា។ លទ្ធផលនៃការធ្វើអធិការកិច្ចនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ និងពិភាក្សានៅក្នុងកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា។

ការបន្តពិភាក្សា និងរៀបចំបញ្ចប់នូវឧបករណ៍ និងការរៀបចំបែបផែននានាផ្នែកស្ថាប័ន និងការបណ្តុះបណ្តាលនឹងត្រូវអនុវត្តក្នុងឆ្នាំ២០១៦ ដើម្បីធានាការចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ២០១៧។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងមហាផ្ទៃ។

**លទ្ធផលរំពឹងទុកទី ៥ ៖ ការរៀបចំតាក់តែង និងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុងរបស់ក្រុង ស្រុក ខណ្ឌ តាមរយៈប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងរបស់ក្រុង ស្រុក សម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់ក៏ដូចជាដើម្បីប្រមូល និងផ្តល់នូវធាតុចូលនានាសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។**

ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុងក្រុង ស្រុក ខណ្ឌបានចាប់ផ្តើមរៀបចំតាំងពីឆ្នាំ២០១៥។ ក្នុងឆ្នាំ២០១៦ ប្រព័ន្ធនេះនឹងត្រូវរៀបចំបញ្ចប់ ដោយសហការជាមួយក្រុង ស្រុក ខណ្ឌនានា ដើម្បីធានាការឆ្លើយតបនឹងតម្រូវការរបស់រដ្ឋបាលទាំងនោះ។ ជាមួយគ្នានេះដែរ ប្រព័ន្ធនេះនឹងត្រូវរៀបចំជាប្រព័ន្ធមួយដែលមានភាពបត់បែន និងផ្តល់សិទ្ធិដល់ក្រុង ស្រុក ខណ្ឌក្នុងការប្រមូលទិន្នន័យ ការកំណត់សូចនាករ និងទិន្នន័យនានាដែលអាចផលិតបាននូវព័ត៌មានតាមតម្រូវការ ទាន់ពេលវេលា និងងាយយល់សម្រាប់ក្រុមប្រឹក្សាប្រើប្រាស់ក្នុងកិច្ចប្រជុំនានា និងជួយដល់សាធារណជន និងអង្គការសង្គមស៊ីវិលនានាក្នុងការទទួលបាន និងការប្រើប្រាស់នូវព័ត៌មានទាំងនេះកាន់តែទូលំទូលាយ។

ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុងក្រុង ស្រុក ខណ្ឌនឹងរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងប្រើប្រាស់ដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

### ២.៣. គម្រោងថវិកា

ចំណាយសរុបនៃសមិទ្ធផលរំពឹងទុកនេះ ក្នុងឆ្នាំ២០១៦មានចំនួនប្រមាណ៣,៦លានដុល្លារ ដូចមានបរិយាយលម្អិតដូចខាងក្រោម ៖

**តារាងទី៨៖ គម្រោងថវិកា និងប្រភពមូលនិធិសម្រាប់សមិទ្ធផលរំពឹងទុកទី២ (គិតជាដុល្លារ)**

| | លទ្ធផលរំពឹងទុក | កញ្ចប់រួម | ផ្សេងៗ | សរុប | សំគាល់ |
|---|---|---|---|---|---|
| ១. | ប្រព័ន្ធ និងនីតិវិធីអភិបាលកិច្ចត្រូវបានពិនិត្យមើល និងកែសម្រួលឡើងវិញដើម្បីធ្វើឱ្យកាន់តែប្រសើរនូវខ្សែគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 28,400 | 0 | 28,400 | |
| ២. | ការអនុវត្តនូវសកម្មភាពគណនេយ្យភាពសង្គម និងការរៀបចំផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមរបស់ឃុំគោលដៅចំនួន៣០០ក្នុង | 344,652 | 3,000,000 | 3,344,652 | (1) |

| លទ្ធផលរំពឹងទុក | | កញ្ចប់រួម | ផ្សេងៗ | សរុប | សំគាល់ |
|---|---|---|---|---|---|
| | ស្រុកគោលដៅយ៉ាងតិចចំនួន៥១ដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិលនិងសហគមន៍មូលដ្ឋាននានា | | | | |
| ៣. | ការពិនិត្យ ការកែសម្រួល និងការអនុវត្តនូវយន្តការដោះស្រាយបណ្ដឹងមានលក្ខណៈជាប្រព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់នូវយន្តការនេះ | 42,460 | 0 | 42,460 | |
| ៤. | ការរៀបចំតាក់តែង និងដាក់ឱ្យអនុវត្តសាកល្បងនូវយន្តការអធិការកិច្ចទៅលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យយន្តការនេះអាចអនុវត្តបានយ៉ាងពេញលេញនៅឆ្នាំ២០១៧ | 37,440 | 0 | 37,440 | |
| ៥. | ការរៀបចំតាក់តែង និងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុងរបស់ក្រុង ស្រុក ខណ្ឌ តាមរយៈប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងរបស់ក្រុង ស្រុក សម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់ក៏ដូចជាដើម្បីប្រមូល និងផ្ដល់នូវធាតុចូលនានាសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | 110,790 | 0 | 110,790 | |
| **សរុប** | | **563,742** | **3,000,000** | **3,563,742** | |

<u>សម្គាល់</u> ៖ (1) មូលនិធិសម្រាប់ផ្នែកតម្រូវការមានប្រមាណ៣លានដុល្លារអាមេរិក គឺជាការប៉ាន់ស្មានដែលបានគណនាផ្អែកលើមូលនិធិសរុបចំនួន៣ឆ្នាំដែលគាំទ្រដោយ JSDF ចំនួន៥លានដុល្លារអាមេរិក គាំទ្រដោយ EU ចំនួន២លានអឺរ៉ូ គាំទ្រដោយ USAID ចំនួន១លានដុល្លារអាមេរិក និងគាំទ្រដោយ NGOs ចំនួន១លានដុល្លារអាមេរិក។ អង្គការ RACHA នឹងគាំទ្រអនុវត្តការងារគណនេយ្យភាពសង្គមទាំងផ្នែកផ្គត់ផ្គង់ក្នុងស្រុកគោលដៅចំនួន១១ផងដែរ។ គម្រោង EU SPACE គ្រោងចូលរួមបដិភាគ តាមរយៈការគាំទ្រជំនួយបច្ចេកទេសក្នុងលទ្ធផលរំពឹងទុកទី១ និងលទ្ធផលរំពឹងទុកទី៣ ប៉ុន្តែថវិកានៃការចូលរួមបដិភាគនេះដាក់បញ្ចូលក្នុងសមិទ្ធផលរំពឹងទុកទី១ដែលពាក់ព័ន្ធនឹង ការរៀបចំគោលនយោបាយ។

## ៣. សមិទ្ធផលរំពឹងទុកទីបី ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

### ៣.១. សេចក្តីផ្តើម និងចំណុចដៅ

ចំនួនបុគ្គលិក សមាសភាព សមត្ថភាពជំនាញនិងឥរិយាបថរបស់បុគ្គលិក ការលើកទឹកចិត្តដល់បុគ្គលិក និងការផ្តល់សិទ្ធិអំណាចសមស្រប ដែលធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រងបុគ្គលិកទាំងនេះប្រកបដោយភាពបត់បែន គឺជាកត្តាដ៏សំខាន់ក្នុងការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ក្នុងសមិទ្ធផលរំពឹងទុកនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបាននូវស្វ័យភាពកាន់តែច្រើនឡើងក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន (ដូចជា ការជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការដាក់វិន័យជាដើម) ហើយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តនឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រី បុគ្គលិកទាំងអស់។ ការអភិវឌ្ឍសមត្ថភាពនឹងផ្តោតជាសំខាន់លើការអភិវឌ្ឍសមត្ថភាពផ្អែកតាមតម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយការអភិវឌ្ឍសមត្ថភាពនេះនឹងធ្វើឡើងតាមរយៈការហ្វឹកហ្វឺន ការផ្តល់ព័ត៌មាននិងសម្ភារៈនានា ការឆ្លើយតបភ្លាមៗទៅនឹងសំណួរនានាតាមរយៈទូរស័ព្ទនិងអ៊ីម៉ែល ការរៀបចំសិក្ខាសាលានិងវេទិកានានា ការបណ្តុះបណ្តាលជាក់លាក់ទៅតាមការស្នើសុំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលធ្វើឡើងដោយផ្ទាល់ ឬតាមរយៈអ្នកផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពផ្សេងទៀត ការបណ្តុះបណ្តាលដែលរៀបចំឡើងដោយថ្នាក់ជាតិអំពីប្រព័ន្ធ ឬលិខិតបទដ្ឋានគតិយុត្តថ្មីៗនានា ការរៀនសូត្រពីសកម្មភាព និងការផ្លាស់ប្តូរបទពិសោធន៍នានា។

សមិទ្ធផលរំពឹងទុកដ៏សំខាន់ពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ដែលត្រូវសម្រេចឱ្យបានគឺ **រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនប្រកបដោយស្វ័យភាព និងប្រសិទ្ធភាព ដើម្បីសម្រេចបាននូវអាណត្តិ និងអាទិភាពនានាក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។**

តារាងទី៩ខាងក្រោមសង្ខេបអំពីសូចនាករ និងចំណុចដៅនានាដែលកំណត់នៅក្នុងផអ៣ទី២។ ស្ថាប័នអនុវត្តទាំងអស់ទទួលខុសត្រូវក្នុងការសម្រេចឱ្យបានចំណុចដៅទាំងនេះ តាមរយៈការកំណត់នូវលទ្ធផលរំពឹងទុក និងសកម្មភាពនានាដែលពាក់ព័ន្ធនឹងសមិទ្ធផលរំពឹងទុកនេះ។ លទ្ធផលរំពឹងទុកនានាដែលត្រូវសម្រេច និងគម្រោងថវិកាមានចែងបន្ទាប់ពីតារាងនេះ។

**តារាងទី៩ ៖ សូចនាករ និងចំណុចដៅនានានៃសមិទ្ធផលរំពឹងទុកទី៣**

| សូចនាករ និងចំណុចដៅ | 2016 |
|---|---|
| ១. ចំនួនភាគរយនៃបុគ្គលិករដ្ឋបាលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានជ្រើសរើស តែងតាំង លើកសរសើរ និងដាក់វិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សា | 100% |
| ២. ចំនួនភាគរយនៃមន្ត្រីថ្នាក់គ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានវាយតម្លៃអំពីគុណផលការងារ ដែលធ្វើឡើងដោយអ្នកគ្រប់គ្រងផ្ទាល់ | 75% |
| ៣. ចំនួនភាគរយនៃនាយក នាយករងរដ្ឋបាលរាជធានី ខេត្ត ជាស្ត្រី | 12% |

| សូចនាករ និងចំណុចដៅ | 2016 |
|---|---|
| ៤. ចំនួនភាគរយនៃនាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានអង្គភាពនៃសាលារាជធានី ខេត្ត ជាស្ត្រី | 12% |
| ៥. ចំនួនភាគរយនៃនាយក នាយករងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាស្ត្រី | 19% |
| ៦. ចំនួនភាគរយនៃប្រធាន អនុប្រធានការិយាល័យ អង្គភាពនៃសាលាក្រុង ស្រុក ខណ្ឌ ជាស្ត្រី | 22% |
| ៧. ចំនួនភាគរយនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តដែលបានផ្តល់ការគាំទ្រផ្នែកអភិវឌ្ឍសមត្ថភាពទាំង៥ប្រភេទ[10] | 100% |
| ៨. ចំនួនភាគរយនៃអភិបាល និងប្រធានក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានទទួលវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចប្រចាំឆ្នាំអំពីការបញ្ជ្រាបយេនឌ័រ | 95% |
| ៩. ចំនួនភាគរយនៃសមាជិកក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលយល់ឃើញថា វគ្គបណ្តុះបណ្តាលបានរៀបចំគ្រប់គ្រាន់សម្រាប់ការអនុវត្តមុខងាររបស់ខ្លួន | 50% |
| ១០.ចំនួនភាគរយនៃកិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាព គឺជាកិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពដែលផ្អែកតាមតម្រូវការ | 40% |
| ១១.ចំនួនជាមធ្យមនៃដីកាដែលបានដាក់ចេញដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ | 0,7% |
| ១២.ចំនួនភាគរយនៃសេចក្តីសម្រេចចិត្តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌបានកើនឡើង | 25% |

<u>សម្គាល់</u> ៖ ការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពធៀបនឹងសូចនាករ និងចំណុចដៅទាំងនេះនឹងឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍ប្រចាំឆ្នាំ។

### ៣.២. លទ្ធផលរំពឹងទុក

ផ្អែកតាមផអ៣ទី២ សមិទ្ធផលរំពឹងទុកទី៣ស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធផលរំពឹងទុកចំនួន៥ ហើយលទ្ធផលរំពឹងទុកទាំងនេះត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ចំនួន៥ សម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ ដែលរួមមានដូចខាងក្រោម ៖

**លទ្ធផលរំពឹងទុកទី ១ ៖ ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។**

សេចក្តីព្រាងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំបញ្ចប់នៅចុងឆ្នាំ២០១៥។ សេចក្តីព្រាងនេះនឹងត្រូវដាក់ជូនរាជរដ្ឋាភិបាលអនុម័ត និងដាក់ឱ្យប្រើប្រាស់ពីដើមឆ្នាំ២០១៦តទៅ។ ការអនុវត្តលក្ខន្តិកៈដោយឡែកនេះតម្រូវឱ្យមានការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តមួយចំនួនផ្សេងទៀត ដូច្នេះ សកម្មភាពជាអាទិភាពដែលត្រូវផ្តោតការយកចិត្ត

---

[10] ប្រភេទនៃការអភិវឌ្ឍសមត្ថភាពទាំង៥រួមមាន ១) ការហ្វឹកហ្វឺន និងការប្រឹក្សាយោបល់ ២)ប្រព័ន្ធទំនាក់ទំនងព័ត៌មានតាមរយៈសារអេឡិចត្រូនិច បណ្តាញទំនាក់ទំនងសង្គម ៣) ការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក និងទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ ៤)ការសម្របសម្រួលការអភិវឌ្ឍស្ថាប័ន និង ៥) ការបណ្តុះបណ្តាល។

ទុកដាក់ក្នុងឆ្នាំ២០១៦ រួមមាន (១) ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំពាក់ព័ន្ធនានា ដែលកំណត់អំពីនីតិវិធីលម្អិតដែលត្រូវអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការតែងតាំង ការគ្រប់គ្រង ការបញ្ឈប់ ការផ្ទេរ ការដាក់វិន័យ ការវាយតម្លៃគុណផលបុគ្គលិក និងកិច្ចការផ្សេងទៀតពាក់ព័ន្ធនឹងការគ្រប់គ្រង ចាត់ចែង ប្រើប្រាស់ និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង(២) ការវាយតម្លៃគុណផលរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ដល់ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយស្វ័យភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់។ ការរៀបចំ និងការអនុវត្តនូវយុទ្ធសាស្ត្រនេះ ត្រូវផ្អែកលើការវិភាគបញ្ហាប្រឈមនានា ព្រមទាំងមេរៀន និងបទពិសោធន៍នាពេលកន្លងមក និងត្រូវរៀបចំឱ្យមានកិច្ចដំណើរការ និងវិធានការជាក់លាក់ដើម្បីធានាដល់ការជំរុញការជ្រើសរើស និងតែងតាំងបុគ្គលិកជាស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការរៀបចំ និងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំពាក់ព័ន្ធនានានៃលទ្ធផលរំពឹងទុកនេះត្រូវស្ថិតក្រោមការដឹកនាំ និងសម្របសម្រួលដោយក្រសួងមុខងារសាធារណៈ។ ការរៀបចំយុទ្ធសាស្ត្រ សម្រាប់ធានាដល់ការបង្កើនចំនួនបុគ្គលិកជាស្ត្រីក្នុងមុខតំណែងថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិនឹងស្ថិតក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។

ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អំពីប្រព័ន្ធគ្រប់គ្រងបុគ្គលិកតាមបែបវិមជ្ឈការនឹងត្រូវអនុវត្តដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ដោយមានការគាំទ្រពីក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

**លទ្ធផលរំពឹងទុកទី ២ ៖ ការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។**

ក្នុងឆ្នាំ២០១៥ ក្រោមការសម្របសម្រួល និងការគាំទ្រពីក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប រដ្ឋបាលរាជធានី ខេត្តមួយចំនួនបានរៀបចំនូវកម្មវិធី ឯកសារ និងវគ្គបណ្តុះបណ្តាលអំពីបញ្ហាយេនឌ័រ និងការលើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការរៀបចំវគ្គបណ្តុះបណ្តាលនេះមានគោលបំណងជួយឱ្យថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានគំនិតផ្តួចផ្តើម និងចាត់វិធានការសមស្របក្នុងការអនុវត្តការងារគ្រប់គ្រងប្រចាំថ្ងៃរបស់ខ្លួន ដែលធានាដល់ការលើកកម្ពស់ការឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមងាយរងគ្រោះ និងពង្រឹងភាពអង់អាចរបស់ស្ត្រី។ ជាមួយគ្នានេះដែរ ក្នុងឆ្នាំ២០១៥ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏បានសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាក្នុងការរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីការបញ្ជ្រាបយេនឌ័រ ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមផងដែរ។ ក្នុងឆ្នាំ២០១៦ សកម្មភាពជាអាទិភាពដែលត្រូវបន្តផ្តោតការយកចិត្តទុកដាក់រួមមាន (១) ការបន្តរៀបចំវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចដល់ថ្នាក់ដឹកនាំទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីបញ្ហាយេនឌ័រ និងការលើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ (២) ការរៀបចំបញ្ចប់ និងដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំស្តីពីការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម (៣) ការបន្តការគាំទ្រ និងពង្រឹងប្រសិទ្ធភាពការងាររបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៤) ការបន្តពង្រឹង និងគាំទ្រដល់

បណ្ដាញសមាជិកក្រុមប្រឹក្សាជាស្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និង (៥) ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃលើប្រសិទ្ធភាពនៃការបញ្ជ្រាបយេនឌ័រ និងការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការអនុវត្តនូវសវនកម្មយេនឌ័រ។

លទ្ធផលរំពឹងទុកនេះ នឹងដឹកនាំ និងសម្របសម្រួលការអនុវត្តដោយក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកទី ៣ ៖ ការសម្របសម្រួលនូវបែបផែននានាស្ដីពីភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការសង្គមស៊ីវិលនានា ដើម្បីអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។**

លទ្ធផលរំពឹងទុកនេះ គ្របដណ្ដប់លើសកម្មភាពទាំងអស់នៃការអភិវឌ្ឍសមត្ថភាពរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ដោយរួមបញ្ចូលទាំងការបណ្ដុះបណ្ដាលផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ការហ្វឹកហ្វឺន ការប្រឹក្សាយោបល់ និងការផ្ដល់ព័ត៌មាន។ល។ លទ្ធផលរំពឹងទុកនេះនឹងគាំទ្រដល់លទ្ធផលរំពឹងទុកផ្សេងទៀតក្នុង ផ.ស.ថ។ បន្ទាប់ពីការអនុម័ត ផ.ស.ថ មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនីមួយៗត្រូវកំណត់អំពីសកម្មភាពអភិវឌ្ឍន៍សមត្ថភាពផ្នែកផ្គត់ផ្គង់ និងពេលវេលាសម្រាប់អនុវត្តសកម្មភាពទាំងនេះ។ ដើម្បីអនុវត្តផែនការបណ្ដុះបណ្ដាល មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានីខេត្តនីមួយៗត្រូវស្វែងរកអ្នកដែលមានលទ្ធភាពផ្ដល់សេវា និងធ្វើការសិក្សាវាយតម្លៃអំពីតម្រូវការបណ្ដុះបណ្ដាលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការកំណត់តម្រូវការនៃការបណ្ដុះបណ្ដាលត្រូវអនុវត្តដោយផ្អែកជាមូលដ្ឋានលើកិច្ចដំណើរការនៃការអភិវឌ្ឍស្ថាប័ន ត្រូវបានបណ្ដុះបណ្ដាលរួចរាល់ហើយ។ នៅដើមឆ្នាំ២០១៦ ផែនការបណ្ដុះបណ្ដាលដ៏ពេញលេញមួយ (ដែលគ្របដណ្ដប់ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការរួមបញ្ចូលទាំងតម្រូវការនានារបស់ក្រុមប្រឹក្សា និងដោយមានការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា) នឹងត្រូវបានរៀបចំ និងអនុម័ត។ ទំនាក់ទំនងរវាងសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយអគ្គលេខាធិការដ្ឋានរបស់ខ្លួននឹងត្រូវបានពង្រឹង ហើយសកម្មភាពនានានៃការអភិវឌ្ឍសមត្ថភាពនឹងផ្ដោតការយកចិត្តទុកដាក់លើការបញ្ជ្រាបយេនឌ័រ ដោយត្រូវគិតគូរពីភាពខុសគ្នាអំពីតម្រូវការអភិវឌ្ឍន៍សមត្ថភាពរវាងបុរស និងស្ត្រី និងក្រុមផ្សេងៗទៀតដែលពុំសូវបានយកចិត្តទុកដាក់នាពេលកន្លងមក។ ការអនុវត្តផែនការបណ្ដុះបណ្ដាលទាំងអស់នឹងត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីវិធីសាស្ត្រ និងប្រសិទ្ធភាព ក៏ដូចជាការកំណត់នូវកញ្ចប់សេវាជាមូលដ្ឋានសម្រាប់អភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសិក្សារៀនសូត្រ និងជាមេរៀន បទពិសោធន៍ក្នុងការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ (លទ្ធផលរំពឹងទុក៤)។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ដោយមានការណែនាំ និងគាំទ្រកិច្ចប្រតិបត្តិការពីក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកទី ៤ ៖ ការអនុម័តផែនការរៀបចំបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ។**

ការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ តម្រូវឱ្យមាននូវសកម្មភាពជាច្រើនដែលត្រូវអនុវត្តជាជំហានៗ។ ក្នុងអំឡុងឆ្នាំ២០១៦ ធនាគារអភិវឌ្ឍន៍អាស៊ីមានគម្រោងគាំទ្រជំនួយបច្ចេកទេស ដើម្បីពង្រឹងនូវការផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅក្នុងដំណាក់កាលដំបូង កិច្ចដំណើរការនេះតម្រូវឱ្យមានការរៀបចំផែនការសកម្មភាពដ៏លម្អិតមួយក្នុងការបង្កើតវិទ្យាស្ថាន (បច្ចុប្បន្នឯកសារទស្សនទានស្តីពីការផ្តល់ជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលរួមបញ្ចូលទាំងជំនួយបច្ចេកទេសក្នុងការសិក្សាអំពីការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំរួចហើយ)។ យើងរំពឹងថា តាមរយៈជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនឹងផ្តល់នូវជម្រើស និងអនុសាសន៍នានាសម្រាប់ការបង្កើតវិទ្យាស្ថានដែលរួមមាន (១) ការវិភាគ ការប៉ាន់ប្រមាណ និង វាយតម្លៃអំពីលទ្ធភាពនៃការបណ្តុះបណ្តាលនាពេលបច្ចុប្បន្ន ការរៀបចំវគ្គបណ្តុះបណ្តាល ការចំណាយ ប្រសិទ្ធភាព គុណតម្លៃនៃថវិកា និងវិធីសាស្ត្រ (២) ការរៀបចំផែនការយុទ្ធសាស្ត្របណ្តុះបណ្តាលសម្រាប់វិទ្យាស្ថានអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងវិសាលភាពនៃការផ្តល់សេវា (៣) ការកំណត់អំពីបទប្បញ្ញត្តិសម្រាប់ការបណ្តុះបណ្តាល និងតម្រូវការបណ្តុះបណ្តាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៤) ការអភិវឌ្ឍកម្មវិធីសិក្សា និងកម្មវិធីនានា និង (៥) ការបញ្ចប់ការសិក្សាអំពីលទ្ធភាពសម្រាប់ការសាងសង់ និងកិច្ចប្រតិបត្តិការរបស់វិទ្យាស្ថាន។ នៅចុងឆ្នាំ២០១៦ ប្រសិនបើការបង្កើតវិទ្យាស្ថានអាចដំណើរការទៅបាន នោះធនធាននឹងត្រូវបានកំណត់សម្រាប់ការសាងសង់ និងកិច្ចប្រតិបត្តិការ។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងមហាផ្ទៃ។

**លទ្ធផលរំពឹងទុកទី ៥ ៖ ការបញ្ចប់គម្រោងសាងសង់អគាររដ្ឋបាលសាលាស្រុកចំនួន៣៤។**

ការសាងសង់អគាររដ្ឋបាលសាលាស្រុកចំនួន៣៤ បានចាប់ផ្តើមក្នុងអំឡុងឆ្នាំ២០១៥ និងត្រូវបញ្ចប់សព្វគ្រប់ និងដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៦។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយរដ្ឋបាលស្រុក ដោយមានការគាំទ្រពីក្រសួងមហាផ្ទៃ និងតាមរយៈហិរញ្ញប្បទានកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

### ៣.៣. គម្រោងថវិកា

ថវិកាប៉ាន់ស្មានសរុបនៃសមិទ្ធផលរំពឹងទុកនេះសម្រាប់ឆ្នាំ២០១៦ មានចំនួនប្រមាណ១៣លានដុល្លារអាមេរិកដែលមានបរិយាយលម្អិតនៅតារាងខាងក្រោម។

### តារាងទី១០ ៖ គម្រោងថវិកា និងប្រភពមូលនិធិសម្រាប់សមិទ្ធផលរំពឹងទុកទី៣ (គិតជាដុល្លារ)

| លទ្ធផលរំពឹងទុក | | កញ្ចប់រួម | ផ្សេងៗ | សរុប | សម្គាល់ |
|---|---|---|---|---|---|
| ១. | ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងយុទ្ធសាស្ត្រស្ដីពីការលើកកម្ពស់ចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 110,000 | 0 | 110,000 | |
| ២. | ការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 554,700 | 0 | 554,700 | |
| ៣. | ការសម្រសម្រួលនូវបែបផែននានាស្ដីពីភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការសង្គមស៊ីវិលនានា ដើម្បីអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 5,629,015 | 0 | 5,629,015 | |
| ៤. | ការអនុម័តផែនការរៀបចំបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ | 18,490 | 0 | 18,490 | [1] |
| ៥. | ការបញ្ចប់គម្រោងសាងសង់អគាររដ្ឋបាលសាលាស្រុកចំនួន៣៤ | 0 | 6,749,124 | 6,749,124 | [2] |
| **សរុប** | | **6,312,205** | **6,749,124** | **13,061,329** | |

<u>*សម្គាល់*</u> ៖ [1] ADB មានគម្រោងជួយគាំទ្រជំនួយបច្ចេកទេសសម្រាប់ការអភិវឌ្ឍសមត្ថភាព។ ថវិកានៃការចូលរួមបដិភាគនេះបានបញ្ចូលក្នុងលទ្ធផលរំពឹងទុកទី៦នៃសមិទ្ធផលរំពឹងទុកទី៥។ [2] ជាកម្ចីរបស់ ADB តាមរយៈគម្រោង ADB/DPSFM1។ គម្រោង EU SPACE នឹងចូលរួមបដិភាគ តាមរយៈការផ្តល់ជំនួយបច្ចេកទេសដើម្បីគាំទ្រការអនុវត្តលទ្ធផលរំពឹងទុកទី១ ប៉ុន្តែថវិកាបដិភាគនេះបានបញ្ចូលក្នុងសមិទ្ធផលរំពឹងទុកទី១ សម្រាប់គាំទ្រការរៀបចំគោលនយោបាយ។

## ៤. សមិទ្ធផលរំពឹងទុកទីបួន ÷ ការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ៤.១. សេចក្តីផ្តើម និងចំណុចដៅ

សមិទ្ធផលរំពឹងទុកនេះ មានគោលបំណងពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវានានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ការងារនេះពាក់ព័ន្ធនឹងការផ្ទេរមុខងារនានាពីក្រសួង ស្ថាប័នឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីរដ្ឋបាលខេត្តឱ្យទៅរដ្ឋបាលក្រុង ការលើកកម្ពស់គំនិតផ្តួចផ្តើមថ្មីៗ និងការបង្កើតភាពជាដៃគូក្នុងការផ្តល់សេវា និងកិច្ចអភិវឌ្ឍមូលដ្ឋានតាមរយៈមុខងារជាអាណត្តិទូទៅ ព្រមទាំងការពង្រឹងការផ្តល់សេវារដ្ឋបាលនានា។

សមិទ្ធផលរំពឹងទុកដ៏សំខាន់ពាក់ព័ន្ធនឹងការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវសម្រេចឱ្យបានគឺ **រដ្ឋបាលថ្នាក់ក្រោមជាតិអាចឆ្លើយតបចំពោះការរំពឹងទុករបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសេវា និងអាចបម្រើសេវាសំខាន់ៗនានានៅថ្នាក់រដ្ឋបាលដែលនៅកៀកជិតបំផុតនឹងប្រជាពលរដ្ឋ។**

តារាងទី១១ខាងក្រោមសង្ខេបអំពីសូចនាករ និងចំណុចដៅដែលកំណត់នៅក្នុងផអ៣ទី២។ ស្ថាប័នអនុវត្តទាំងអស់ទទួលខុសត្រូវក្នុងការសម្រេចឱ្យបានចំណុចដៅទាំងនេះ តាមរយៈការកំណត់នូវលទ្ធផលរំពឹងទុក និងសកម្មភាពនានាដែលពាក់ព័ន្ធនឹងសមិទ្ធផលរំពឹងទុកនេះ។ លទ្ធផលរំពឹងទុកនានាដែលត្រូវសម្រេច និងគម្រោងថវិកាមានចែងបន្ទាប់ពីតារាងនេះ។

**តារាងទី១១ ៖ សូចនាករ និងចំណុចដៅសម្រាប់សមិទ្ធផលរំពឹងទុកទី៤**

| សូចនាករ និងចំណុចដៅ | 2016 |
|---|---|
| ១. ចំនួនភាគរយនៃថវិកាជាតិបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជាលទ្ធផលនៃការផ្ទេរមុខងារ | 1% |
| ២. ចំនួនរដ្ឋបាលក្រុង ស្រុកដែលបានទទួលនូវការផ្ទេរមុខងារ និងធនធានពីការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុកនៃក្រសួង ស្ថាប័នក្នុងវិស័យសំខាន់ៗចំនួន០២ (ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល) | 4 |
| ៣. ចំនួនរដ្ឋបាលក្រុង ស្រុកដែលបានទទួលនូវការផ្ទេរមុខងារ និងធនធានពីការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុករបស់ក្រសួង ស្ថាប័នក្នុងវិស័យផ្សេងៗទៀតយ៉ាងតិចចំនួន០៣[11] | 50 |
| ៤. ចំនួនរដ្ឋបាលក្រុង ស្រុកដែលបានទទួលការផ្ទេរមុខងារនិងធនធានពាក់ព័ន្ធនឹងសេវាទីប្រជុំជន[12] ពីរដ្ឋបាលខេត្ត | 3 |
| ៥. ការវាយតម្លៃដោយឯករាជ្យមួយនឹងបង្ហាញឱ្យឃើញថា ការផ្តល់សេវាកាន់តែមានភាពល្អប្រសើរឡើង នៅពេលដែលមុខងារត្រូវបានធ្វើវិមជ្ឈការពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាល ក្រុង | គ្មាន |

[11] ការិយាល័យដែលមានបុគ្គលិកពី១-៣នាក់។

[12] រួមបញ្ចូលការប្រមូលសំរាម ការគ្រប់គ្រងប្រព័ន្ធលូបង្ហូរកាកសំណល់ ការគ្រប់គ្រង និងការអភិវឌ្ឍទីផ្សារ និងការអភិវឌ្ឍតំបន់រមណីយដ្ឋានជាដើម និងយ៉ាងហោចណាស់មានសេវា២ផ្សេងទៀត។

| សូចនាករ និងចំណុចដៅ | 2016 |
|---|---|
| ៦. ចំនួនភាគរយនៃការកើនឡើងនៃការចំណាយពីមូលនិធិឃុំ សង្កាត់ទៅលើសេវាសង្គម | 150% |
| ៧. ចំនួនសេវាថ្មី(មិនធ្លាប់អនុវត្តពីមុន)ដែលរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុងស្រុកបានផ្តួចផ្តើមគំនិត និងសាកល្បងក្នុងការផ្តល់សេវា ដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក | 10 |
| ៨. ចំនួនករណីនៃបទពិសោធន៍ល្អៗអំពីភាពជោគជ័យនៃការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានប្រមូលចងក្រងជាឯកសារ | 10 |
| ៩. ចំនួនថវិកាដែលរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌបានអនុវត្តនូវការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានក្នុងភាពជាដៃគូជាមួយក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងវិស័យឯកជនសម្រាប់កម្រិតថ្នាក់រដ្ឋបាលនីមួយៗ (គិតជាលានដុល្លារ) | 3 |
| ១០. ចំនួនភាគរយនៃប្រជាពលរដ្ឋដែលពេញចិត្តចំពោះការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានដែលជាគំនិតផ្តួចផ្តើមថ្មីៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 50% |
| ១១.ចំនួនការិយាល័យច្រកចេញចូលតែមួយដែលបានពង្រីកបន្ថែមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងនៅថ្នាក់ខេត្ត | 5 |
| ១២.យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមលក្ខណៈច្រកចេញចូលតែមួយ (ក្រៅពីក្រុង ស្រុក ខណ្ឌ ខេត្តដែលមានការិយាល័យ ច្រកចេញចូលតែមួយ) ត្រូវបានរៀបចំឡើងនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នៅទូទាំងប្រទេស | អនុវត្ត |
| ១៣.ចំនួនភាគរយនៃការកើនឡើងនូវសេវារដ្ឋបាលផ្សេងៗដែលផ្តល់តាមរយៈការិយាល័យច្រកចេញចូលតែមួយ | 8% |
| ១៤.ចំនួនភាគរយនៃការកើនឡើងរបស់ប្រជាពលរដ្ឋដែលបានមកទទួលសេវារដ្ឋបាលតាមរយៈការិយាល័យច្រកចេញចូលតែមួយ | 10% |

សម្គាល់ ៖ ការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពធៀបនឹងសូចនាករ និងចំណុចដៅទាំងនេះនឹងឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍ប្រចាំឆ្នាំ។

### ៤.២. លទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកទី៤នៃផអ៣ទី២ស្តីពីការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធផលរំពឹងទុកចំនួន៥ ហើយលទ្ធផលរំពឹងទុកទាំងនេះត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ចំនួន១២ សម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ ដែលរួមមានដូចខាងក្រោម ៖

**លទ្ធផលរំពឹងទុកទី ១ ៖ ការកំណត់ និងការអនុវត្តមុខងារជាជម្រើសជាច្រើនផ្សេងទៀត ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។**

តាមរយៈមុខងារជាអាណត្តិទូទៅរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តនូវសកម្មភាពនានាដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន។ មុខងារទាំងនេះរួមមានមុខងារទាំងឡាយណាដែលមិនស្ថិតនៅក្រោមអាណត្តិនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល ឬមុខងារទាំងឡាយដែលស្ថិតនៅក្រោម

អាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា ហើយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាពុំជំទាស់ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងអនុវត្តនូវមុខងារទាំងនោះ។ មុខងារជាជម្រើសអាចអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់ ឬអនុវត្តក្នុងភាពជាដៃគូជាមួយស្ថាប័នផ្សេងទៀត។

សកម្មភាពនានាស្តីពីការប្រមូលព័ត៌មាន ការអភិវឌ្ឍសមត្ថភាព ការប្រាស្រ័យទាក់ទង និងការសិក្សាមេរៀនបទពិសោធន៍នឹងត្រូវបានអនុវត្ត ដើម្បីលើកកម្ពស់សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តសកម្មភាពសេវាសង្គមឱ្យបានកាន់តែច្រើន ក៏ដូចជាការផ្តួចផ្តើមគំនិតអំពីបែបផែននៃការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សេចក្តីណែនាំបច្ចេកទេសស្តីពីការអនុវត្តមុខងារជាជម្រើស ត្រូវបានរៀបចំ និងអនុម័តនៅចុងឆ្នាំ២០១៥។ ការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈនឹងត្រូវធ្វើឡើង ដើម្បីលើកកម្ពស់ការអនុវត្តមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សកម្មភាពទាំងនេះនឹងផ្តល់ព័ត៌មានច្បាស់លាស់ ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពផ្តួចផ្តើម និងអនុវត្តមុខងារជាជម្រើស ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនៅមូលដ្ឋាន។ ជាមួយគ្នានេះដែរ ត្រូវរៀបចំយន្តការនានា ដើម្បីលើកកម្ពស់ការសិក្សារៀនសូត្រ និងការផ្លាស់ប្តូរបទពិសោធន៍នានាក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រៅពីនេះ ត្រូវពិនិត្យមើលឡើងវិញ និងកែសម្រួលប្រព័ន្ធ និងនីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុ ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីកំណត់ និងធ្វើឱ្យមានតុល្យភាពរវាងការប្រើប្រាស់មូលនិធិសម្រាប់ការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការយកចិត្តទុកដាក់លើការផ្តល់សេវាកម្មជូនប្រជាពលរដ្ឋ។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**លទ្ធផលរំពឹងទុកទី ២ ៖ ការលើកកម្ពស់ការផ្តល់សេវាសង្គម ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានពង្រឹង តាមរយៈការអនុវត្តមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់។**

គម្រោងមួយចំនួន ដែលត្រូវបានអនុវត្តនៅថ្នាក់ក្រោមជាតិបានប្រើប្រាស់មូលនិធិក្រុង ស្រុក និងឃុំ សង្កាត់ សម្រាប់គាំទ្រការអនុវត្តសកម្មភាពជាក់លាក់មួយចំនួន។ គម្រោងទាំងនោះរួមមាន ៖

- កម្មវិធីសិទ្ធិកុមារនៃអង្គការ UNICEF ៖ ការលើកកម្ពស់ភាពធន់ ការរស់រានមានជីវិតរបស់សហគមន៍ ការការពារនិងអភិវឌ្ឍន៍កុមារនិងទារក ក៏ដូចជាកុមារពិការ ដែលមានថវិកាគាំទ្រសរុបចំនួន២.១១៦.៣៤៦ដុល្លារអាមេរិក។
- ទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍរបស់ប្រទេសស្វីស បានផ្តល់មូលនិធិចំនួន ៥០០.០០០ដុល្លារអាមេរិក តាមរយៈថវិកាកញ្ចប់រួម ដើម្បីគាំទ្រមូលនិធិឃុំ សង្កាត់ក្នុងការលើកកម្ពស់សេវាសង្គម។
- គម្រោងសង្គហទានសង្គមសម្រាប់សុខភាព និងអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារ និងគម្រោងគ្រប់គ្រងអនាម័យជនបទ គាំទ្រដោយធនាគារពិភពលោក បានផ្តល់មូលនិធិគាំទ្រចំនួន

៣១៣.៧៧៣ដុល្លារអាមេរិក។

- គម្រោងលើកកម្ពស់សិទ្ធិ និងសុខភាពបន្តពូជ គាំទ្រដោយអង្គការ UNFPA ផ្តល់មូលនិធិគាំទ្រចំនួន១៥០.១៤១ដុល្លារអាមេរិក។ ជាមួយគ្នានេះដែរ UNFPA នឹងសហការជាមួយកម្មវិធីសិទ្ធិកុមារ ដើម្បីផ្តល់ថវិកាគាំទ្រដល់វគ្គបណ្តុះបណ្តាលអំពីសៀវភៅណែនាំស្តីពីការរៀបចំគម្រោងសេវាកម្មក្រុង ស្រុក។
- គម្រោងកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍកសិកម្មខ្នាតតូចតំបន់ជុំវិញបឹងទន្លេសាប គាំទ្រដោយ ADB ផ្តល់មូលនិធិគាំទ្រចំនួន៦,២លានដុល្លារអាមេរិក។
- គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់គាំទ្រដោយ GiZ RED III នឹងផ្តល់មូលនិធិគាំទ្រសម្រាប់កិច្ចអភិវឌ្ឍមូលដ្ឋាន និងវិស័យឯកជនដែលមានចំនួន៤១៦.៨៧៦ដុល្លារអាមេរិក។
- គម្រោងសេវាកម្មកសិកម្មសម្រាប់ការផ្តួចផ្តើម ភាពធន់ និងការផ្សព្វផ្សាយ ដែលគាំទ្រដោយ **IFAD** នឹងផ្តល់មូលនិធិគាំទ្រចំនួន៥៧៧.០០០ដុល្លារអាមេរិក សម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។
- គម្រោងអភិបាលកិច្ចមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ គាំទ្រមូលនិធិដោយ Sida និង UNCDF នឹងផ្តល់មូលនិធិគាំទ្រចំនួន១៥១.៨២០ដុល្លារអាមេរិក សម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

លទ្ធផលរំពឹងទុកនេះនឹងសម្របសម្រួល អនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងស្ថាប័នពាក់ព័ន្ធនានា។

**លទ្ធផលរំពឹងទុកទី ៣ ៖ ការផ្ទេរមុខងារគ្រប់គ្រងការអប់រំបឋមសិក្សា ការអប់រំកុមារតូច និងការអប់រំក្រៅប្រព័ន្ធទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំងអស់នៅក្នុងខេត្តគោលដៅចំនួនមួយ។**

នៅក្នុងឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការសម្រេចចិត្តក្នុងការផ្ទេរមុខងារគ្រប់គ្រងការអប់រំកម្រិតបឋមសិក្សា ការអប់រំកុមារតូច និងការអប់រំក្រៅប្រព័ន្ធទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមដំណាក់កាលៗ។ ដើម្បីធានាដល់ការអនុវត្តសេចក្តីសម្រេចចិត្តនេះ កិច្ចការដែលត្រូវផ្តោតការយកចិត្តទុកដាក់អនុវត្តបន្តនៅក្នុងឆ្នាំ២០១៦ គឺ ១) ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ផ្ទេរមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំបឋមសិក្សា ការអប់រំកុមារតូច និងការអប់រំក្រៅប្រព័ន្ធ ២) ការរៀបចំយន្តការគាំទ្ររួមមានការបណ្តុះបណ្តាល និងការតាមដានត្រួតពិនិត្យ ៣) ការផ្ទេរមុខងារទាំងនេះ (រួមជាមួយធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស) ទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅទាំងអស់នៅក្នុងខេត្តបាត់ដំបង និង៤)ការសិក្សាវាយតម្លៃ ដកស្រង់បទពិសោធន៍ដើម្បីកែលម្អ និងពង្រីកការផ្ទេរមុខងារទាំងនោះ ទៅឱ្យក្រុង ស្រុកនៃខេត្តមួយចំនួនផ្សេងទៀត តាមដំណាក់កាលនានាដែលបានកំណត់។

លទ្ធផលរំពឹងទុកនេះនឹងដឹកនាំអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា ដោយសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកទី ៤ ៖ រដ្ឋបាលរាជធានី រដ្ឋបាលក្រុង ស្រុកទាំងអស់អនុវត្តនូវមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព។**

នៅចុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានសម្រេចផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកនៅទូទាំងប្រទេស តាមរយៈអនុក្រឹត្យលេខ១១៣ អនក្រ ប.ក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ ក្នុងឆ្នាំ២០១៦ កិច្ចការជាអាទិភាពដែលត្រូវអនុវត្តរួមមាន ១) ការរៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានា ២) ការរៀបចំយន្តការគាំទ្រនានា (ការរៀបចំផ្ទេរ ការបណ្តុះបណ្តាល ការគាំទ្របច្ចេកទេស និងការតាមដានត្រួតពិនិត្យ) ដើម្បីធានាថា រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកទាំងអស់អាចមានលទ្ធភាពក្នុងការចាប់ផ្តើមទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព ចាប់ពីឆ្នាំ២០១៦តទៅ និង ៣) ការសិក្សាវាយតម្លៃ និងការចែករំលែកមេរៀន និងបទពិសោធន៍ស្តីពីការអនុវត្តមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

លទ្ធផលរំពឹងទុកនេះនឹងត្រូវដឹកនាំអនុវត្តដោយក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកទី ៥ ៖ ការផ្ទេរមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល និងការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ក្នុងខេត្តគោលដៅចំនួនមួយ។**

ក្នុងឆ្នាំ២០១៥កន្លងមក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានសម្រេចចិត្តក្នុងការធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលខេត្តបាត់ដំបង និងរដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលឃុំ សង្កាត់នានានៃខេត្តបាត់ដំបងនូវមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល និងមុខងារការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍។ ដើម្បីធានាឱ្យរដ្ឋបាលទាំងនេះមានលទ្ធភាពក្នុងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មប្រកបដោយប្រសិទ្ធភាព សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៦ រួមមាន ១) ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការផ្ទេរធនធាននានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដើម្បីអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្ម ២)ការបន្តរៀបចំយន្តការគាំទ្រ (ការបណ្តុះបណ្តាល ការគាំទ្រផ្នែកបច្ចេកទេស និងការតាមដាន ត្រួតពិនិត្យ) ៣) ការសិក្សាវាយតម្លៃ ប្រមូលចងក្រងបទពិសោធន៍ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការកែលម្អការអនុវត្ត និងការធ្វើសេចក្តីសម្រេចចិត្តក្នុងការប្រគល់មុខងារទាំងនេះជាអចិន្ត្រៃយ៍ និងពង្រីកការផ្ទេរមុខងារទាំងនោះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅផ្សេងទៀត។

លទ្ធផលរំពឹងទុកនេះនឹងត្រូវដឹកនាំអនុវត្តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកទី ៦ ៖ ការផ្ទេរមុខងារគាំពារសុខភាពបឋមទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន។**

ក្នុងឆ្នាំ២០១៥ ក្រសួងសុខាភិបាលបានសាកល្បងផ្ទេរនូវមុខងារគ្រប់គ្រងមណ្ឌលសុខភាព ដែលស្ថិតនៅក្នុងស្រុកគោលដៅចំនួន៥នៃខេត្តពោធិសាត់ និងបាត់ដំបង។ ផ្អែកលើការសាកល្បងនេះ ក្រសួងសុខាភិបាល និងលេខាធិការដ្ឋាន គ.ជ.អ.ប ក៏បានសិក្សាអំពីលទ្ធភាព និងជម្រើសនានាសម្រាប់ ការផ្ទេរមុខងារគាំពារសុខភាពបឋមទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ ដើម្បីឈានទៅរកការឯក ភាពគ្នាក្នុងការផ្ទេរមុខងារនេះ កិច្ចការជាអាទិភាពសម្រាប់ឆ្នាំ២០១៦រួមមាន ១) ការបន្តពិភាក្សា ពិគ្រោះ យោបល់ជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ ដើម្បីស្វែករកការឯកភាពគ្នា ទៅលើជម្រើសនានា សម្រាប់ការផ្ទេរមុខងារសំណុំសកម្មភាពអប្បបរមានៃសេវាសុខាភិបាលទៅឱ្យ រដ្ឋបាលក្រោមជាតិមួយចំនួន ២) ការរៀបចំលិខិតបទដ្ឋានសម្រាប់ការផ្ទេរមុខងារ និងធនធានពាក់ព័ន្ធ នានា ៣) ការរៀបចំយន្តការគាំទ្រដល់ការផ្ទេរ និងការអនុវត្តមុខងារដែលត្រូវបានផ្ទេរ (ការបណ្តុះបណ្តាល ការគាំទ្រផ្នែកបច្ចេកទេស និងការត្រួតពិនិត្យ តាមដាន) និង៤) ការសិក្សាវាយតម្លៃ ដើម្បីកែលម្អ និងជា មូលដ្ឋានសម្រាប់ការពង្រីកការផ្ទេរមុខងារទាំងនេះទៅឱ្យរដ្ឋបាលក្រុង ស្រុកផ្សេងទៀត។

លទ្ធផលរំពឹងទុកនេះនឹងត្រូវដឹកនាំអនុវត្តដោយក្រសួងសុខាភិបាល សហការជាមួយក្រសួង មហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកទី ៧ ៖ ការផ្ទេរមុខងារការថែទាំផ្លូវលំជនបទមានលក្ខណៈជាប្រចាំទៅឱ្យរដ្ឋបាលថ្នាក់ ក្រោមជាតិគោលដៅមួយចំនួន។**

មុខងារថែទាំផ្លូវលំជនបទមានលក្ខណៈជាប្រចាំ គឺជាមុខងារមួយក្នុងចំណោមមុខងារផ្សេងទៀត ដែលបានស្នើឡើង ក្នុងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ការផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីធានាដល់ការផ្ទេរមុខងារនេះ សកម្មភាពដែលត្រូវ ផ្តល់អាទិភាពសម្រាប់ឆ្នាំ២០១៦នេះរួមមាន ១) ការពិគ្រោះពិភាក្សាដើម្បីស្វែងរកការឯកភាពអំពីជម្រើស នានាសម្រាប់ការផ្ទេរ ២) ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានា ៣) ការរៀបចំ បង្កើតយន្តការគាំទ្រ (ការបណ្តុះបណ្តាល ការគាំទ្រផ្នែកបច្ចេកទេស ការតាមដានត្រួតពិនិត្យ) និង ៤) ការសិក្សាវាយតម្លៃ និងប្រមូលចងក្រងបទពិសោធន៍នានា។

លទ្ធផលរំពឹងទុកនេះនឹងត្រូវដឹកនាំអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ សហការជាមួយក្រសួង មហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកទី ៨ ៖ បន្តគាំទ្រការអនុវត្តសាកល្បងនៃការផ្ទេរមុខងារគ្រប់គ្រងអនាម័យជនបទ និង ការគ្រប់គ្រង ការថែទាំ និងការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទៅស្រុកគោលដៅមួយចំនួន។**

ក្នុងឆ្នាំ២០១៦ ការសាកល្បងអនុវត្តមុខងារដែលត្រូវផ្ទេរឱ្យថ្នាក់ស្រុកពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការ និងការថែរទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនឹងអនុវត្តក្នុងស្រុកគោលដៅចំនួន៧ និងមុខងារនៃការគ្រប់គ្រង អនាម័យជនបទនឹងអនុវត្តក្នុងស្រុកគោលដៅចំនួន១០។ នៅដំណាច់ឆ្នាំ២០១៦ សិក្ខាសាលាឆ្លុះបញ្ចាំង

និងការសិក្សាវាយតម្លៃនឹងត្រូវបានរៀបចំ ដើម្បីពិនិត្យមើលប្រសិទ្ធភាពនៃការសាកល្បងទាំងពីរនេះ។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ សហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកទី ៩ ៖ ការព្រមព្រៀងទៅលើមុខងារជាក់លាក់របស់ក្រសួង ស្ថាប័នមួយចំនួនបន្ថែមទៀត ដើម្បីផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅឆ្នាំ២០១៧។**

ក្នុងក្របខណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួង ស្ថាប័ននានាមានតួនាទី និងការទទួលខុសត្រូវលើការរៀបចំតាក់តែងគោលនយោបាយ ការពង្រឹងការអនុវត្តតាមស្តង់ដារ ការផ្តល់ហិរញ្ញប្បទាន និងការអភិវឌ្ឍសមត្ថភាព។ ដោយឡែក រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនានាក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្នុងឆ្នាំ២០១៥កន្លងមកនេះ ក្រសួង ស្ថាប័នដែលស្ថិតក្នុងវិស័យអាទិភាពមួយចំនួនផ្សេងទៀតបានចាប់ផ្តើមរៀបចំបញ្ជីវិភាគមុខងារ និងការត្រួតពិនិត្យមើលមុខងារឡើងវិញ ដើម្បីឈានទៅធ្វើការកំណត់នូវមុខងារ និងធនធានសមស្របដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងឆ្នាំ២០១៦ កិច្ចការជាអាទិភាពដែលត្រូវផ្តោតការយកចិត្តទុកដាក់ គឺការបន្តពិនិត្យ ពិភាក្សា ដើម្បីឈានទៅរកការឯកភាពលើមុខងារនានាពាក់ព័ន្ធនឹងវិស័យកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ ជលផល ធនធានទឹក ទេសចរណ៍ និងការចូលរួមលើកកម្ពស់វប្បធម៌ជាតិជាដើម។ ដោយឡែកក្រសួងបរិស្ថាននឹងរៀបចំបញ្ចប់នូវលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការផ្ទេរមុខងារមួយចំនួនពាក់ព័ន្ធនឹងកិច្ចការពារធនធានធម្មជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងពាក់ព័ន្ធ។

**លទ្ធផលរំពឹងទុកទី ១០ ៖ ការព្រមព្រៀងទៅលើមុខងារសេវាទីប្រជុំជនសមស្របមួយចំនួនរបស់រដ្ឋបាលខេត្ត ដើម្បីផ្ទេរទៅឱ្យរដ្ឋបាលក្រុងនៅឆ្នាំ២០១៧។**

ក្នុងឆ្នាំ២០១៥ ក្រៅពីមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃក៏បានធ្វើការសិក្សា ប្រមូលព័ត៌មាននិងកំណត់នូវលទ្ធភាព និងជម្រើសនានាសម្រាប់ការផ្ទេរមុខងារសេវាទីប្រជុំជនផ្សេងទៀតពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង។ ក្នុងឆ្នាំ២០១៦នេះ សកម្មភាពជាអាទិភាពពាក់ព័ន្ធនឹងការផ្ទេរមុខងារទីប្រជុំជននេះរួមមាន ១) បន្តការពិនិត្យពិភាក្សាទៅលើជម្រើសនានាដែលបានសិក្សានៅក្នុងឆ្នាំ២០១៥ ២) រៀបចំឱ្យមានការពិគ្រោះយោបល់ ដើម្បីឈានទៅរកការឯកភាពគ្នាក្នុងការផ្ទេរមុខងារសេវាទីប្រជុំជននានាដូចជា ការគ្រប់គ្រងសួនច្បារសាធារណៈ ការបំភ្លឺផ្លូវសាធារណៈ ការគ្រប់គ្រងប្រព័ន្ធបង្ហូរកាកសំណល់រាវ ការគ្រប់គ្រងផ្សារ និងចំណតយានយន្តសាធារណៈជាដើម និង ៣) ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានា សម្រាប់ការផ្ទេរមុខងារទីប្រជុំជនដែលបានឯកភាពគ្នា។

លទ្ធផលរំពឹងទុកនេះនឹងត្រូវដឹកនាំអនុវត្តដោយក្រសួងមហាផ្ទៃ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុកពាក់ព័ន្ធនានា។

**លទ្ធផលរំពឹងទុកទី ១១ ៖ ការពង្រឹង និងពង្រីកការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ក្រុង ស្រុកចំនួន៥បន្ថែមទៀត ព្រមទាំងការរៀបចំបង្កើតយន្តការច្រកចេញចូលតែមួយនៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ស្រុក និងឃុំ សង្កាត់។**

បច្ចុប្បន្ន ការិយាល័យច្រកចេញចូលតែមួយដែលបានបង្កើត និងកំពុងដំណើរការមានចំនួន៤០ ដែលនឹងទទួលបាននូវការគាំទ្រជាបន្តទៀត។ ក្នុងឆ្នាំ២០១៦ ការិយាល័យច្រកចេញចូលតែមួយនឹងត្រូវបានបង្កើត នៅថ្នាក់ស្រុកចំនួន៥ បន្ថែមទៀត ព្រមទាំងការបង្កើតយន្តការ ច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត។ ក្រៅពីនេះ ក៏នឹងមានការសិក្សា ដើម្បីកំណត់ពីលទ្ធភាពនៃការផ្ទេរមុខងារផ្តល់សេវាបន្ថែមទៀតពីក្រសួងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ លិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងកិច្ចការនេះនឹងត្រូវពិនិត្យ កែសម្រួល និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**លទ្ធផលរំពឹងទុកទី ១២ ៖ ការសម្របសម្រួលនូវបែបផែននៃភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងអង្គការសង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។**

ការបង្កើតភាពជាដៃគូមានសារសំខាន់ ក្នុងការពង្រឹងការអនុវត្តអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាការអភិវឌ្ឍសមត្ថភាព។ ក្នុងឆ្នាំ២០១៦ កិច្ចការជាអាទិភាពពាក់ព័ន្ធនឹងបញ្ហានេះ គឺការរៀបចំនូវយន្តការ និងគំរូនានា ដើម្បីសម្របសម្រួលបែបផែននានានៃភាពជាដៃគូ និងការពិភាក្សាជាមួយអង្គការសង្គមស៊ីវិល សភាពាណិជ្ជកម្មនិងអ្នកពាក់ព័ន្ធនានា។ ដូច្នេះ បែបផែននៃភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជននានាដែលមាននាពេលបច្ចុប្បន្ន នឹងត្រូវបានពិនិត្យមើលឡើងវិញ ដើម្បីកំណត់ពីចំណុចខ្លាំង និងចំណុចខ្សោយនៃបែបផែនទាំងនេះ សម្រាប់ជាមូលដ្ឋានក្នុងការកែលម្អកិច្ចសហប្រតិបត្តិការ និងការពង្រីកនូវបទពិសោធន៍ល្អៗ។

យន្តការ និងគំរូនានានៃបែបផែនភាពជាដៃគូដែលបានរៀបចំ នឹងត្រូវផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលនានា បន្ទាប់មកនឹងធ្វើការផ្សព្វផ្សាយតាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងតំណាងរបស់អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។

### ៤.៣. គម្រោងថវិកា

ថវិកាប៉ាន់ស្មានសរុបនៃសមិទ្ធផលរំពឹងទុកនេះសម្រាប់ឆ្នាំ២០១៦ មានចំនួនប្រមាណ២៩,២ លានដុល្លារអាមេរិក ដែលមានបរិយាយលម្អិតនៅតារាងទី១២ខាងក្រោម ៖

## តារាងទី១២ ៖ គម្រោងថវិកា និងប្រភពមូលនិធិសម្រាប់សមិទ្ធផលរំពឹងទុកទី៤ (គិតជាដុល្លារ)

| លទ្ធផលរំពឹងទុក | ថវិកាកញ្ចប់រួម | ដៃគូអភិវឌ្ឍន៍ផ្សេងទៀត | មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ (រាជរដ្ឋាភិបាល) | សរុប | សម្គាល់ |
|---|---|---|---|---|---|
| ១. ការកំណត់ និងការអនុវត្តមុខងារជាជម្រើសជាច្រើនផ្សេងទៀតដោយរដ្ឋបាលថ្នាក់ក្រោមជាតិ | 20,160 | 0 | 0 | 20,160 | |
| ២. ការលើកកម្ពស់ការផ្តល់សេវាសង្គម ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការអនុវត្តមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ | 0 | 11,335,956 | 0 | 11,335,956 | មូលនិធិគាំទ្រដោយ UNICEF, WB/CTPMCH, UNFPA, ADB/TS-PRSDP និង IFAD/ASPIRE |
| ៣. ការផ្ទេរមុខងារគ្រប់គ្រងការអប់រំបឋមសិក្សា ការអប់រំកុមារតូច និងការអប់រំក្រៅប្រព័ន្ធទៅឱ្យក្រុង ស្រុកទាំងអស់នៅក្នុងខេត្តគោលដៅចំនួនមួយ | 40,000 | 100,000 | 12,000,000 | 12,140,000 | ជំនួយបច្ចេកទេសគាំទ្រដោយ UNICEF មូលនិធិមានភ្ជាប់លក្ខខណ្ឌគាំទ្រដោយរាជរដ្ឋាភិបាល (តារាងទី៣ ទំព័រទី១១) |
| ៤. រដ្ឋបាលរាជធានី រដ្ឋបាលក្រុង ស្រុកទាំងអស់អនុវត្តនូវមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព | 40,000 | | 2,026,500 | 2,066,500 | មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌនឹងផ្តល់តាមរយៈក្រសួងបរិស្ថាន (តារាងទី៣ ទំព័រទី១១) |
| ៥. ការផ្ទេរមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ការត្រួត ពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល និងការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ក្នុងខេត្តគោលដៅចំនួនមួយ | 40,000 | 30,000 | 250,000 | 320,000 | ជំនួយបច្ចេកទេសគាំទ្រដោយ UNICEF មូលនិធិមានភ្ជាប់លក្ខខណ្ឌគាំទ្រដោយរាជរដ្ឋាភិបាល (តារាងទី៣ ទំព័រទី១១) |
| ៦. ការផ្ទេរមុខងារគាំពារសុខភាពបឋមទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន | 50,000 | 52,000 | 960,000 | 1,062,000 | ជំនួយបច្ចេកទេសគាំទ្រដោយ UNICEF មូលនិធិមានភ្ជាប់លក្ខខណ្ឌរបស់រាជរដ្ឋាភិបាល (តារាងទី៣ ទំព័រទី១១) |
| ៧. ការផ្ទេរមុខងារការថែទាំផ្លូវលំជនបទមានលក្ខណៈជាប្រចាំ | 30,000 | 0 | 850,000 | 880,000 | មូលនិធិមានភ្ជាប់លក្ខខណ្ឌរបស់រាជរដ្ឋាភិ |

| លទ្ធផលរំពឹងទុក | ថវិកាកញ្ចប់រួម | ដៃគូអភិវឌ្ឍន៍ផ្សេងទៀត | មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ (រាជរដ្ឋាភិបាល) | សរុប | សម្គាល់ |
|---|---|---|---|---|---|
| ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅមួយចំនួន | | | | | បាល (តារាងទី៣ ទំព័រទី១១) |
| ៨. ការបន្តគាំទ្រការអនុវត្តសាកល្បងនៃការផ្ទេរមុខងារគ្រប់គ្រងអនាម័យជនបទ និងការគ្រប់គ្រង ការថែទាំ និងការជួសជុលប្រព័ន្ធទឹកស្អាតទៅស្រុកមួយចំនួន | 40,000 | 225,000 | 62,500 | 327,500 | បដិភាគដោយ ADB/RWS, WB/WSP មូលនិធិមានភ្ជាប់លក្ខខណ្ឌគាំទ្រដោយរាជរដ្ឋាភិបាល |
| ៩. ការព្រមព្រៀងទៅលើមុខងារជាក់លាក់របស់ក្រសួង ស្ថាប័នមួយចំនួនបន្ថែមទៀត ដើម្បីផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅឆ្នាំ២០១៧ | 371,200 | 0 | 0 | 371,200 | |
| ១០. ការព្រមព្រៀងទៅលើមុខងារសេវាទីប្រជុំជនសមស្របមួយចំនួនរបស់រដ្ឋបាលខេត្ត ដើម្បីផ្ទេរទៅឱ្យរដ្ឋបាលក្រុងនៅឆ្នាំ២០១៧ | 17,900 | 0 | 0 | 17,900 | |
| ១១. ការពង្រឹង និងពង្រីកការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ក្រុង ស្រុក ចំនួន៥បន្ថែមទៀត ព្រមទាំងការរៀបចំបង្កើតយន្តការច្រកចេញចូលតែមួយនៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ស្រុក និងឃុំ សង្កាត់ | 161,765 | 0 | 500,000 | 661,765 | |
| ១២. ការសម្របសម្រួលនូវបែបផែននៃភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងអង្គការសង្គមស៊ីវិល និងផ្នែកឯកជនដើម្បីលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន | 0 | 0 | 0 | 0 | |
| **សរុប** | **811,025** | **11,742,956** | **16,649,000** | **29,202,981** | |

__*សម្គាល់*__ ៖ គម្រោង EU SPACE នឹងចូលរួមចំណែកមិនមែនជាថវិកា តាមរយៈការគាំទ្របច្ចេកទេសសម្រាប់ការងារនានាពាក់ព័ន្ធនឹងមុខងារជាជម្រើស ការផ្ទេរមុខងារក្នុងវិស័យអប់រំ សុខាភិបាល និងការិយាល័យច្រកចេញចូលតែមួយ ប៉ុន្តែថវិកាសរុបនៃការរួមចំណែកនេះបានដាក់បញ្ចូលក្នុងសមិទ្ធផលរំពឹងទុកទី១។

## ៥. សមិទ្ធផលរំពឹងទុកទី៥ ៖ វិមជ្ឈការហិរញ្ញវត្ថុ

### ៥.១. សេចក្តីផ្តើម និងចំណុចដៅ

ក្នុងឆ្នាំ២០១៦នេះ យន្តការនៃការផ្ទេរហិរញ្ញវត្ថុក្រៅពីមូលនិធិក្រុង ស្រុកនឹងត្រូវបានរៀបចំ និងអនុវត្ត ដើម្បីជួយគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលទ្ធភាពទទួលបាននូវប្រភពធនធានហិរញ្ញវត្ថុផ្សេងៗបន្ថែមទៀត រួមមានដូចជា មូលនិធិផ្ទេរដោយមានភ្ជាប់ល័ក្ខខ័ណ្ឌ មូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចការសំខាន់ៗ ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ រួមមានការពិនិត្យមើលឡើងវិញនូវប្រព័ន្ធកសាងផែនការ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កាត់បន្ថយភាពយឺតយ៉ាវក្នុងការផ្ទេរមូលនិធិ និងជួយឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួនមានលក្ខណៈប្រាកដប្រជា ព្រមទាំងមានគោលដៅច្បាស់លាស់ក្រោមការដឹកនាំ និងត្រួតពិនិត្យមើលដោយក្រុមប្រឹក្សា។

សមិទ្ធផលរំពឹងទុកដ៏សំខាន់ពាក់ព័ន្ធនឹងវិមជ្ឈការហិរញ្ញវត្ថុ ដែលត្រូវសម្រេចឱ្យបានគឺ **ធនធានហិរញ្ញវត្ថុ ត្រូវបានគ្រោងរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរ ព្រមទាំងមានចំនួនសមស្របសម្រាប់រដ្ឋបាលក្រុង ស្រុកក្នុងការអនុវត្តនូវអាណត្តិរបស់ខ្លួន។**

តារាងទី១៣ខាងក្រោមសង្ខេបអំពីសូចនាករ និងចំណុចដៅ ដែលកំណត់នៅក្នុងផអ៣ទី២។ ស្ថាប័នអនុវត្តទាំងអស់ទទួលខុសត្រូវក្នុងការសម្រេចឱ្យបានចំណុចដៅទាំងនេះ តាមរយៈការកំណត់នូវលទ្ធផលរំពឹងទុក និងសកម្មភាពនានាដែលពាក់ព័ន្ធនឹងសមិទ្ធផលរំពឹងទុកនេះ។ លទ្ធផលរំពឹងទុកនានាដែលត្រូវសម្រេច និងគម្រោងថវិកាមានចែងបន្ទាប់ពីតារាងនេះ។

**តារាងទី១៣ ៖ សូចនាករ និងចំណុចដៅសម្រាប់សមិទ្ធផលរំពឹងទុកទី៥**

| សូចនាករ និងចំណុចដៅ | 2016 |
|---|---|
| ១. ចំនួនភាគរយនៃធនធានសម្រាប់សមាសភាគអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុក ធៀបនឹងចំណូលចរន្តថវិការដ្ឋ | 0,5% |
| ២. ចំនួនភាគរយនៃចំណូលពីប្រភពនៅមូលដ្ឋានរបស់រដ្ឋបាលក្រុង ស្រុក ធៀបនឹងចំណូលសរុបរបស់ខ្លួន | 2,5% |
| ៣. ចំនួនធនធានដែលសហគមន៍មូលដ្ឋានបានចូលរួមសម្រាប់គម្រោងឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក (គិតជាលានដុល្លារអាមេរិក) | 0,5 |
| ៤. យន្តការផ្ទេរមូលនិធិមានភ្ជាប់លក្ខខណ្ឌ ដើម្បីធានាដល់ការអនុវត្តមុខងារដែលបានផ្ទេរ | គ្មាន |
| ៥. ចំនួនធនធានដែលបានផ្តល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគ (គិតជាលានដុល្លារអាមេរិក) | 3 |
| ៦. ចំនួនភាគរយនៃការកាត់បន្ថយនូវភាពយឺតយ៉ាវនៃការផ្ទេរធនធានពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោម (ក្របខណ្ឌពេលវេលា) | 25% |

| សូចនាករ និងចំណុចដៅ | 2016 |
|---|---|
| ៧. ចំនួនភាគរយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលបានប្រើប្រាស់ប្រព័ន្ធកសាងផែនការថ្មី | 100% |

<u>សម្គាល់</u> ៖ ការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពធៀបនឹងសូចនាករ និងចំណុចដៅទាំងនេះនឹងឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍ប្រចាំឆ្នាំ។

### ៥.២. លទ្ធផលរំពឹងទុក

ផ្អែកតាមផអ៣ទី២ សមិទ្ធផលរំពឹងទុកទី៥ស្តីពីវិមជ្ឈការហិរញ្ញវត្ថុមានលទ្ធផលរំពឹងទុកចំនួន៥ ហើយផ្អែកលើលទ្ធផលទាំងនេះ ត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ចំនួន៧ សម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ ដែលរួមមានដូចខាងក្រោម ៖

**លទ្ធផលរំពឹងទុកទី ១ ៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមូលនិធិក្រុង ស្រុកទាំងផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍ ព្រមទាំងការវិភាជថវិកាទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងមូលនិធិឃុំ សង្កាត់។**

ផអ៣ទី២មានគោលដៅជាអាទិភាពក្នុងការបង្កើនការវិភាជមូលនិធិក្រុង ស្រុកឱ្យបានពី០,៨ដល់ ១% ដោយកំណត់សមាសភាគអភិវឌ្ឍចំនួន០,៥% ធៀបនឹងចំណូលចរន្តនៃថវិការដ្ឋ។ ក្នុងឆ្នាំ២០១៦ ទោះបីពុំទាន់មានការគាំទ្រពីដៃគូអភិវឌ្ឍន៍ក៏ដោយ ក៏រាជរដ្ឋាភិបាលបានវិភាជមូលនិធិឱ្យក្រុង ស្រុកនីមួយៗសម្រាប់សមាសភាគអភិវឌ្ឍន៍ចំនួនជាមធ្យមប្រមាណ៣៣.៧២០ដុល្លារអាមេរិក។ អាស្រ័យហេតុនេះ មូលនិធិក្រុង ស្រុកសរុបក្នុងឆ្នាំ២០១៦សម្រាប់សមាសភាគអភិវឌ្ឍន៍មានចំនួនប្រមាណជាង ៦,២លានដុល្លារអាមេរិក ឬស្មើនឹង០,២៣%នៃចំណូលចរន្តថវិការដ្ឋប្រចាំឆ្នាំ។ ការអនុវត្តមូលនិធិក្រុង ស្រុកតម្រូវឱ្យមានការគាំទ្រ និងតាមដាន ត្រួតពិនិត្យឱ្យបានហ្មត់ចត់ ដើម្បីកែលម្អការផ្តល់ហិរញ្ញប្បទានសម្រាប់ឆ្នាំ២០១៧ឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាព។

ក្រៅពីនេះ ក្នុងឆ្នាំ២០១៦ ថវិការដ្ឋបានវិភាជសម្រាប់មូលនិធិឃុំ សង្កាត់មានចំនួន៧៦,២លានដុល្លារអាមេរិក មូលនិធិក្រុង ស្រុកមានចំនួន២៤,៥លានដុល្លារអាមេរិក និងថវិការាជធានី ខេត្តមានចំនួន២២៥,៨លានដុល្លារអាមេរិក។

លទ្ធផលរំពឹងទុកនេះនឹងទទួលខុសត្រូវអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**លទ្ធផលរំពឹងទុកទី ២ ៖ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវយន្តការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌ ដើម្បីគាំទ្រដល់ការផ្ទេរមុខងារ។**

ក្នុងឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌ ដែលបានផ្តល់ជាមូលដ្ឋានក្នុងការរៀបចំសេចក្តីណែនាំ និងនីតិវិធីនានាស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌ ដែលពាក់ព័ន្ធនឹងការផ្ទេរមុខងារ និងការគាំទ្រពីដៃគូអភិវឌ្ឍន៍។ នៅពេលដែលការិយាល័យជំនាញ និងមុខងារមួយចំនួនត្រូវបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក នោះនឹងតម្រូវឱ្យមានការពិនិត្យ និងកែសម្រួលប្រព័ន្ធ និងយន្តការនានារួមទាំងរូបមន្ត

នានាដែលមានស្រាប់ពាក់ព័ន្ធនឹងការផ្ទេរធនធាន ដើម្បីធានាសមធម៌ ប្រសិទ្ធភាព និងតម្លាភាពនៃការវិភាជ។ អាស្រ័យហេតុនេះ យន្តការ លិខិតបទដ្ឋាន និងសេចក្តីណែនាំពាក់ព័ន្ធនានាចាំបាច់ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនៅដើមឆ្នាំ២០១៦ ដើម្បីធានាដល់ការអនុវត្តនូវការផ្ទេរមុខងារ។ ការអនុវត្តកិច្ចការនេះក៏ទាមទារឱ្យមានការត្រួតពិនិត្យ តាមដាន និងការសិក្សាវាយតម្លៃជាប្រចាំ។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការផ្ទេរមុខងារ។

**លទ្ធផលរំពឹងទុកទី ៣ ៖ ការរៀបចំ និងអនុម័តគោលនយោបាយ និងលិខិតបទដ្ឋាននានាស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។**

ក្នុងឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបញ្ចប់ការវិភាគ និងការកំណត់ពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ បន្ទាប់មកនឹងធ្វើការសម្រេចអំពីប្រភពចំណូលនានាដែលមានលក្ខណៈសមស្របសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធចាំបាច់នានា (ដូចជា គោលនយោបាយ សេចក្តីណែនាំ។ល។) ដោយមានការពិភាក្សា និងប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធនានា។ អង្គការសង្គមស៊ីវិលនឹងត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការប្រឹក្សាយោបល់អំពីតម្លៃសេវា ដែលអ្នកប្រើប្រាស់សេវាត្រូវបង់ និងការចូលរួមបដិភាគរបស់មូលដ្ឋាន។ នៅពេលដែលការរៀបចំឯកសារទាំងនេះត្រូវបានបញ្ចប់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងរៀបចំការផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីកិច្ចដំណើរការនៃការប្រមូលចំណូល តាមរយៈវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**លទ្ធផលរំពឹងទុកទី ៤ ៖ ការរៀបចំ និងការអនុម័តនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាសម្រាប់ការរៀបចំ និងការអនុវត្តគម្រោងគាំទ្រដោយមូលនិធិវិនិយោគរបស់ថ្នាក់ក្រោមជាតិ ដើម្បីធានាការអនុវត្តនៅឆ្នាំ២០១៧ ។**

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៦ រួមមាន ៖

- ការរៀបចំ និងផ្សព្វផ្សាយនូវលិខិតបទដ្ឋាននានាក្នុងការប្រតិបត្តិមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការបង្កើតលេខាធិការដ្ឋានមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការសិក្សាវាយតម្លៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតលើលក្ខខណ្ឌអប្បបរមា និងការបំពេញការងារ ដើម្បីជាមូលដ្ឋានក្នុងការវិភាជថវិកាឱ្យក្រុង ស្រុកនីមួយៗ
- ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាអំពីមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានសេចក្តីណែនាំពាក់ព័ន្ធនានា។
- រដ្ឋបាលក្រុង ស្រុករៀបចំសំណើគម្រោង

- គណៈកម្មការនៃលេខាធិការដ្ឋានមូលនិធិវិនិយោគពិនិត្យ វាយតម្លៃ និងអនុម័តសំណើគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តក្នុងឆ្នាំ២០១៧។
- ការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍នានា សម្រាប់អនុវត្តមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**លទ្ធផលរំពឹងទុកទី ៥ ៖ ការពិនិត្យ និងការកែសម្រួលប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការផ្ទេរថវិកាឱ្យបានទាន់ពេលវេលា និងការអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព។**

ផ្អែកលើលទ្ធផលនៃការវិភាគ ការសិក្សា និងការពិភាក្សាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុវត្តកន្លងមកអំពីប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងពិនិត្យ និងកំណត់នូវចំណុចខ្វះខាត ព្រមទាំងបញ្ហានានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងនីតិវិធីអនុវត្តថវិកាដែលមាននាពេលបច្ចុប្បន្ន ដើម្បីធ្វើជាមូលដ្ឋានក្នុងការកែលម្អប្រព័ន្ធ និងនីតិវិធីទាំងនោះឱ្យកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ ការកែសម្រួលនេះនឹងផ្តល់ការយកចិត្តទុកដាក់លើការលើកកម្ពស់សេវាសង្គម ដោយពិនិត្យមើលបញ្ហានានាពាក់ព័ន្ធនឹងនីតិវិធីដូចជា ការកសាងផែនការ ការរៀបចំគម្រោងថវិកា និងការអនុវត្ត។ សំណូមពរ និងអនុសាសន៍នានានៃការពិនិត្យ និងកែសម្រួលនឹងយកមកពិភាក្សាជាមួយអ្នកពាក់ព័ន្ធនានា តាមរយៈកិច្ចប្រជុំ ឬសិក្ខាសាលា បន្ទាប់មកនឹងរៀបចំជាសេចក្តីណែនាំ ដើម្បីផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា សម្រាប់ការចាប់ផ្តើមអនុវត្តនៅឆ្នាំ២០១៧។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកទី ៦ ៖ ការពិនិត្យកែសម្រួល និងការដាក់ឱ្យអនុវត្តសេចក្តីណែនាំបច្ចេកទេសស្តីពីកិច្ចដំណើរការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលឆ្លុះបញ្ចាំងទៅនឹងចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ។**

ផ្អែកលើគោលនយោបាយស្តីពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានអនុម័តក្នុងឆ្នាំ២០១៤ ក្រសួងផែនការបានចាប់ផ្តើមពិនិត្យ និងកែសម្រួលសេចក្តីណែនាំស្តីពីការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឆ្នាំ២០១៥។ ដូចមានអធិប្បាយក្នុងផអ៣ទី១ និងផអ៣ទី២ សេចក្តីណែនាំបច្ចេកទេសស្តីពីកិច្ចដំណើរការកសាងផែនការ តាមប្រភេទផ្សេងគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ (១) បែងចែករវាងផែនការអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន (២) ជាផែនការដែលផ្អែកលើទិន្នន័យមូលដ្ឋាន មានលក្ខណៈសាមញ្ញ និងមានការវិភាគស្ថានភាពច្បាស់លាស់ (៣) មានការចូលរួម (៤) មានលក្ខណៈទូលំទូលាយដែលគ្របដណ្តប់ទាំងហេដ្ឋារចនាសម្ព័ន្ធ ការផ្តល់សេវាជាប្រចាំ ការរៀបចំ

លិខិតបទដ្ឋានគតិយុត្ត និងសកម្មភាពរដ្ឋបាល (៥) អាចត្រួតពិនិត្យបានដោយមានសូចនាករច្បាស់លាស់ (៦) ផ្អែកលើលទ្ធផលរំពឹងទុក (៧) មានការផ្សារភ្ជាប់យ៉ាងច្បាស់រវាងផែនការ និងថវិកា (៨) បញ្ចូលបញ្ហាបរិយាប័ន្ន និងសមធម៌សង្គម (៩) បញ្ចូលការប្រែប្រួលអាកាសធាតុ ការផ្តល់សេវាសង្គម គណនេយ្យភាពសង្គម និងការផ្តួចផ្តើមនានា និង (១០) កំណត់កិច្ចដំណើរការច្បាស់លាស់ដែលពាក់ព័ន្ធនឹងតួនាទីរបស់ក្រុមប្រឹក្សាដែលជាប់ឆ្នោត។

សេចក្តីណែនាំបច្ចេកទេសនៃការកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងបញ្ចូលផងដែរនូវឧបករណ៍ និងនីតិវិធីនានាសម្រាប់ការកសាងផែនការ បន្ទាប់មក សេចក្តីណែនាំនេះនឹងត្រូវធ្វើការផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពឱ្យបានទូលំទូលាយដល់អ្នកពាក់ព័ន្ធនានា។ នៅថ្នាក់ក្រោមជាតិ ការបណ្តុះបណ្តាលនឹងត្រូវធ្វើឡើង តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងផែនការ ដោយសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុកទី ៧ ៖ ការពង្រឹងការប្រើប្រាស់ទិន្នន័យនានាដែលបានធ្វើបច្ចុប្បន្នភាព សម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។**

លទ្ធផលរំពឹងទុកនេះពាក់ព័ន្ធនឹងការប្រមូល ការរៀបចំ ការផលិត និងការផ្សព្វផ្សាយទិន្នន័យមូលដ្ឋានថ្នាក់ក្រោមជាតិ ការរៀបចំតារាងពិន្ទុគោលដៅសហសវត្ស និងវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីការប្រើប្រាស់ប្រព័ន្ធទិន្នន័យគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (SPD)។ ការអនុវត្ត និងការប្រើប្រាស់នូវប្រព័ន្ធទាំងនេះនឹងត្រូវពិនិត្យឡើងវិញ និងកែសម្រួលជាប្រចាំ។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយក្រសួងផែនការ។

### ៥.៣. គម្រោងថវិកា

ក្នុងឆ្នាំ២០១៦ ថវិកាប៉ាន់ស្មានសរុបសម្រាប់សមិទ្ធផលរំពឹងទុកនេះមានចំនួនប្រមាណ៣២៨,២ លានដុល្លារអាមេរិក ដូចមានបរិយាយតាមលទ្ធផលរំពឹងទុកដូចខាងក្រោម ៖

**តារាងទី១៤៖ គម្រោងថវិកា និងប្រភពមូលនិធិសម្រាប់សមិទ្ធផលរំពឹងទុកទី៥ (គិតជាដុល្លារ)**

| | លទ្ធផលរំពឹងទុក | កញ្ចប់រួម | ផ្សេងៗ | សរុប | សម្គាល់ |
|---|---|---|---|---|---|
| ១. | ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមូលនិធិក្រុង ស្រុកទាំងផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍ ព្រមទាំងការវិភាជថវិកាទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងមូលនិធិឃុំ សង្កាត់ | 0 | 326,470,000 | 326,470,000 | (1) |
| ២. | ការរៀបចំ និងដាក់ឱ្យអនុវត្តយន្តការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ ដើម្បីគាំទ្រដល់ការផ្ទេរមុខងារ | 0 | 537,820 | 537,820 | (2) |

| លទ្ធផលរំពឹងទុក | | កញ្ចប់រួម | ផ្សេងៗ | សរុប | សម្គាល់ |
|---|---|---|---|---|---|
| ៣. | ការរៀបចំ និងការអនុម័តគោលនយោបាយ និងលិខិតបទដ្ឋាននានាស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 0 | 59,600 | 59,600 | (2) |
| ៤. | ការរៀបចំ និងការអនុម័តលិខិតបទដ្ឋាន និងសេចក្តីណែនាំនានា សម្រាប់ការរៀបចំ និងការអនុវត្តគម្រោងគាំទ្រដោយមូលនិធិវិនិយោគរបស់ថ្នាក់ក្រោមជាតិ ដើម្បីធានាការអនុវត្តនៅឆ្នាំ២០១៧ | 0 | 342,920 | 342,920 | (2) |
| ៥. | ការពិនិត្យ និងការកែសម្រួលប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការផ្ទេរថវិកាបានទាន់ពេលវេលា និងការអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព | | | | (3) |
| ៦. | ការពិនិត្យកែសម្រួល និងការដាក់ឱ្យអនុវត្តសេចក្តីណែនាំបច្ចេកទេសស្តីពីកិច្ចដំណើរការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលឆ្លុះបញ្ចាំងទៅនឹងចរិកលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ | 110,000 | 400,000 | 510,000 | |
| ៧. | ការពង្រឹងការប្រើប្រាស់ទិន្នន័យនានាដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 16,920 | 0 | 16,920 | |
| **សរុប** | | **343,310** | **327,810,340** | **328,153,650** | |

សម្គាល់ ៖ (1) ជាមូលនិធិឃុំ សង្កាត់ មូលនិធិក្រុង ស្រុក និងថវិការាជធានី ខេត្ត (2) គាំទ្រមូលនិធិដោយ ADB/DPSFM (3) គាំទ្រមូលនិធិដោយ ADB/PPTA។

# ឧបសម្ព័ន្ធនានា

# ឧបសម្ព័ន្ធទី១ ៖ សុន្ទរកថាបើកសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦របស់ គ.ជ.អ.ប ដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាអនុប្រធាន គ.ជ.អ.ប

- ឯកឧត្តម លោកជំទាវ សមាជិក សមាជិការាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- ឯកឧត្តមប្រធានក្រុមប្រឹក្សា និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល
- ឯកឧត្តម លោកជំទាវ អស់លោក និងលោកស្រី

១. ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយនិងកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានមកចូលរួមជាអធិបតីក្នុងពិធីបើក **សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ របស់ គ.ជ.អ.ប** ជាមួយឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់នាពេលនេះ។ ក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវគារវកិច្ច និងស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានចំណាយពេលវេលា ដ៏មានតម្លៃដើម្បីអញ្ជើញចូលរួម**សិក្ខាសាលាជាតិ**ដែលនឹងប្រព្រឹត្តទៅរយៈពេលពីរថ្ងៃនេះ។

២. សិក្ខាសាលាជាតិនេះ គឺជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីធ្វើការឆ្លុះបញ្ចាំងនូវវឌ្ឍនភាព និងបញ្ហាប្រឈមនានានៃការអនុវត្តផែនការ សកម្មភាពនិងថវិកាឆ្នាំ២០១៥ របស់គ.ជ.អ.ប និងផ្តល់ឱកាសឱ្យមានការពិភាក្សាពិគ្រោះយោបល់ក្នុងចំណោមតួអង្គពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ដើម្បីស្វែងរកដំណោះស្រាយដែលត្រូវផ្តោតការយកចិត្តទុកដាក់អនុវត្តនៅក្នុងឆ្នាំ ២០១៦ និងការឯកភាពគ្នាលើសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ របស់ គ.ជ.អ.ប ដើម្បីឈានទៅរៀបចំបញ្ចប់ និងដាក់ជូន គ.ជ.អ.ប ពិនិត្យនិងសម្រេចក្នុងពេលឆាប់ៗខាងមុខនេះ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !**

៣. ការអនុវត្ត ផែនការអនុវត្តរយៈពេល៣ឆ្នាំ ដំណាក់កាលដំបូងនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ផអ៣ទី១) ត្រូវបានបញ្ចប់នៅចុងឆ្នាំ២០១៤ ប្រកបដោយជោគជ័យ។ ចំពោះ ផែនការអនុវត្តរយៈពេល៣ឆ្នាំ ដំណាក់កាលទី២ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ផអ៣ទី២) ដែលបានចាប់ផ្តើមអនុវត្តពីឆ្នាំ២០១៥នេះ រហូតដល់ឆ្នាំ

២០១៧ គឺជាដំណាក់កាលដែលត្រូវផ្តោតជាសំខាន់ទៅលើការផ្ទេរមុខងារ ការផ្ទេរធនធានហិរញ្ញវត្ថុ និងការផ្ទេរធនធានបុគ្គលិកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤. ខ្ញុំជឿជាក់ថា ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីដែលមានវត្តមាននៅក្នុងសិក្ខាសាលាជាតិរបស់យើងនាថ្ងៃនេះ សុទ្ធតែមានការយល់ដឹងអំពីគោលបំណងលទ្ធផលរំពឹងទុកនិងយុទ្ធសាស្ត្រនានាដែលបានកំណត់នៅក្នុង **ផអ៣ទី២** ។ ជាមួយគ្នានេះដែរ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីក៏បានចូលរួម និងគាំទ្រយ៉ាងសកម្មក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ របស់ គ.ជ.អ.ប ដែលជាឆ្នាំទី១នៃការអនុវត្ត **ផអ៣ទី២** ផងដែរ។ ដើម្បីធានាដល់ការបន្តទទួលបាននូវជោគជ័យថ្មីៗបន្ថែមទៀតនៃកម្មវិធីកំណែទម្រង់ ខ្ញុំសូមស្នើឱ្យការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ របស់ គ.ជ.អ.ប ដែលជាប្រធានបទនៃសិក្ខាសាលាជាតិរបស់យើងនាពេលនេះ ត្រូវផ្អែកជាសំខាន់ទៅលើលទ្ធផលរំពឹងទុក និងយុទ្ធសាស្ត្រនានាដែលបានកំណត់ក្នុង**ផអ៣ទី២** ព្រមទាំងត្រូវផ្តោតជាចាំបាច់ផងដែរទៅលើមេរៀន បទពិសោធន៍ និងបញ្ហាប្រឈមជាគន្លឹះនានាដែលបានជួបប្រទះ ក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ ២០១៥ របស់ គ.ជ.អ.ប នាពេលកន្លងមក។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

៥. ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះខ្ញុំសូមជម្រាបជូនអង្គសិក្ខាសាលាជ្រាបថា រាជរដ្ឋាភិបាលបាននិងកំពុងរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP3) នៃកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលគ្រោងនឹងដាក់អនុវត្តនៅខែមករា ឆ្នាំ២០១៦ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ដោយឡែក ផែនការសកម្មភាពជាគន្លឹះសម្រាប់គាំទ្រដល់កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលបានរំលេចនៅក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ។

៦. ជារួម គោលបំណងសំខាន់នៃវិមជ្ឈការហិរញ្ញវត្ថុ ដែលជាផ្នែកមួយសំខាន់នៃផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP3) នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការទទួល និងកៀរគរបាននូវធនធានសមស្របសម្រាប់បំពេញមុខងារដែលជាការទទួលខុសត្រូវរបស់ខ្លួន។ ធនធានទាំងនោះ ត្រូវប្រើប្រាស់តាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុដែលធានាដល់ការលើកកម្ពស់ស្វ័យភាព ការទទួលខុសត្រូវប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងកាត់បន្ថយនូវការិយាធិបតេយ្យ។

៧. លើសពីនេះទៅទៀត កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានចេញនូវសារាចរលេខ ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាននិងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលបំណងពង្រឹង ជំរុញ និងលើកទឹកចិត្តដល់គ្រប់ក្រសួង ស្ថាប័ន បន្តអនុវត្តនូវកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ខ្ញុំជឿជាក់

ថា សារាចរនេះនឹងក្លាយទៅជាឧបករណ៍គតិយុត្តថ្មីមួយទៀត ក្នុងការលើកកម្ពស់ការចូលរួមរបស់ក្រសួង ស្ថាប័នទាំងអស់។

៨. ផ្អែកតាមការប៉ាន់ស្មាន យើងអាចមានធនធានសរុបប្រមាណ**៣៥៩,២ លានដុល្លារ USD** ក្នុងការរៀបចំផែនការសកម្មភាពនិងថវិកាឆ្នាំ២០១៦ របស់ គ.ជ.អ.ប ដែលក្នុងនោះមានថវិកា រដ្ឋចំនួនប្រមាណ **៣២៦,៥ លានដុល្លារ USD** និង ថវិកាចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ចំនួន ប្រមាណ **៣២,៧ លានដុល្លារ USD**។

៩. ក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងនាម គ.ជ.អ.ប ខ្ញុំសូមផ្តល់គោលការណ៍ណែនាំ តម្រង់ទិសជូនអង្គសិក្ខាសាលាជាតិ ដោយផ្តោតជាសំខាន់ទៅលើការងារអាទិភាពមួយចំនួនដូចខាងក្រោម៖

**ទី១. អំពីថវិកាវាជធានីខេត្ត**

១០. ការបែងចែកថវិកាប្រចាំឆ្នាំដល់រាជធានី ខេត្តទាំងអស់ ធ្វើឡើងតាមរូបមន្តដែលយកលំនាំ តាមប៉ារ៉ាម៉ែត្ររបស់ក្រុង ស្រុក ក្នុងកម្រិត ០,៩៦% នៃចំណូលចរន្តថវិការដ្ឋ ។ ថវិការាជធានី ខេត្ត ឆ្នាំ២០១៦ មានចំនួន **៩១៤ ៦៣៥** លានរៀល ឬប្រមាណ **២២៥,៨៤** លានដុល្លារ USD។ កំណើនថវិការាជធានី ខេត្ត ឆ្នាំ២០១៦ មានចំនួនប្រមាណ ២១,៣១% ធៀបនឹងថវិកា ឆ្នាំ២០១៥។

**ទី២. មូលនិធិក្រុង ស្រុក**

១១. ការរៀបចំបង្កើត និងការដាក់ឱ្យអនុវត្តនូវមូលនិធិក្រុង ស្រុក និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក គឺជាសមិទ្ធផលដ៏គួរឱ្យកត់សម្គាល់មួយក្នុងចំណោមសមិទ្ធផលធំៗ ជាច្រើន ផ្សេងទៀតដែលសម្រេចបាននៅក្នុងអំឡុងពេល **ផអ៣ទី១**។ ទោះជាយ៉ាងនេះក្តី យើងទទួលស្គាល់ថាមូលនិធិក្រុងស្រុកនេះ នៅមានចំនួនតិចតួចនៅឡើយហើយរដ្ឋបាលក្រុង ស្រុក ក៏កំពុងប្រើប្រាស់មូលនិធិទាំងនេះ ភាគច្រើនសម្រាប់រ៉ាប់រងទៅលើប្រាក់ឧបត្ថម្ភក្រុមប្រឹក្សា ប្រាក់បៀវត្សមន្ត្រី និងកិច្ចការរដ្ឋបាល ដោយមានថវិកាសេសសល់តិចតួចប៉ុណ្ណោះសម្រាប់ គាំទ្រដល់ការរៀបចំនិងអនុវត្តគម្រោងអភិវឌ្ឍមូលដ្ឋាន។ អាស្រ័យហេតុនេះ នៅចុងឆ្នាំ២០១៤ កន្លងទៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ដោយបង្កើនកម្រិតសមាមាត្រនៃមូលនិធិនេះធៀបទៅនឹងចំណូលចរន្តថវិកាជាតិសរុបពី **០,៨០%** សម្រាប់ឆ្នាំ២០១៥ ទៅ **០,៩០%** សម្រាប់ឆ្នាំ២០១៦ និងទៅដល់ **១%** សម្រាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩។ ផ្អែកតាមស្មារតីនៃអនុក្រឹត្យនេះ មូលនិធិក្រុង ស្រុកនឹងមានចំនួនកើនឡើងពីចំនួន **១៩,២ លានដុល្លារ USD** នៅក្នុងឆ្នាំ២០១៥ ដល់ចំនួន **២៤,៥ លានដុល្លារ USD** សម្រាប់ឆ្នាំ២០១៦ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់យ៉ាងជាក់លាក់នូវចំនួនមូលនិធិសម្រាប់សមាសភាគរដ្ឋបាល និងសមាសភាគសម្រាប់គាំទ្រដល់កិច្ចអភិវឌ្ឍន៍មូលដ្ឋាន។ ពាក់ព័ន្ធនឹងកិច្ចការនេះ ក្នុងនាម គ.ជ.អ.ប ខ្ញុំសូមស្នើឱ្យក្រុមប្រឹក្សាក្រុង ស្រុកនីមួយៗផ្តោតការយកចិត្តទុកដាក់ក្នុងការធានាថា មូលនិធិក្រុង ស្រុករបស់ខ្លួន ត្រូវបានប្រើប្រាស់សម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានយ៉ាងមានប្រសិទ្ធភាព និងយ៉ាងត្រឹមត្រូវតាមនីតិវិធីដែលបានកំណត់។ ខ្ញុំក៏សូមស្នើមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋបាលរាជធានី ខេត្តរួមគ្នាបន្តគាំទ្រ និងផ្តល់អន្តរាគមន៍ក្នុងករណីចាំបាច់

ដល់រដ្ឋបាលក្រុង ស្រុកលើការអនុវត្តមូលនិធិក្រុងស្រុកឱ្យកាន់តែមានប្រសិទ្ធភាព។

**ទី៣. អំពីមូលនិធិឃុំ សង្កាត់**

១២. មូលនិធិឃុំសង្កាត់ គឺជាមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ដែលមានចំនួនសមាមាត្រ ២,៨០% ធៀបទៅនឹងចំណូលចរន្តថវិកាជាតិសរុប ។ មូលនិធិនេះត្រូវបានកើនឡើងយ៉ាងខ្លាំង នៅក្នុងរយៈពេលជាង ១០ ឆ្នាំកន្លងមកនេះ ។ នៅក្នុងឆ្នាំ២០១៦ មូលនិធិឃុំ សង្កាត់នេះ មាន ចំនួនប្រមាណ **៣០៨ ៤១០ លានរៀល**ឬសមមូលនឹង **៧៦,១៥ លានដុល្លារ USD** ដែលចំនួននេះមានការកើនឡើង **១៣,៥%** បើប្រៀបធៀបទៅនឹងទំហំមូលនិធិឃុំ សង្កាត់ក្នុងឆ្នាំ២០១៥។ ជាទូទៅ ក្នុងការអនុវត្តជាក់ស្តែង ឃុំ សង្កាត់បានប្រើប្រាស់មូលនិធិនេះភាគច្រើន ផ្តោតតែទៅលើគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋាននានា។ ក្នុងដំណាក់កាលនេះ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវរបស់ឃុំ សង្កាត់ក្នុងការចូលរួមចំណែកទាំងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម, ក្រុមប្រឹក្សាឃុំ សង្កាត់ គប្បីពិចារណាប្រើប្រាស់មូលនិធិនេះមួយចំណែកសម្រាប់សកម្មភាពនានា ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសង្គមជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានរបស់ខ្លួន។

**ទី៤. ការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ**

១៣. មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ គឺជាប្រភពធនធានដ៏មានសារៈសំខាន់មួយទៀតសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាទូទៅ មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ គឺពាក់ព័ន្ធទៅនឹង ការផ្ទេរមុខងារជាក់លាក់មួយចំនួនដែលធ្លាប់បានអនុវត្តដោយក្រសួង ស្ថាប័នទៅឱ្យរដ្ឋបាល ថ្នាក់ក្រោមជាតិ។ ជាការពិតណាស់ នៅពេលដែលមុខងារទាំងនេះត្រូវបានផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ នោះចាំបាច់ត្រូវតែមានការផ្ទេរធនធាន ទាំងធនធានហិរញ្ញវត្ថុ ទាំងធនធានមនុស្សសម្រាប់អនុវត្តមុខងារទាំងនោះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ នៅក្នុងយន្តការនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រើប្រាស់ធនធានទាំងនោះសម្រាប់តែការគ្រប់គ្រងចាត់ចែង និងអនុវត្តនូវមុខងារដែលបានផ្ទេរទាំងនោះប៉ុណ្ណោះ។

១៤. ពាក់ព័ន្ធនឹងកិច្ចការនេះ ខ្ញុំសូមគូសបញ្ជាក់ជាថ្មីឡើងវិញថា **ផអ៣ទី២**បានផ្តោតទៅលើការផ្ទេរមុខងារដែលក្នុងនោះ មុខងារជាក់លាក់របស់ក្រសួង ស្ថាប័នក្នុងវិស័យអាទិភាពមួយចំនួននឹងត្រូវបានចាប់ផ្តើមផ្ទេរជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងក្នុងបែបផែននៃការផ្ទេរដោយសាកល្បង និងក្នុងបែបផែននៃការផ្ទេរជាលក្ខណៈអចិន្ត្រៃយ៍ចាប់ពីឆ្នាំ២០១៦នេះតទៅ។ ក្នុងន័យនេះ ដើម្បីគាំទ្រនិងបង្កលក្ខណៈងាយស្រួលដល់កិច្ចដំណើរការ ផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ខ្ញុំសូមស្នើក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវខិតខំសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីបន្តធ្វើការសិក្សា រៀបចំនិងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានចាំបាច់នានាពាក់ព័ន្ធនឹងការបង្កើតប្រព័ន្ធ និងយន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌនេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ជាក់ស្តែង ក្នុងឆ្នាំ២០១៥នេះ ក្រសួងបរិស្ថានក៏បានសាកល្បងផ្ទេរនូវមុខងារគ្រប់គ្រងសេវាអនាម័យបរិស្ថានតាមទីប្រជុំជន ឱ្យទៅរដ្ឋបាលក្រុងគោល

ដៅទាំង២៦។ ទន្ទឹមគ្នានេះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុងទាំងនេះ ដើម្បីអនុវត្តមុខងារខាងលើ។

**ទី៥. អនុវត្តសាកល្បង និងពង្រីកមូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ**

១៥. ការបង្កើតយន្តការនេះ មានគោលបំណងផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបាននូវធនធានបន្ថែមសម្រាប់អនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានចាំបាច់មួយចំនួន ដែលរដ្ឋបាលថ្នាក់ក្រោមជាតិពុំមានលទ្ធភាពប្រើប្រាស់នូវមូលនិធិរបស់ខ្លួន ។ យន្តការនេះក៏បង្កលក្ខណៈដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការប្រើប្រាស់មូលនិធិរបស់ខ្លួនសម្រាប់ផ្តោតទៅលើការពង្រឹងអភិបាលកិច្ចការផ្តល់សេវាសង្គម និងសេវាគាំទ្រដល់ក្រុមជនងាយរងគ្រោះនិងអ្នកក្រីក្រនៅក្នុងមូលដ្ឋានរបស់ខ្លួន។

១៦. ពាក់ព័ន្ធនឹងកិច្ចការនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធបានរៀបចំរួចរាល់នូវសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីធានាឱ្យយន្តការនេះអាចចាប់ផ្តើមដំណើរការ បានពេញលេញពីឆ្នាំ២០១៦ នេះតទៅ ខ្ញុំសូមស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបន្តការខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនានា សម្រាប់ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ អនុម័ត និងដាក់ឱ្យអនុវត្តឲ្យបានទាន់ពេល។

**ទី៦. អំពីការរៀបចំ និងអនុវត្តប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

១៧. ការរៀបចំបង្កើតចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាសមាសធាតុដ៏សំខាន់មួយនៃវិមជ្ឈការហិរញ្ញវត្ថុ។ ចំណូលផ្ទាល់នៅមូលដ្ឋាន អាចបានមកពីចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ក្នុងអំឡុង **ផអ៣ទី១** ការសិក្សាអំពីជម្រើសនានាសម្រាប់ការរៀបចំបង្កើតចំណូលផ្ទាល់នៅមូលដ្ឋានត្រូវបានរៀបចំរួចរាល់ហើយ។ ក្នុងឆ្នាំ២០១៥ នេះ ក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានពិនិត្យ និងពិភាក្សាជាច្រើនលើក ច្រើនសារក្នុងកម្រិតបច្ចេកទេសទៅលើជម្រើសនានាទាំងនោះ។ អាស្រ័យហេតុនេះ ខ្ញុំសូម ស្នើឱ្យក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្តជំរុញកិច្ចការដែលនៅសេសសល់ ទាំងនេះ ដោយត្រូវចាត់ទុកកិច្ចការនេះជាអាទិភាពមួយនៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ របស់ខ្លួន ដើម្បីធានាដល់ការសម្រេចបានតាមយុទ្ធសាស្ត្រ និងចំណុចដៅនៃលទ្ធផលរំពឹងទុកដែលបានកំណត់ក្នុង**ផអ៣ទី២**។

**ទី៧. ការៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកាកម្មវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ**

១៨. ផែនការយុទ្ធសាស្ត្រថវិកានិងថវិកាកម្មវិធីនឹងត្រូវរៀបចំ និងដាក់ឱ្យអនុវត្តស្របតាមទិសដៅនៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា (២០១៣-២០២០)។ ទាំងនេះ គឺការផ្លាស់ប្តូរជាបណ្តើរៗពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាដែលផ្អែកលើធាតុចូល និងមជ្ឈការឆ្ពោះទៅកាន់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាដែលផ្អែកលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ។ ខ្ញុំក៏សូមបញ្ជាក់បន្ថែមថា ចាប់ពីឆ្នាំ២០១៧ តទៅ រដ្ឋបាលរាជធានី ខេត្តមួយចំនួនត្រូវបានជ្រើសរើស ដើម្បីចាប់

ផ្ដើមអនុវត្តថវិកាកម្មវិធី និងពង្រីកជាបណ្ដើរៗរហូតដល់ឆ្នាំ២០២០ គឺគ្រប់រដ្ឋបាលរាជធានី ខេត្តទាំងអស់ត្រូវអនុវត្តថវិកាកម្មវិធី។ អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវយកចិត្តទុកដាក់ក្នុងការបណ្ដុះបណ្ដាលដល់រដ្ឋបាលរាជធានី ខេត្ត ដែលត្រូវចាប់ផ្ដើមមុនគេ ចំណែកឯ គ.ជ.អ.ប. និងបណ្ដារដ្ឋបាលរាជធានី ខេត្ត ដែលពាក់ព័ន្ធក៏ត្រូវចូលរួមសហការឲ្យបានពេញលេញជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសម្រេចបាននូវគោលដៅកំណែទម្រង់ប្រព័ន្ធថវិការបស់រាជរដ្ឋាភិបាល។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

១៩. មុននឹងបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាល និង គ.ជ.អ.ប ខ្ញុំសូមស្នើឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ ផ្ដោតការយកចិត្តទុកដាក់ក្នុងការចូលរួមពិនិត្យ ពិភាក្សាលើបញ្ហានានា និងផ្ដល់ជាធាតុចូលទាំងឡាយទៅក្នុងការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ២០១៦ របស់ គ.ជ.អ.ប ដើម្បីធានាបាននូវផែនការដ៏លម្អិតមួយដែលមានភាពប្រាកដប្រជា និងធានាបាននូវភាពជាម្ចាស់របស់ស្ថាប័នព្រមទាំងអាចអនុវត្តបានប្រកបដោយជោគជ័យ។

២០. ខ្ញុំក៏សូមឆ្លៀតឱកាសនេះ សម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍ដែលបាន និងកំពុងបន្តគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់កិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះ។ យើងខ្ញុំនឹងខិតខំបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីសម្រេចបាននូវគោលដៅ ជាគន្លឹះនៃកិច្ចដំណើរការកែទម្រង់របស់យើងទៅអនាគត។

២១. ជាថ្មីម្ដងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលបានចូលរួមនៅក្នុងកិច្ចដំណើរការនានានៃការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ ២០១៦ របស់ គ.ជ.អ.ប តាំងពីដំណាក់កាលដំបូងរហូតឈានមកដល់ ការរៀបចំសិក្ខាសាលាជាតិនាពេលនេះ ហើយខ្ញុំជឿជាក់យ៉ាងមុតមាំថា សិក្ខាសាលាជាតិនេះ នឹងប្រព្រឹត្តទៅតាមកម្មវិធីនិងទទួលបានលទ្ធផលជាផ្លែផ្កាតាមគោលដៅដែលបានគ្រោងទុក។

២២. ជាមួយនេះ ខ្ញុំសូមប្រសិទ្ធពរបវរមហាប្រសើរជូនចំពោះឯកឧត្តម លោកជំទាវ អស់លោកលោកស្រីទាំងអស់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ សិរីមង្គល វិបុលភាព ជាតិយោ្យាភាព និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចតាមមុខសញ្ញារៀងៗខ្លួន ដែល**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាប្រគល់ជូន។ ខ្ញុំ រួមជាមួយគណៈអធិបតី និងអង្គពិធីទាំងមូល សូមប្រកាសបើក **សិក្ខាសាលាជាតិស្ដីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ ២០១៦ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**

## ឧបសម្ព័ន្ធទី២ ៖ សុន្ទរកថាបិទសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និង ថវិកាឆ្នាំ២០១៦របស់ គ.ជ.អ.ប ដោយសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

- **ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ សមាជិក សមាជិកានៃ គ.ជ.អ.ប**
- **ឯកឧត្តមប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្ត**
- **លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីសមាជិក សមាជិកាអង្គសិក្ខាសាលា**

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានមកចូលរួមពិធីបិទសិក្ខាសាលាជាតិស្តីពី**ការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ របស់ គ.ជ.អ.ប** ដែលបានប្រព្រឹត្តទៅអស់រយៈពេលពីរថ្ងៃកន្លងមកនេះ។ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានខិតខំប្រឹងប្រែងចូលរួមចំណែកក្នុងការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៦នេះ បើទោះបីជាក្នុងរយៈពេលជិត១ឆ្នាំកន្លងមកនេះ យើងទាំងអស់គ្នាមានការមមាញឹកបំផុតក្នុងការជំរុញ ការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ក៏ដោយ។ ពាក់ព័ន្ធនឹងកិច្ចការនេះ ខ្ញុំសូម អរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍នានាដែលបានបន្តគាំទ្រទាំងផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុដល់កិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះ។ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះអង្គការសង្គមស៊ីវិលនានា ដែលបានចូលរួមចំណែក និងផ្តល់ការគាំទ្រ នៅក្នុងកិច្ចការសំខាន់ៗមួយចំនួននៃកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។ ជាទូទៅ ការរួមសហការគ្នារវាងអ្នកពាក់ព័ន្ធទាំងអស់ គឺជាមធ្យោបាយដ៏ល្អប្រសើរតែមួយគត់ ដែលអាចធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការលើកកម្ពស់ការទទួលខុសត្រូវ និងពង្រឹងនូវសមត្ថភាពរបស់ខ្លួន សំដៅធានាការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ឆ្នាំនេះ យើងសម្រេចបានសមិទ្ធផលធំៗជាច្រើនបន្ថែមទៀតនៅក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ យើងបានបោះជំហានដោយជោគជ័យពីការបញ្ចប់នូវផែនការអនុវត្តដំណាក់កាលទី១នៃកម្មវិធីជាតិ ឬហៅកាត់ថា **ផអ៣ទី១** ដែលផ្តោតទៅលើការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំនូវកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្ពោះមកការអនុវត្តផែនការអនុវត្តរយៈពេល៣ឆ្នាំដំណាក់កាលទី២ ឬហៅកាត់ថា **ផអ៣ទី២** ដែលផ្តោតជាសំខាន់ទៅលើការផ្ទេរមុខងារ និងធន

ធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសំដៅបង្កិតសេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានឱ្យទៅកៀកជិតប្រជាពលរដ្ឋ និងដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

ឆ្នាំ២០១៥ដែលជាឆ្នាំទី១នៃ**ផអ៣ទី២** ក្រសួង ស្ថាប័នមួយចំនួនបានធ្វើការសម្រេចចិត្តគួរឱ្យកោតសរសើរក្នុងការផ្ទេរនូវមុខងារជាក់លាក់ និងចាំបាច់មួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងក្នុងបែបផែនជាការធ្វើប្រតិភូកម្ម និងការប្រគល់។ នាពេលថ្មីៗកន្លងមកនេះ ផ្អែកតាមសំណើរបស់ក្រសួងបរិស្ថាន រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជនក្នុងគោលបំណងផ្ទេរនូវមុខងារគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជននេះទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកទាំងអស់នៅទូទាំងប្រទេស។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក៏បានធ្វើប្រតិភូកម្មជាបណ្តើរៗនូវមុខងារគ្រប់គ្រង និងតាមដានត្រួតពិនិត្យមណ្ឌលថែទាំកុមារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន។ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល ក៏បានអនុវត្តសាកល្បងនូវការធ្វើប្រតិភូកម្មមុខងារថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ មុខងារផ្តល់សេវាអនាម័យជនបទ និងមុខងារគ្រប់គ្រងមណ្ឌលសុខភាពទៅឱ្យរដ្ឋបាលស្រុកគោលដៅមួយចំនួនផងដែរ។ ផ្អែកលើបទពិសោធន៍នៃការអនុវត្តសាកល្បងនេះ ក្រសួងទាំងពីរក៏បាន និងកំពុងពិនិត្យពិចារណាទៅលើជម្រើសនានា ដើម្បីឈានទៅធ្វើការសម្រេចចិត្តក្នុងការផ្ទេរជាបណ្តើរៗនូវ មុខងារថែទាំ ជួសជុលផ្លូវលំជនបទ និងមុខងារគ្រប់គ្រងការិយាល័យស្រុកប្រតិបត្តិសុខាភិបាលឱ្យទៅរដ្ឋបាលក្រុង ស្រុក។ ក្រសួងអប់រំ យុវជន និងកីឡាក៏បានធ្វើការសម្រេចចិត្តក្នុងការផ្ទេរមុខងារគ្រប់គ្រងការអប់រំកម្រិតបឋមសិក្សា ការអប់រំកុមារតូច និងការអប់រំក្រៅប្រព័ន្ធទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ លើសពីនេះ ក្រសួង ស្ថាប័នមួយចំនួនដែលស្ថិតក្នុងវិស័យអាទិភាពផ្សេងទៀត ក៏បាន និងកំពុងខិតខំប្រឹងប្រែងជំរុញកិច្ចដំណើរការវិភាគ និងការពិនិត្យមើលឡើងវិញនូវមុខងាររបស់ខ្លួន ដើម្បីឈានទៅកំណត់នូវមុខងារជាក់លាក់នានាសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងបណ្តាឆ្នាំខាងមុខផងដែរ។

ជាគោលការណ៍ ការផ្ទេរមុខងារចាំបាច់ត្រូវភ្ជាប់ជាមួយនឹងធនធាន ដែលរួមមានទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានស្វ័យភាពក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរឱ្យទាំងនោះប្រកបដោយប្រសិទ្ធភាព។ ឆ្លើយតបទៅនឹងគោលការណ៍នេះ ក្នុងឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធបានសាកល្បងផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកមួយចំនួនសម្រាប់អនុវត្តមុខងារពាក់ព័ន្ធនឹងការផ្តល់សេវាអនាម័យបរិស្ថាន និងមុខងារ ជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បាន និងកំពុងត្រៀមរៀបចំលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនានា ដើម្បីធានាដល់យន្តការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តនូវមុខងារដែលនឹងត្រូវបានផ្ទេរទៅឱ្យជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០១៦នេះតទៅ។

ជាមួយគ្នានេះដែរ ក្រសួងមុខងារសាធារណៈ ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាក៏បានរៀបចំបញ្ចប់នូវសេចក្តីព្រាងលក្ខន្តិកៈដោយឡែកសម្រាប់

បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដោយគ្រោងដាក់ឆ្លងសេចក្តីព្រាងលក្ខន្តិកៈនេះ ក្នុងកិច្ចប្រជុំ គ.ជ.អ.ប និងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចនាពេលឆាប់ៗខាងមុខនេះ។ លក្ខន្តិកៈដោយឡែកនេះ មានគោលបំណងបង្កើតនូវប្រព័ន្ធគ្រប់គ្រងបុគ្គលិក តាមបែបវិមជ្ឈការមួយ ក៏ប៉ុន្តែស្ថិតក្រោមគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ដើម្បីធានាដល់ការផ្តល់សិទ្ធិអំណាច និងស្វ័យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងអភិវឌ្ឍសមត្ថភាពបុគ្គលិកប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព ជំរុញលើកទឹកចិត្តបុគ្គលិកឱ្យទៅបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ធានាអព្យាក្រឹត្យភាពរបស់បុគ្គលិកក្នុងការបំពេញតួនាទីរបស់ខ្លួន និងបង្កលក្ខណៈងាយស្រួលក្នុងការផ្ទេរបុគ្គលិកទន្ទឹមនឹងដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

សមិទ្ធផលគួរជាទីមោទនៈសំខាន់មួយទៀតផងដែរ ពាក់ព័ន្ធនឹងកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺការធ្វើប្រតិភូកម្មលើការគ្រប់គ្រង ចាត់ចែង និងការទទួលខុសត្រូវលើការផ្តល់សេវារដ្ឋបាលឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ គិតមកដល់ពេលនេះ មានក្រសួង ស្ថាប័នចំនួន១០បានធ្វើប្រតិភូកម្មនូវមុខងារផ្តល់សេវារដ្ឋបាលចំនួន ប្រមាណជាង២០០ប្រភេទសេវាឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន៤០ ដើម្បីផ្តល់សេវារដ្ឋបាលទាំងនេះជូនប្រជាពលរដ្ឋតាមរយៈការិយាល័យច្រកចេញចូលតែមួយ។ ការិយាល័យទាំងនេះបាន និងកំពុងផ្តល់សេវាយ៉ាងសកម្ម និងទទួលបានការពេញចិត្តពីប្រជាពលរដ្ឋ។ ក្នុងរយៈពេល០៩ខែនៃឆ្នាំ២០១៥ ការិយាល័យច្រកចេញចូលទាំង៤០នេះបានផ្តល់សេវាប្រមាណ**៣៥៦**ពាន់សេវា ដោយប្រមូលចំណូលបានប្រមាណ**១១,៥៥**ពាន់លានរៀល ឬស្មើនឹង**២,៨៥**លានដុល្លារ។ យើងនឹងបន្តពង្រីកការិយាល័យច្រកចេញចូលតែមួយនេះទៅបណ្តាស្រុកមួយចំនួនផ្សេងទៀត ហើយនឹងរៀបចំការិយាល័យរបៀបនេះនៅតាមថ្នាក់រាជធានី ខេត្ត ជាបណ្តើរៗនៅបណ្តាឆ្នាំបន្តបន្ទាប់ខាងមុខនេះ។

បន្ថែមពីលើកិច្ចការសំខាន់ៗដូចបានគូសបញ្ជាក់ខាងលើ សមិទ្ធផលសំខាន់ផ្សេងទៀតដែលយើងសម្រេចបាននៅក្នុងឆ្នាំ២០១៥នេះ គឺការរៀបចំបង្កើត និងដាក់ឱ្យដំណើរការនូវមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៅតាមរដ្ឋបាលរាជធានី ខេត្តទាំងអស់នៅទូទាំងប្រទេស។ មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនេះ គឺជាយន្តការដ៏មានសារៈសំខាន់ថ្មីមួយសម្រាប់សម្របសម្រួលជាមួយស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋដើម្បីផ្តល់សេវាគាំទ្រផ្នែកអភិវឌ្ឍន៍សមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ដើម្បីធានាបន្តលើកកម្ពស់នូវប្រព័ន្ធអភិបាលតាមបែបប្រជាធិបតេយ្យ រដ្ឋបាលក្រុង ស្រុកនីមួយៗក៏បាន និងកំពុងរៀបចំនូវវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួន ក្នុងគោលបំណងបែងចែងតួនាទី ការទទួលខុសត្រូវឱ្យកាន់តែមានភាពច្បាស់លាស់រវាងអ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកប្រតិបត្តិ។

លើសពីនេះទៀត ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលជាដៃគូ ក្នុងឆ្នាំ២០១៥នេះ យើងក៏បានចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមជាបណ្តើរៗនៅតាមឃុំនានាក្នុងស្រុកគោលដៅមួយចំនួន ក្នុងគោលបំណងធានាឱ្យប្រជាពលរដ្ឋមានលទ្ធភាពងាយស្រួលក្នុងការទទួលបាននូវព័ត៌មានសំខាន់ៗអំពីការប្រើប្រាស់ថវិកា និងការបំពេញមុខងាររបស់ក្រុមប្រឹក្សា និងអង្គភាពផ្តល់សេវានានា និងលើកកម្ពស់ការចូល រួមរបស់ប្រជាពលរដ្ឋក្នុងការតាម

ដានត្រួតពិនិត្យ និងផ្តល់យោបល់ទៅលើកិច្ចការទាំងនេះ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ជាការពិតណាស់ រាល់ការធ្វើកំណែទម្រង់ ជាពិសេសកំណែទម្រង់វិមជ្ឈការ តែងតែជួបប្រទះនូវឧបសគ្គ និងការមិនពេញចិត្តមួយចំនួន។ ក៏ប៉ុន្តែយើងត្រូវតែមានភាពជឿជាក់ថា កំណែទម្រង់វិមជ្ឈការ គឺជាយុទ្ធសាស្ត្រដ៏ចាំបាច់ និងសមស្របបំផុតក្នុងការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈ និងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដែលជាការចូលរួមចំណែកដ៏សំខាន់ក្នុងការអភិវឌ្ឍជាតិលើគ្រប់វិស័យ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព។ ក្នុងន័យនេះ យើងត្រូវតែបន្តខិតខំប្រឹងប្រែងជំនះរាល់ឧបសគ្គទាំងឡាយ ដើម្បីធានាដល់ការសម្រេចបាននូវគោលបំណងនៃកំណែទម្រង់របស់យើង។

នៅក្នុងបរិបទនៃកំណែទម្រង់វិមជ្ឈការ ក្រសួង ស្ថាប័នថ្នាក់ជាតិ ចាំបាច់ត្រូវប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួនតាមរបៀបថ្មីមួយ ព្រមទាំងត្រូវបង្កើតនូវបរិយាកាស ដើម្បីលើកទឹកចិត្ត រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយជាស្ថាប័នទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ ដោយឡែក ក្រសួង ស្ថាប័នថ្នាក់ជាតិទទួលខុសត្រូវក្នុងការអភិវឌ្ឍគោលនយោបាយ ការកំណត់ស្តង់ដារសេវា ការគាំទ្រ និងការតាមដានត្រួតពិនិត្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាឱ្យសម្រេចបានតាមគោលនយោបាយ និងស្តង់ដារដែលបានកំណត់។

ជាមួយគ្នានេះ ក្នុងការរៀបចំ និងដាក់ចេញនូវគោលនយោបាយ គោលការណ៍ណែនាំនានា ដើម្បីធានាគុណភាពនៃការផ្តល់សេវាតាមស្តង់ដារដែលបានកំណត់ ក្រសួង ស្ថាប័នក៏ត្រូវតែពិចារណាទៅលើការធានាដល់ស្វ័យភាព និងភាពអាចបត់បែនបានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងការចាត់ចែងការផ្តល់សេវា និងការចាត់វិធានការដោះស្រាយបញ្ហានានាទៅតាមស្ថានភាពជាក់ស្តែង ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ចាំបាច់ត្រូវខិតខំបង្កើននូវភាពដឹកនាំ និងការទទួលខុសត្រូវរបស់ខ្លួនឱ្យបានកាន់តែរឹងមាំបន្ថែមទៀត។ ផ្អែកលើស្ថានភាពជាក់ស្តែងនៃមូលដ្ឋាននីមួយៗ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគំនិតផ្តួចផ្តើមដោះស្រាយបញ្ហានានា ក្រោមអំណាច និងមុខងារជាធន្មានុសិទ្ធិរបស់ខ្លួន ដោយពុំត្រូវរង់ចាំតែការណែនាំលម្អិតពីថ្នាក់ជាតិនោះឡើយ។ ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែយល់អំពីសិទ្ធិអំណាច និងស្វ័យភាពរបស់ខ្លួនក្នុងក្របខ័ណ្ឌនៃច្បាប់ និងត្រូវតែមានចក្ខុវិស័យច្បាស់លាស់ក្នុងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន និងត្រូវធានាដល់ការអភិវឌ្ឍរដ្ឋបាលរបស់ខ្លួនឱ្យក្លាយទៅជាស្ថាប័នមានសមត្ថភាព និងមានលទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយ តម្លាភាព គណនេយ្យភាព និងមានប្រសិទ្ធភាព។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ខ្ញុំសូមចាត់ទុកថា ឆ្នាំ២០១៦ខាងមុខនេះ គឺជាឆ្នាំដែលយើងត្រូវប្រមូលផ្តុំរាល់កិច្ចខិតខំប្រឹង

ប្រែងនៃការអនុវត្តកំណែទម្រង់របស់យើងទៅលើការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ យើងចាំបាច់ត្រូវតែគ្រោងរៀបចំនូវលទ្ធផលរំពឹងទុក និងចំណុចដៅជាអាទិភាពនានានៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦របស់យើងដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា និងគាំទ្រគ្នាទៅវិញទៅមក សំដៅសម្រេចបាននូវគោលបំណងខាងលើ។ ជាមួយគ្នានេះដែរ នៅពាក់កណ្តាលឆ្នាំ២០១៦ខាងមុខនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏ត្រូវរៀបចំឱ្យមានការត្រួតពិនិត្យមើលឡើងវិញនូវចំណុចដៅនានានៃផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី២ ដើម្បីធានាថា ក្រោយពេលអនុវត្តចប់នូវផែនការនេះនៅឆ្នាំ២០១៧ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានសមត្ថភាព និងលទ្ធភាពអនុវត្តមុខងារនានាយ៉ាងពេញលេញ និងកាន់តែមានប្រសិទ្ធភាពនៅក្នុងដំណាក់កាលទី៣ចុងក្រោយនៃកម្មវិធីជាតិរយៈពេល១០ឆ្នាំ។ ក្នុងក្របខណ្ឌនៃកិច្ចការជាអាទិភាពជាច្រើនសម្រាប់ឆ្នាំ២០១៦ខាងមុខនេះ ខ្ញុំសូមផ្តល់អនុសាសន៍ទៅលើបញ្ហាមួយចំនួនដូចខាងក្រោមៈ

**ទីមួយៈ អំពីការផ្ទេរមុខងារ**

ដូចខ្ញុំបានគូសបញ្ជាក់ពីខាងដើម នាពេលថ្មីៗកន្លងទៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យ ដើម្បីផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកទាំងអស់ទូទាំងប្រទេស។ ខ្ញុំសូមស្នើក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសហការគ្នាក្នុងការរៀបចំនូវយន្តការគាំទ្រនានា ដើម្បីធានាថា រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកទាំងអស់អាចមានលទ្ធភាពចាប់ផ្តើមទទួលខុសត្រូវលើការងារគ្រប់គ្រងសំរាមទីប្រជុំជននេះ ប្រកបដោយប្រសិទ្ធភាពចាប់ពីឆ្នាំ២០១៦តទៅ។ រដ្ឋបាលរាជធានី រដ្ឋបាលក្រុង រដ្ឋបាលស្រុកទាំងអស់ត្រូវសហការជាមួយរដ្ឋបាលខេត្ត រដ្ឋបាលខណ្ឌ រដ្ឋបាលឃុំ សង្កាត់ អង្គការសង្គមស៊ីវិល និងផ្នែកឯកជនលើការរៀបចំផែនការ និងការបង្កើតសេវាគ្រប់គ្រងសំរាមតាមទីប្រជុំជននានា ដើម្បីធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងអនាម័យបរិស្ថាននៅតាមទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ផ្អែកតាមការសម្រេចចិត្តក្នុងការផ្ទេរមុខងារក្នុងវិស័យអប់រំ ខ្ញុំសូមស្នើក្រសួងអប់រំ យុវជន និងកីឡាបន្តកិច្ចសហកាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាចាប់ផ្តើមរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ផ្ទេរមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំបឋមសិក្សា ការអប់រំកុមារតូច និងការអប់រំក្រៅប្រព័ន្ធ ដើម្បីឈានទៅធ្វើការផ្ទេរមុខងារទាំងនេះទៅឱ្យរដ្ឋបាលក្រុង ស្រុកមួយចំនួននៅក្នុងឆ្នាំ២០១៦ និងតាមដំណាក់កាលនានាដែលបានកំណត់។

យោងលើបទពិសោធន៍ នៃការអនុវត្តសាកល្បងនូវការផ្ទេរមុខងារគ្រប់គ្រងមណ្ឌលសុខភាពនៅតាមស្រុកគោលដៅមួយចំនួន ខ្ញុំសូមស្នើក្រសួងសុខាភិបាលបន្តការសិក្សា និងពិគ្រោះយោបល់ជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យលទ្ធភាព និងកំណត់ជម្រើសនានា ក្នុងការចាប់ផ្តើមផ្ទេរសាកល្បងនូវមុខងារគាំពារសុខភាពបឋមទៅឱ្យរដ្ឋបាលក្រុង ស្រុកមួយចំនួនក្នុងឆ្នាំ២០១៦ខាងមុខនេះ។

ដូចគ្នានេះដែរ ខ្ញុំសូមលើកទឹកចិត្តឱ្យក្រសួងអភិវឌ្ឍន៍ជនបទធ្វើការពង្រីកការផ្ទេរមុខងារពាក់ព័ន្ធនឹងការជួសជុល ការថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទឱ្យទៅស្រុកមួយចំនួនផ្សេងបន្ថែមទៀត ព្រមទាំងត្រូវរៀបចំផ្ទេរជាបណ្តើរៗនូវមុខងារចាំបាច់មួយចំនួនផ្សេងទៀត ដូចជា មុខងារជួសជុល និងថែទាំផ្លូវលំជនបទឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួននៅក្នុងឆ្នាំ២០១៦នេះ។

ដោយឡែក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក៏ចាំបាច់ត្រូវបន្តសហការ ជាមួយក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំយន្តការគាំទ្រ និងតាមដានត្រួតពិនិត្យឱ្យបានជាប្រចាំលើការអនុវត្តមុខងារ ពាក់ព័ន្ធនឹងការគ្រប់គ្រងមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល និងការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ ដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ក្នុងខេត្តគោលដៅមួយចំនួននៅក្នុងឆ្នាំ២០១៥នេះ ហើយត្រូវសិក្សា វាយតម្លៃ ប្រមូលមេរៀន និងបទពិសោធន៍ពីការធ្វើប្រតិភូកម្មនេះ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តក្នុងការពង្រីកការធ្វើប្រតិភូកម្ម ឬការប្រគល់មុខងារទាំងនេះជាអចិន្ត្រៃយ៍ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនផ្សេងទៀតនៅក្នុងបណ្តាឆ្នាំខាងមុខ។

ក្រៅពីនេះ ខ្ញុំសូមស្នើឱ្យក្រសួង ស្ថាប័នដែលស្ថិតក្នុងវិស័យអាទិភាពផ្សេងទៀត បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការជំរុញកិច្ចដំណើរការផ្ទេរមុខងាររបស់ខ្លួន ដើម្បីឈានទៅធ្វើការសម្រេចចិត្តក្នុងការកំណត់ និងផ្ទេរនូវមុខងារសំខាន់ៗមួយចំនួនផ្សេងទៀត ជាពិសេសមុខងារពាក់ព័ន្ធនឹងវិស័យកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ ជលផល ធនធានទឹក ដែលជាកិច្ចការដ៏មានសារៈសំខាន់ និងជាកិច្ចការដែលចាំបាច់តម្រូវឱ្យមានការចូលរួមចំណែក និងទទួលខុសត្រូវយ៉ាងច្បាស់លាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់លំដាប់ថ្នាក់។

ការផ្ទេរមុខងារសេវាទីប្រជុំជនមួយចំនួនពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ក៏ជាចំណុចដៅជាអាទិភាពមួយសម្រាប់ឆ្នាំ២០១៦ផងដែរ។ ពាក់ព័ន្ធនឹងកិច្ចការនេះ អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដើម្បីបន្តរៀបចំការសិក្សា ប្រមូលព័ត៌មាន និងកំណត់នូវជម្រើសនានាដើម្បីស្នើសុំការសម្រេចចិត្តក្នុងការផ្ទេរមុខងារសេវាទីប្រជុំជនចាំបាច់មួយចំនួន ដូចជាការគ្រប់គ្រងសួនច្បារសាធារណៈ ការបំភ្លឺផ្លូវសាធារណៈ ការគ្រប់គ្រងប្រព័ន្ធបង្ហូរកាកសំណល់រាវ ការគ្រប់គ្រងទីផ្សារ និងចំណតយានយន្តសាធារណៈជាដើម។

ជាមួយគ្នានេះដែរ ក្រៅពីការទទួលខុសត្រូវលើការគ្រប់គ្រង ចាត់ចែងអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលត្រូវបានផ្ទេរពីក្រសួង ស្ថាប័ននានា រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ក៏ត្រូវបង្កើនការយកចិត្តទុកដាក់ឱ្យបានកាន់តែច្រើនបន្ថែមទៀតក្នុងការផ្តួចផ្តើមគំនិតជ្រើសរើស គ្រប់គ្រង និងចាត់ចែងអនុវត្តនូវមុខងារជាជម្រើសនានា ដោយប្រើប្រាស់ធនធានឆន្ទានុសិទ្ធិរបស់ខ្លួន សំដៅធានាដល់ការឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើងនៅតាមមូលដ្ឋានបានទាន់ពេលវេលា។

**ទីពីរ៖ អំពីវិមជ្ឈការហិរញ្ញវត្ថុ**

**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាអនុប្រធាន គ.ជ.អ.ប បានគូសបញ្ជាក់នៅក្នុងសន្ទរកថាបើកសិក្ខាសាលាជាតិកាលពីម្សិលមិញរួចហើយ អំពីសារៈសំខាន់ និងអំពីវិធានការចាំបាច់នានាដើម្បីបន្តជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុ។ ខ្ញុំសូមឯកភាពទាំងស្រុងទៅលើគោលការណ៍តម្រង់ទិសនានាដែល **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** បានលើកឡើងពាក់ព័ន្ធនឹងការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក ការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនឹងការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ ការរៀបចំបង្កើតយន្តការផ្តល់មូលនិធិវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើតប្រភពចំណូលផ្ទាល់នៅមូលដ្ឋាន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការអនុវត្តតាមគោលកាណ៍តម្រង់ទិសទាំងនេះ នឹងធានាបាននូវភាពសុខដុមនីយកម្មរវាងកម្មវិធីកំណែទម្រង់ទាំងពីរ ពោលគឺ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាពិសេសនឹងធានាឱ្យមានភាពប្រទាក់ក្រឡាគ្នារវាងការផ្ទេរមុខងារ និងការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ទីបី៖ អំពីការបន្តពង្រឹងការអភិវឌ្ឍស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ**

ការបន្តពង្រឹងការអភិវឌ្ឍស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយទៅជាស្ថាប័នដ៏រឹងមាំ មានលទ្ធភាព និងមានការទទួលខុសត្រូវយ៉ាងពេញលេញក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តនូវមុខងារ និងធនធាននានាដែលបានផ្ទេរទៅឱ្យ ក៏នៅតែជាចំណុចដៅជាអាទិភាពដ៏មានសារៈសំខាន់មួយដែលយើងត្រូវបន្តខិតខំសម្រេចឱ្យបាននៅក្នុងឆ្នាំ២០១៦។

ពាក់ព័ន្ធនឹងកិច្ចការនេះ ខ្ញុំបានដឹងថា ថ្មីៗនេះក្រសួងមុខងារសាធារណៈ បានខិតខំសហការជាមួយអ្នកបច្ចេកទេសជំនាញរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការរៀបចំបញ្ចប់នូវ សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិរួចហើយ ព្រមទាំងត្រៀមដាក់ឆ្លងកិច្ចប្រជុំ គ.ជ.អ.ប ដែលគ្រោងរៀបចំឡើងនៅពេលខាងមុខឆាប់ៗនេះ។ អាស្រ័យហេតុនេះ ក្រសួងមុខងារសាធារណៈ គប្បីបន្តរៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាសម្រាប់អនុវត្តលក្ខន្តិកៈដោយឡែកនេះ ដើម្បីធានាដល់ការរៀបចំបាននូវប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធានាដល់ការលើកកម្ពស់ស្វ័យភាពរបស់រដ្ឋបាលទាំងនោះក្នុងការគ្រប់គ្រង និងចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួន លើកកម្ពស់គណនេយ្យភាពរបស់បុគ្គលិកចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ និងបង្កលក្ខណៈងាយស្រួលក្នុងការផ្ទេរបុគ្គលិក ភ្ជាប់ជាមួយនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាល ថ្នាក់ក្រោមជាតិ។

ទន្ទឹមគ្នានេះ អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃត្រូវផ្តោតការយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លាបន្ថែមទៀតក្នុងកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាដើម្បីបន្តពង្រឹងការអភិវឌ្ឍស្ថាប័នដ្ឋបាលក្រុង ស្រុកនិងលើកកម្ពស់សមត្ថភាពធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដើម្បីធានាថា រដ្ឋបាលទាំងនេះមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង ចាត់ចែងការផ្តល់សេវាសាធារណៈ

នានាដែលនឹងត្រូវផ្ទេរទៅឱ្យជាបណ្តើរៗចាប់ពីឆ្នាំ២០១៦ខាងមុខនេះ។ ខ្ញុំក៏សូមស្នើឱ្យមានការផ្តោតការយកចិត្តទុកដាក់ដល់ការរៀបចំ និងដាក់ឱ្យអនុវត្តនូវយន្តការអធិការកិច្ចដ៏ច្បាស់លាស់ និងមានលក្ខណៈជាប្រព័ន្ធមួយ សំដៅធានាដល់ការចាប់ផ្តើមអនុវត្តនូវយន្តការនេះពីឆ្នាំក្រោយតទៅ ដើម្បីលើកកម្ពស់ការអនុវត្តសិទ្ធិអំណាច តួនាទី ការទទួលខុសត្រូវ និងការប្រើប្រាស់ធនធាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

**ទីបួន៖ អំពីការបន្តអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម**

ការបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋ ឱ្យទទួលបាននូវព័ត៌មានសំខាន់ៗអំពីការប្រើប្រាស់ថវិកា ការផ្តល់សេវានៅតាមមូលដ្ឋាន និងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការតាមដានត្រួតពិនិត្យលើការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន ដើម្បីចូលរួមចំណែកពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន គឺជាគោលបំណងសំខាន់នៃផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម។ ក្នុងឆ្នាំ២០១៦ខាងមុខនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្តខិតខំសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា អង្គការសង្គមស៊ីវិលជាដៃគូ ដើម្បីបន្តពង្រីកការអនុវត្តការងារគណនេយ្យភាពសង្គមនេះទៅតាមឃុំ សង្កាត់នានាក្នុងក្រុង ស្រុកគោលដៅមួយចំនួនផ្សេងទៀត ដោយផ្អែកលើមេរៀន និងបទពិសោធន៍ដែលបានអនុវត្តនាពេលកន្លងមក។

**ទីប្រាំ៖ អំពីការបន្តលើកកម្ពស់ការងារយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម**

ផអ៣ទី២ បានបន្តផ្តោតការយកចិត្តទុកដាក់ឱ្យមានការខិតខំប្រឹងប្រែងបន្ថែមទៀតទៅលើការបញ្ជ្រាបយេនឌ័រ ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម ដើម្បីធានានូវការផ្តល់សិទ្ធិដល់ក្រុមផ្សេងៗ ជាពិសេសក្រុមជនងាយរងគ្រោះ និងក្រុមជនក្រីក្រឱ្យទទួលបានឱកាសសមស្របក្នុងការចូលរួម និងទទួលបានផលប្រយោជន៍ដោយមិនរើសអើងពីការផ្តល់សេវា ពីការអភិវឌ្ឍមូលដ្ឋាន និងពីល័ក្ខខ័ណ្ឌនានានៃការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយនៅតាមមូលដ្ឋាននីមួយៗ។ ផអ៣ទី២ ក៏បានកំណត់នូវវិធានការ និងជម្រើសនានាដើម្បីធានាដល់ការបញ្ជ្រាបយេនឌ័រ លើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមទៅក្នុងលទ្ធផលរំពឹងទុកទាំងអស់។ ពាក់ព័ន្ធនឹងកិច្ចការនេះ ខ្ញុំសូមស្នើក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប បន្តការសម្របសម្រួល និងគាំទ្រក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាក្នុងការរៀបចំបញ្ជ្រាបកិច្ចការដ៏មានសារៈសំខាន់នេះ ទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់ស្ថាប័នដើម្បីធានាឱ្យបានថា រាល់ការធ្វើសេចក្តីសម្រេចចិត្តនានារបស់ស្ថាប័ននីមួយៗ បានគិតគូរ និងពិចារណាអំពីបញ្ហាយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។ ជាមួយគ្នានេះដែរ ក្នុងឆ្នាំ២០១៦ខាងមុខនេះ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីត្រូវផ្តល់អាទិភាពទៅលើការរៀបចំ និងដាក់ចេញនូវគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម បន្តពង្រឹងយន្តការគាំទ្រដល់បណ្តាញស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងជំរុញឱ្យបានខ្លាំងក្លានូវការរៀបចំវគ្គបណ្តុះបណ្តាល ជាកាតព្វកិច្ចដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅបង្កើនការយល់ដឹងថ្មីៗបន្ថែមទៀតអំពី

បញ្ហាយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។ ខ្ញុំសូមអំពាវនាវឱ្យថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវពិចារណាអំពីបញ្ហាស្ត្រី កុមារ បរិយាប័ន្ន និងសមធម៌សង្គមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តរបស់ខ្លួន ដើម្បីធានាដល់ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចនៅ តាមមូលដ្ឋានប្រកបដោយសុខដុមរមនានៅក្នុងសង្គម។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

មុននឹងបញ្ចប់ ខ្ញុំសូមគូសបញ្ជាក់អះអាងសារជាថ្មីថា រាជរដ្ឋាភិបាលមានការតាំងចិត្តផ្នែកនយោបាយយ៉ាងច្បាស់លាស់អំពីការអនុវត្តកំណែទម្រង់នេះ។ ទោះបីមានបញ្ហាប្រឈមមួយចំនួនដែលយើងត្រូវបន្តដោះស្រាយឱ្យបាន ប៉ុន្តែយ៉ាងណាមិញ ឆន្ទៈនេះត្រូវបានបង្ហាញឱ្យឃើញយ៉ាងច្បាស់តាមរយៈសមិទ្ធផលដ៏ធំធេងនានា ដែលយើងទាំងអស់គប្បីទទួលស្គាល់។ ទោះបីយ៉ាងនេះក្តី យើងនៅតែនៅត្រូវការការគាំទ្រពីដៃគូអភិវឌ្ឍន៍នានាក្នុងរយៈពេលមធ្យមមួយដែលនៅតែជាតម្រូវការចាំបាច់ ដើម្បីធានាដល់ការឈានឆ្ពោះទៅសម្រេចគោលបំណងចុងក្រោយនៃកំណែទម្រង់។

ជំនួសមុខឱ្យប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបាន និងកំពុងបន្តផ្តល់ការគាំទ្រប្រកបដោយភាពយោគយល់ដល់កិច្ចដំណើរការកំណែទម្រង់នៅកម្ពុជា ហើយខ្ញុំសូមធានាអះអាងថា ជំនួយទាំងនេះនឹងត្រូវបានប្រើប្រាស់ប្រកបដោយគណនេយ្យភាព និងតម្លាភាព។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមចំណែកយ៉ាងសកម្មរបស់អង្គការសង្គមស៊ីវិលនានា នៅក្នុងកិច្ចដំណើរការជាទូទៅនៃកំណែទម្រង់ដ៏មានសារៈសំខាន់នេះ។ យើងនឹងខិតខំបន្តពង្រីកពូនជ្រំនូវភាពជាដៃគូប្រកបដោយភាពស្ថាបនា និងស្មោះស្ម័គ្រជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដើម្បីរួមគ្នាឆ្លើយតបឱ្យបានពេញលេញទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួម និងផ្តល់មតិយោបល់ក្នុងសិក្ខាសាលាជាតិរយៈពេលពីរថ្ងៃនេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លេខាធិការដ្ឋាន គ.ជ.អ.ប ដែលបានខិតខំប្រឹងប្រែងរៀបចំ និងសម្របសម្រួលរាល់កិច្ចការដែលធ្វើឱ្យសិក្ខាសាលាទទួលបានលទ្ធផលជាផ្លែផ្កាតាមការគ្រោងទុក។

ជាទីបញ្ចប់ ជាមួយសមិទ្ធផលដែលសម្រេចបានក្នុងសិក្ខាសាលាជាតិនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រសិទ្ធិពរជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ទទួលបាននូវពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លាងឃ្លាតឡើយ និង**សូមប្រកាសបិទសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។**

**សូមអរគុណ**

## ឧបសម្ព័ន្ធទី៣ ៖ ផែនការជំនួយបច្ចេកទេស

តារាងខាងក្រោមសង្ខេបពីថវិកាសម្រាប់ជំនួយបច្ចេកទេសសម្រាប់ឆ្នាំ២០១៦។ ផែនការជំនួយបច្ចេកទេសឆ្នាំ២០១៦ មានលក្ខណៈខុសគ្នាពីផែនការជំនួយបច្ចេកទេសឆ្នាំ២០១៥ដូចខាងក្រោម ៖

- ចំនួនបុគ្គលិកនៃជំនួយបច្ចេកទេសមានការថយចុះពី១.០១៣នាក់មក៦៧៥នាក់ (ថយចុះចំនួន៣៣%)
- ថវិកាសរុបថយចុះពី៦,០៧លានដុល្លារអាមេរិកមកចំនួន៤,៨៤លានដុល្លារអាមេរិក (ថយចុះចំនួន២១%)
- ក្នុងឆ្នាំ២០១៦ ជំនួយបច្ចេកទេសភាគច្រើន គឺនៅថ្នាក់ក្រោមជាតិដែលចំណាយមានចំនួន៧១%នៃថវិកាជំនួយបច្ចេកទេសសរុប។

តារាងខាងក្រោមស្តីពីជំនួយបច្ចេកទេសមិនរួមបញ្ចូលចំណាយ សម្រាប់ការធានារ៉ាប់រងផ្នែកសុខភាពរបស់បុគ្គលិកដែលមានចំនួន២៤០.៤៨០ដុល្លារអាមេរិកឡើយ។ ថវិកាសរុបរួមសម្រាប់បុគ្គលិកដែលរួមបញ្ចូលប្រាក់បៀវត្ស ប្រាក់ធានារ៉ាប់រងសុខភាព និងចំណាយពាក់ព័ន្ធផ្សេងទៀតមានចំនួន៥.០៨៧.៤៣៦ដុល្លារអាមេរិក។

### តារាងស្តីពីផែនការជំនួយបច្ចេកទេសនៃផអ៣ទី២តាមថ្នាក់រដ្ឋបាល និងថវិកា

| ថ្នាក់រដ្ឋបាល និងស្ថាប័ន | ទីប្រឹក្សា | | បុគ្គលិកកិច្ចសន្យា | | សរុប | |
|---|---|---|---|---|---|---|
| | ចំនួន | ប្រាក់ខែ | ចំនួន | ប្រាក់ខែ | ចំនួន | ប្រាក់ខែ |
| 1. ថ្នាក់ជាតិ | | | | | | |
| 1.1. លេខាធិការដ្ឋាន គ.ជ.អ.ប | | | | | | |
| ក. ទីប្រឹក្សាអន្តរជាតិ | 2 | 411,792 | 0 | 0 | **2** | **411,792** |
| ខ. ទីប្រឹក្សាជាតិ និងបុគ្គលិកកិច្ចសន្យា | 18 | 439,500 | 59 | 319,080 | **77** | **758,580** |
| 1.2. ក្រសួងមហាផ្ទៃ | 7 | 163,764 | 7 | 30,960 | **14** | **194,724** |
| 1.3. ក្រសួងមុខងារសាធារណៈ | 1 | 26,700 | 2 | 10,560 | **3** | **37,260** |
| 1.4. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 1 | 26,700 | 4 | 12,780 | **5** | **39,480** |
| 1.5. សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 0 | 0 | 3 | 17,040 | **3** | **17,040** |
| **សរុបរង** | **29** | **1,068,456** | **75** | **390,420** | **104** | **1,458,876** |
| 2. ថ្នាក់ក្រោមជាតិ | | | | | | |
| 2.1. រាជធានី ខេត្ត | 96 | 1,721,880 | 105 | 312,000 | **201** | **2,033,880** |
| 2.2. ក្រុង ស្រុក | 185 | 799,200 | 185 | 555,000 | 370 | **1,354,200** |
| **សរុបរង** | **281** | **2,521,080** | **290** | **867,000** | **571** | **3,388,080** |
| **3. សរុបរួម (1 + 2)** | **310** | **3,589,536** | **265** | **1,257,420** | **675** | **4,846,956** |

# ឧបសម្ព័ន្ធទី៤ ÷ តារាងសកម្មភាព និងថវិកាលម្អិត

| **សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ និងសកម្មភាព** | | | **ស្ថាប័នអនុវត្ត** | **ថវិកា** | **ប្រភព** |
|---|---|---|---|---|---|
| **សមិទ្ធផលរំពឹងទុកនៃផអ៣ទី២** | **1** | **ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ សំដៅឈានឆ្ពោះទៅរកការគ្រប់គ្រងដែលធានាឲ្យមានការផ្លាស់ប្តូរ** | | **5,418,718** | |
| លទ្ធផលរំពឹងទុកនៃផអ៣ទី២ | 1.1 | ការដឹកនាំ ការគ្រប់គ្រង និងការសម្របសម្រួលរបស់ គ.ជ.អ.ប លើកិច្ចដំណើរការផ្នែកនយោបាយ និងការអនុវត្តកម្មវិធីកំណែទម្រង់ត្រូវបានលើកកម្ពស់ ដើម្បីធានាដល់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឲ្យកាន់តែមានប្រសិទ្ធភាព | | 33,200 | |
| យុទ្ធសាស្ត្រនៃផអ៣ទី២ | 1.1.2 | រៀបចំកិច្ចប្រជុំ គ.ជ.អ.ប យ៉ាងតិចចំនួន៣លើកក្នុងមួយឆ្នាំ ដោយមានការកំណត់ច្បាស់លាស់ជាមុននូវកាលបរិច្ឆេទនៃកិច្ចប្រជុំទាំងនោះ និងផ្តោតទៅលើបញ្ហា និងការសម្រេចចិត្តផ្នែកគោលនយោបាយសំខាន់ៗ | | 33,200 | |
| លទ្ធផលរំពឹងទុកទី១នៃ ផ.ស.ថ | 1.1.2.1 | ការលើកកម្ពស់ និងការអនុវត្តយន្តការសម្របសម្រួលនានា ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយស្តីពីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | | 33,200 | |
| សកម្មភាពនៃ ផ.ស.ថ | 1.1.2.1.1 | រៀបចំឱ្យមានកិច្ចប្រជុំ គ.ជ.អ.ប. យ៉ាងហោចណាស់ចំនួន៣ដងក្នុង១ឆ្នាំ | PADD | 30,000 | Basket |
| | 1.1.2.1.2 | រៀបចំកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនីមួយៗនៃ គ.ជ.អ.ប. | PADD | 3,200 | Basket |
| | 1.1.2.1.3 | រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្ត ផ.ស.ថ. ជូន គ.ជ.អ.ប. ជាទៀងទាត់ | PADD | 0 | Basket |
| | 1.1.2.1.4 | ពិនិត្យមើលឡើងវិញ និងពង្រឹងការប្រាស្រ័យទាក់ទង និងការគាំទ្ររបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដល់ គ.ជ.អ.ប. និងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការងារកំណែទម្រង់ | PADD | 0 | Basket |
| | 1.1.2.1.5 | ចូលរួមក្នុងការសម្របសម្រួលកំណែទម្រង់អន្តរវិស័យជាមួយកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ ហិរញ្ញវត្ថុសាធារណៈ ដើម្បីលើកកម្ពស់ការសម្របសម្រួល និងប្រសិទ្ធភាព | PADD | 0 | Basket |
| លទ្ធផលរំពឹងទុកនៃផអ៣ទី២ | 1.2 | តួនាទីលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបានផ្លាស់ប្តូរពីតួនាទីបែបប្រតិបត្តិការទៅជាតួនាទីសម្របសម្រួលការអនុវត្ត និងការគ្រប់គ្រងកម្មវិធីកំណែទម្រង់ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ | | 4,181,018 | |
| យុទ្ធសាស្ត្រនៃផអ៣ទី២ | 1.2.1 | ពិនិត្យឡើងវិញ និងកែសម្រួលរចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ជ.អ.ប ល័ក្ខខ័ណ្ឌការងារ និងការរៀបចំមន្ត្រី បុគ្គលិកដើម្បីឆ្លើយតបទៅនឹងអាទិភាពជាយុទ្ធសាស្ត្រនានានៃកំណែទម្រង់ក្នុងផអ៣ដំណាក់កាលទី២ | | 4,181,018 | |
| លទ្ធផលរំពឹងទុកទី២នៃ ផ.ស.ថ | 1.2.1.1 | ការពង្រឹងរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី និងសមត្ថភាពរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការអភិវឌ្ឍគោលនយោបាយ និងការគ្រប់គ្រងកម្មវិធី | | 4,181,018 | |
| សកម្មភាពនៃ ផ.ស.ថ | 1.2.1.1.1 | ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ជ.អ.ប ផ្អែកតាមអាទិភាពនៃកំណែទម្រង់ដែលបានកំណត់ក្នុងផអ៣ទី២ ក៏ដូចជាការគ្រប់គ្រងគម្រោង និងកម្មវិធីនានាក្នុងក្របខ័ណ្ឌ ផអ៣ទី២ | AFD | 0 | Basket |
| | 1.2.1.1.2 | ពិនិត្យ និងកែសម្រួលតួនាទី និងភារកិច្ចរបស់បុគ្គលិកលេខាធិការដ្ឋាន គ.ជ.អ.ប ផ្អែកតាមផអ៣ទី២ | AFD | 0 | Basket |

| សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ និងសកម្មភាព | | | ស្ថាប័នអនុវត្ត | ថវិកា | ប្រភព |
|---|---|---|---|---|---|
| | 1.2.1.1.3 | រៀបចំការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិកនៃលេខាធិការដ្ឋាន គ.ជ.អ.ប តាមរយៈវគ្គបណ្តុះបណ្តាលផ្លូវការ និងមិនផ្លូវការ ការចូលរួមកិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងសកម្មភាពពាក់ព័ន្ធផ្សេងទៀត | AFD | 30,000 | Basket |
| | 1.2.1.1.4 | ជួលទីប្រឹក្សារយៈពេលខ្លីដើម្បីរៀបចំគោលនយោបាយលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានា | PADD | 50,000 | Basket |
| | 1.2.1.1.5 | រៀបចំកិច្ចប្រជុំ សិក្ខាសាលាស្តីពីការអនុវត្តសេចក្តីសម្រេចរួម និងការអភិវឌ្ឍសមត្ថភាពរបស់ថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | PMSD | 26,950 | Basket |
| | 1.2.1.1.6 | ពិនិត្យមើលឡើងវិញ និងសិក្សាវាយតម្លៃស្តីពីការអនុវត្តកម្មវិធីជាតិ និងការរៀបចំ ផអ៣ទី៣ | PMSD | 27,850 | Basket |
| | 1.2.1.1.7 | ពង្រឹងកិច្ចប្រជុំផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ជាប្រចាំស្តីពីការគ្រប់គ្រង ផ.ស.ថ. រួមទាំងគម្រោង កម្មវិធីនានា | PMSD | 0 | Basket |
| | 1.2.1.1.8 | ពង្រឹងកិច្ចប្រជុំផ្ទៃក្នុងរបស់អង្គភាពនៃលេខាធិការដ្ឋាន គ.ជ.អ.ប ជាប្រចាំស្តីពីការគ្រប់គ្រងកម្មវិធី និងការគាំទ្រក្រសួង ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ | PMSD | 0 | Basket |
| | 1.2.1.1.9 | គាំទ្រប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ពង្រឹងការប្រាស្រ័យទាក់ទងក្នុងលេខាធិការដ្ឋាន គ.ជ.អ.ប. | MEID | 6,000 | Basket |
| | 1.2.1.1.10 | រៀបចំ និងពង្រឹងប្រព័ន្ធផ្ទុកទិន្នន័យរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | MEID | 22,000 | Basket |
| | 1.2.1.1.11 | អនុវត្តសាកល្បងចំនួន២ករណីអំពីកិច្ចដំណើរការរៀបចំគោលនយោបាយដែលបានកែសម្រួល | PADD | 0 | Basket |
| | 1.2.1.1.12 | គាំទ្រការអភិវឌ្ឍគោលនយោបាយ និងសមត្ថភាពពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកំណែទម្រង់រដ្ឋបាលសាធារណៈ | PMU | 350,000 | GiZ EU/SPACE |
| | 1.2.1.1.13 | គាំទ្រការអភិវឌ្ឍគោលនយោបាយ និងសមត្ថភាពពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកំណែទម្រង់រដ្ឋបាលសាធារណៈ | PMU | 650,000 | GiZ ARDP |
| | 1.2.1.1.14 | លេខាធិការដ្ឋាន គ.ជ.អ.ប រៀបចំកិច្ចប្រជុំប្រចាំជាមួយដៃគូអភិវឌ្ឍន៍នានាអំពីការរៀបចំ និងការគ្រប់គ្រង ផ.ស.ថ. ក៏ដូចជាការត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត | PMSD | 1,200 | Basket |
| | 1.2.1.1.15 | លេខាធិការដ្ឋាន គ.ជ.អ.ប រៀបចំទស្សនកិច្ចសិក្សាជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីតាមដានពីវឌ្ឍនភាពនៃការអនុវត្ត និង សិក្សារៀនសូត្រពីកម្មវិធីនៅថ្នាក់ក្រោមជាតិ | PMSD | 5,000 | Basket |
| | 1.2.1.1.16 | លេខាធិការដ្ឋាន គ.ជ.អ.ប រៀបចំកិច្ចប្រជុំប្រចាំជាមួយគម្រោងដាច់ដោយឡែកនានា | PMSD | 0 | Basket |
| | 1.2.1.1.17 | រៀបចំវគ្គបណ្តុះបណ្តាលសៀវភៅណែនាំស្តីពីរដ្ឋបាល និងហិរញ្ញវត្ថុដែលបានកែសម្រួល | AFD | 20,000 | Basket |
| | 1.2.1.1.18 | ប្រកាសជ្រើសរើសសវនកម្ម២០១៥ និងចំណាយសម្រាប់ការធ្វើសវនកម្មឆ្នាំ២០១៦ | AFD | 30,000 | Basket |
| | 1.2.1.1.19 | កិច្ចប្រជុំជាមួយថ្នាក់ក្រោមជាតិអំពីការអនុវត្តថវិកា ផ.ស.ថ. ការអភិវឌ្ឍសមត្ថភាព និងចែករំលែកបទពិសោធន៍នានា | AFD | 15,000 | Basket |
| | 1.2.1.1.20 | ត្រួតពិនិត្យ តាមដាន និងគាំទ្រថ្នាក់ក្រោមជាតិក្នុងការអនុវត្ត និងការគ្រប់គ្រងថវិកានៃ ផ.ស.ថ និងសវនកម្មនានា | AFD | 25,000 | Basket |
| | 1.2.1.1.21 | ផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពស្តីពីការងារសវនកម្មផ្ទៃក្នុង | IAG | 3,000 | Basket |
| | 1.2.1.1.22 | ចុះធ្វើសវនកម្មផ្ទៃក្នុងលើការអនុវត្ត ផ.ស.ថ. ព្រមទាំងការងារពាក់ព័ន្ធនានា និងរៀបចំរបាយការណ៍ | IAG | 7,000 | Basket |
| | 1.2.1.1.23 | ពិនិត្យ និងកែសម្រួលឡើងវិញនូវសេចក្តីណែនាំស្តីពីការរៀបចំ ផ.ស.ថ | PMSD | 0 | Basket |

| សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ និងសកម្មភាព | | | ស្ថាប័នអនុវត្ត | ថវិកា | ប្រភព |
|---|---|---|---|---|---|
| | 1.2.1.1.24 | រៀបចំ ផ.ស.ថ របស់ គ.ជ.អ.ប ដោយមានការចូលរួម និងការប្រឹក្សាយោបល់ពីអ្នកពាក់ព័ន្ធនានា | PMSD | 1,000 | Basket |
| | 1.2.1.1.25 | ពិនិត្យ និងអនុម័តសេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. ជាមួយស្ថាប័នអនុវត្តនានានា | PMSD | 0 | Basket |
| | 1.2.1.1.26 | រៀបចំ និងចុះកិច្ចព្រមព្រៀងរវាង គ.ជ.អ.ប. ជាមួយគម្រោង និងកម្មវិធីនានា | PMSD | 0 | Basket |
| | 1.2.1.1.27 | រៀបចំវគ្គរំលឹកឡើងវិញស្តីពីការរៀបចំ ការធ្វើវិសោធនកម្ម និងការបិទសេចក្តីសម្រេចរួម | PMSD | 15,670 | Basket |
| | 1.2.1.1.28 | រៀបចំសិក្ខាសាលាជាតិស្តីពីការរៀបចំ ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនានា រួមទាំងអង្គការសង្គមស៊ីវិល | PMSD | 121,500 | Basket |
| | 1.2.1.1.29 | រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប និងកំណត់ អាទិភាព និងយុទ្ធសាស្ត្រសម្រាប់ឆ្នាំបន្ទាប់ | PMSD | 20,050 | Basket |
| | 1.2.1.1.30 | ពិនិត្យ កែសម្រួល និងផ្សព្វផ្សាយឯកសារបច្ចេកទេស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងមូលនិធិក្រុង ស្រុក | PMSD | 24,700 | Basket |
| | 1.2.1.1.31 | តាមដាន និងផ្តល់ការគាំទ្របច្ចេកទេសជាប្រចាំដល់ស្ថាប័នអនុវត្តនានានៃផអ៣ទី២នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | PMSD | 31,560 | Basket |
| | 1.2.1.1.32 | ផ្តល់ការគាំទ្រជំនួយបច្ចេកដល់លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័ននានាក្នុងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០១៦ របស់ គ.ជ.អ.ប. | AFD | 1,493,796 | Basket |
| | 1.2.1.1.33 | គាំទ្រ និងសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ការអនុវត្ត ការគ្រប់គ្រង ការតាមដាន និងការរៀបចំរបាយការណ៍នៃ ផ.ស.ថ. ឆ្នាំ២០១៦ របស់ គ.ជ.អ.ប. ដោយលេខាធិការដ្ឋាន គ.ជ.អ.ប. | AFD | 300,000 | Basket |
| | 1.2.1.1.34 | គាំទ្រហេដ្ឋរចនាសម្ព័ន្ធ និងចំណាយទឹក ភ្លើង...របស់លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការគ្រប់គ្រង ផអ៣ទី២ | AFD | 200,000 | RGC |
| | 1.2.1.1.35 | អនុវត្តសកម្មភាព និងព្រឹត្តិការណ៍មិនបានគ្រោងទុកនានាពាក់ព័ន្ធនឹងការគ្រប់គ្រងកម្មវិធី និងការរៀបចំគោលនយោបាយ | AFD | 703,742 | Basket |
| លទ្ធផលរំពឹងទុកនៃផអ៣ទី២ | 1.3 | យុទ្ធសាស្ត្រស្តីពីការចែករំលែកព័ត៌មានក្នុងចំណោមស្ថាប័នរដ្ឋ និងរវាងស្ថាប័នរដ្ឋជាមួយនឹងសាធារណជន ត្រូវបានរៀបចំបញ្ចប់ និងដាក់ឲ្យអនុវត្ត ក្នុងគោលបំណងផ្តល់ព័ត៌មានសំខាន់ៗឲ្យបានច្បាស់លាស់ និងកំណត់អំពីវិធីសាស្ត្រសមស្របសម្រាប់ផ្តល់ព័ត៌មានដល់ក្រុមអ្នកពាក់ព័ន្ធផ្សេងៗ | | 113,900 | |
| យុទ្ធសាស្ត្រនៃផអ៣ទី២ | 1.3.2 | រៀបចំ និងដាក់ឲ្យអនុវត្តនូវប្រព័ន្ធសម្របសម្រួលជាប្រចាំ ប្រព័ន្ធប្រឹក្សាយោបល់ដោយចំហ និងប្រព័ន្ធផ្លាស់ប្តូរព័ត៌មានរវាងក្រុមអ្នកពាក់ព័ន្ធសំខាន់ៗទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | 113,900 | |
| លទ្ធផលរំពឹងទី៣នៃ ផ.ស.ថ | 1.3.2.1 | ការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ដោយរួមបញ្ចូលទាំងការប្រឹក្សាយោបល់ និងការផ្លាស់ប្តូរព័ត៌មានជាប្រចាំ និងបើកចំហនៅក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | 113,900 | |
| សកម្មភាពនៃ ផ.ស.ថ | 1.3.2.1.1 | រៀបចំផ្ទាំងព័ត៌មាន និងខិតប័ណ្ណជាឧបករណ៍នៃការប្រាស្រ័យទាក់ទងជាមូលដ្ឋានដែលផ្ទាំងនីមួយៗមានសញ្ញាសម្គាល់ដោយឡែក | MEID | 35,000 | Basket |
| | 1.3.2.1.2 | រៀបចំសេចក្តីណែនាំ សម្រាប់ការបញ្ជ្រាបយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងទៅក្នុងគ្រប់វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការរៀបចំកិច្ចដំណើរការកសាងផែនការ | MEID | 0 | Basket |
| | 1.3.2.1.3 | បង្កើតនូវសំណុំព័ត៌មាន រូបថត និងក្រាភិចដែលមានគុណភាពខ្ពស់ | MEID | 15,000 | Basket |
| | 1.3.2.1.4 | ធ្វើបច្ចុប្បន្នភាពនិងធ្វើឱ្យប្រសើរឡើងនូវគេហទំព័ររបស់ គ.ជ.អ.ប ដើម្បីផ្តល់ភាពងាយ ស្រួលសម្រាប់អ្នកប្រើប្រាស់នានា | MEID | 4,000 | Basket |

| សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក យុទ្ធសាស្រ្ត និងសកម្មភាព | | | ស្ថាប័នអនុវត្ត | ថវិកា | ប្រភព |
|---|---|---|---|---|---|
| | 1.3.2.1.5 | ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធរបស់ការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន ចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប ដោយរួមបញ្ចូលការទទួលខុសត្រូវផ្នែកបណ្ណាល័យ និងពង្រឹងសមត្ថភាពបុគ្គលិក ដើម្បីទទួលបាននូវជំនាញដែលត្រូវការ | MEID | 3,000 | Basket |
| | 1.3.2.1.6 | រៀបចំ និងអនុវត្តកម្មវិធីផ្សព្វផ្សាយសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយសារព័ត៌មាន វិទ្យុ និងទូរទស្សន៍ជាដើម | MEID | 15,000 | Basket |
| | 1.3.2.1.7 | អភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធផ្សព្វផ្សាយតាមបណ្តាញសង្គមដែលបានធ្វើបច្ចុប្បន្ន ភាពជាប្រចាំ ដើម្បីលើកកម្ពស់ការចូលរួមរបស់សាធារណជន | MEID | 20,900 | Basket |
| | 1.3.2.1.8 | លើកកម្ពស់ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវ ការយល់ដឹងស៊ីជម្រៅអំពីការងារកំណែទម្រង់ | PADD | 15,000 | Basket |
| | 1.3.2.1.9 | រៀបចំ និងអនុវត្តវិធីសាស្រ្តដែលមានលក្ខណៈជាប្រព័ន្ធនៃការចូលរួមរបស់ក្រសួង ស្ថាប័ន ជំនាញ ដើម្បីធានាឱ្យមានការយល់ដឹងស៊ីជម្រៅអំពីការងារកំណែទម្រង់ជាពិសេស កិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | PADD | 6,000 | Basket |
| | 1.3.2.1.10 | អនុវត្តយុទ្ធនាការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ដោយគូសបញ្ជាក់អំពីសារសំខាន់នៃការផ្ទេរមុខងារ និងធនធាននានា ដូចជាការអប់រំកម្រិតបឋមសិក្សា ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ល។ | PADD | 0 | Basket |
| | 1.3.2.1.11 | រៀបចំសិក្ខាសាលានានាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីស្តាប់មតិយោបល់ សិក្សា រៀនសូត្រ និងដកស្រង់បទពិសោធន៍សម្រាប់កែលម្អការអនុវត្តកម្មវិធី | PADD | 0 | Basket |
| លទ្ធផលរំពឹងទុកនៃផអ៣ទី២ | 1.4 | ភាពជាម្ចាស់ និងការចូលរួមរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិក្នុងកិច្ចដំណើរការកំណែទម្រង់ត្រូវបានពង្រឹង | | 18,200 | |
| យុទ្ធសាស្រ្តនៃផអ៣ទី២ | 1.4.1 | ក្រសួង ស្ថាប័ននានាត្រូវបន្តរៀបចំដាក់បញ្ចូលនូវតួនាទី និងធនធានសម្រាប់ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួង ស្ថាប័នទៅក្នុងគោលនយោបាយ ផែនការ ថវិកា និងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃនៃក្រសួង ស្ថាប័នរបស់ខ្លួន ដើម្បីធ្វើឲ្យកិច្ចការដែលទាក់ទងនឹងកិច្ចដំណើរការផ្ទេរមុខងារ និងការអភិវឌ្ឍសមត្ថភាពក្លាយទៅជាផ្នែកមួយនៃសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន | | 18,200 | |
| លទ្ធផលរំពឹងទុកទី៤នៃ ផ.ស.ថ | 1.4.1.1 | ការប្រឹក្សាយោបល់ជាប្រចាំអំពីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយក្រសួង ស្ថាប័នអនុវត្តនានា | | 18,200 | |
| សកម្មភាពនៃ ផ.ស.ថ | 1.4.1.1.1 | ពង្រឹងសមត្ថភាពក្នុងការបំពេញមុខងារ និងសមត្ថភាពរបស់ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួង ស្ថាប័នក្នុងការអនុវត្តកិច្ចដំណើរការនៃការផ្ទេរមុខងារឱ្យកាន់តែមានប្រសិទ្ធភាព | PADD | 4,200 | Basket |
| | 1.4.1.1.2 | រៀបចំកិច្ចប្រជុំសម្របសម្រួលជាប្រចាំជាមួយក្រសួង ស្ថាប័ននានាស្តីពីការរៀបចំគោលនយោបាល និងលិខិតបទដ្ឋាននានាស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារ ការគ្រប់គ្រងបុគ្គលិក... | PADD | 4,000 | Basket |
| | 1.4.1.1.3 | លេខាធិកាដ្ឋាន គ.ជ.អ.ប. រៀបចំទស្សនកិច្ចសិក្សារួមគ្នាជាមួយក្រសួង ស្ថាប័ន ដើម្បីតាមដាន និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការផ្ទេរមុខងារ ការគ្រប់គ្រងធនធានមនុស្ស និងបញ្ហាពាក់ព័ន្ធផ្សេងទៀត | PADD | 10,000 | Basket |
| លទ្ធផលរំពឹងទុកនៃផអ៣ទី២ | 1.5 | ភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិលើកិច្ចដំណើរការកំណែទម្រង់ និងវឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ទៅតាមតម្រូវការជាក់លាក់របស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើង | | 1,072,400 | |
| យុទ្ធសាស្រ្តនៃផអ៣ទី២ | 1.5.1 | ពិនិត្យឡើងវិញ កែសម្រួល និងពង្រឹងតួនាទី ភារកិច្ច និងចរិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីធានាឲ្យមន្ត្រី | | 0 | |

| សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ និងសកម្មភាព | | | ស្ថាប័នអនុវត្ត | ថវិកា | ប្រភព |
|---|---|---|---|---|---|
| | | បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិទទួលយកជាបណ្តើរៗនូវការងារដែលធ្លាប់បានអនុវត្តដោយទីប្រឹក្សានាពេលកន្លងមក | | | |
| លទ្ធផលរំពឹងទុកទី៥នៃ ផ.ស.ថ | 1.5.1.1 | ការពិនិត្យឡើងវិញ និងការពង្រឹងរចនាសម្ព័ន្ធ ការទទួលខុសត្រូវ និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារនានាដែលបានផ្ទេរ | | 0 | |
| សកម្មភាពនៃ ផ.ស.ថ | 1.5.1.1.1 | ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមមុខងារដែលបានផ្ទេរឱ្យ | CP | 0 | Basket |
| | 1.5.1.1.2 | ពិនិត្យ និងកែសម្រួលតួនាទី និងភារកិច្ចរបស់មន្ត្រី បុគ្គលិក ដើម្បីអនុវត្តមុខងារដែលបានផ្ទេរប្រកបដោយប្រសិទ្ធភាព | CP | 0 | Basket |
| | 1.5.1.1.3 | រៀបចំ និងអនុវត្តផែនការពង្រឹង និងផ្ទេរសមត្ថភាពពីទីប្រឹក្សាឱ្យបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | CP | 0 | Basket |
| | 1.5.1.1.4 | តាមដាន វាយតម្លៃ និងរៀបចំរបាយការណ៍ស្តីពីការអភិវឌ្ឍ និងផ្ទេរសមត្ថភាពរបស់ទីប្រឹក្សា | CP | 0 | Basket |
| យុទ្ធសាស្ត្រនៃផអ៣ទី២ | 1.5.2 | ពង្រឹងយន្តការផ្តល់យោបល់ត្រឡប់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលតំណាងដោយសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ផ្តល់ជូនលេខាធិកាដ្ឋាន គ.ជ.អ.ប និង គ.ជ.អ.ប ដើម្បីធ្វើឲ្យប្រសើរឡើងនូវការរៀបចំតាក់តែង និងការអនុវត្តកម្មវិធីកំណែទម្រង់ | | 1,072,400 | |
| លទ្ធផលរំពឹងទុកទី៦នៃ ផ.ស.ថ | 1.5.2.1 | ការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាននៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រ និងផ្តល់សេវាដល់សមាជិករបស់ខ្លួន | | 1,072,400 | |
| សកម្មភាពនៃ ផ.ស.ថ | 1.5.2.1.1 | រៀបចំកិច្ចប្រជុំរបស់របស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងគណៈកម្មាធិការប្រតិបត្តិ ដើម្បីសិក្សារៀនសូត្រ និងពិនិត្យមើលឡើងវិញអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | GS | 19,000 | Basket |
| | 1.5.2.1.2 | រៀបចំកិច្ចប្រជុំរបស់របស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និងគណៈកម្មាធិការប្រតិបត្តិ ដើម្បីសិក្សារៀនសូត្រ និងពិនិត្យមើលឡើងវិញអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ | GS | 20,000 | Basket |
| | 1.5.2.1.3 | រៀបចំសិក្ខាសាលាស្តីពីការអនុវត្តតួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងសិទ្ធិអំណាចរបស់សមាជិក ក្រុមប្រឹក្សាក្នុងការអនុវត្តអាណត្តិរបស់ខ្លួន | GS | 11,000 | Basket |
| | 1.5.2.1.4 | រៀបចំវេទិកាអំពីភាពជាតំណាងស្របច្បាប់របស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីប្រមូលមតិយោបល់ និងបញ្ហានានាពាក់ព័ន្ធនឹងការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សា និងការផ្តល់សេវាសាធារណៈ | GS | 10,000 | Basket |
| | 1.5.2.1.5 | គាំទ្រចំណាយប្រតិបត្តិការ ដើម្បីសម្របសម្រួលការអនុវត្ត ផ.ស.ថ. ឆ្នាំ២០១៦ របស់អគ្គលេខាធិការដ្ឋាន | GS | 11,400 | Basket |
| | 1.5.2.1.5 | ពង្រឹងសមត្ថភាពក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋានក្នុងការលើកកម្ពស់ការផ្តល់សេវារបស់ខ្លួន | GS | 1,000,000 | UNDP-EU/ACES |
| | 1.5.2.1.7 | សម្របសម្រួល និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអគ្គលេខាធិការដ្ឋាននៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការរៀបចំ និងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | PADD | 1,000 | Basket |
| **សមិទ្ធផលរំពឹងទុកនៃផអ៣ទី២** | **2** | **រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារជាស្ថាប័នប្រជាធិបតេយ្យនៅមូលដ្ឋាន ដែលមានស្វ័យភាព និងមានគណនេយ្យភាព ដោយគណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | **3,563,742** | |
| លទ្ធផលរំពឹងទុកនៃផអ៣ទី២ | 2.1 | តួនាទី និងខ្សែគណនេយ្យភាពច្បាស់លាស់រវាងគណៈអភិបាល និងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងអនុវត្ត | | 28,400 | |

| សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ និងសកម្មភាព | | | ស្ថាប័នអនុវត្ត | ថវិកា | ប្រភព |
|---|---|---|---|---|---|
| យុទ្ធសាស្ត្រនៃផអ៣ទី២ | 2.1.2 | ពិនិត្យ និងកែសម្រួលប្រព័ន្ធ និងនីតិវិធីនានា ដើម្បីធានាថា តួនាទីរបស់ក្រុមប្រឹក្សាត្រូវបានអនុវត្តស្របតាមច្បាប់រៀបចំស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងដើម្បីធានាដល់ការពង្រឹងសិទ្ធិអំណាចខាងបញ្ញត្តិ ការធ្វើសេចក្តីសម្រេចចិត្ត និងការត្រួតពិនិត្យមើលពីលើរបស់ក្រុមប្រឹក្សា | | 28,400 | |
| លទ្ធផលរំពឹងទុកទី១នៃ ផ.ស.ថ | 2.1.2.1 | ការពិនិត្យ និងកែសម្រួលនូវប្រព័ន្ធ និងនីតិវិធីនានានៃអភិបាលកិច្ចមូលដ្ឋាន ដើម្បីលើកកម្ពស់ខ្សែគណនេយ្យភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | 28,400 | |
| សកម្មភាពនៃ ផ.ស.ថ | 2.1.2.1.1 | វាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តវិធានផ្ទៃក្នុងក្រុង ស្រុក និងបែបផែនអភិបាលកិច្ចផ្សេងទៀត | PADD | 0 | Basket |
| | 2.1.2.1.2 | រៀបចំផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ និងបណ្តុះបណ្តាលឯកសារបច្ចេកទេសស្តីពីទំនាក់ទំនងអន្តររដ្ឋបាល និងទំនាក់ ទំនងផ្ទៃក្នុង | PADD | 14,200 | Basket |
| | 2.1.2.1.3 | រៀបចំផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ និងបណ្តុះបណ្តាលឯកសារបច្ចេកទេសស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ | PADD | 14,200 | Basket |
| លទ្ធផលរំពឹងទុកនៃផអ៣ទី២ | 2.2 | មតិយោបល់របស់ប្រជាពលរដ្ឋត្រូវបានផ្តោតការយកចិត្តទុកដាក់កាន់តែប្រសើរឡើងនៅក្នុងកិច្ចដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | 3,387,112 | |
| យុទ្ធសាស្ត្រនៃផអ៣ទី២ | 2.2.1 | ពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទៅគ្រប់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទូទាំងប្រទេស ព្រមទាំងធ្វើការវាយតម្លៃ និងពង្រឹងការអនុវត្តបន្ថែម។ ជាមួយគ្នានេះ រហូតឆ្នាំ២០១៧ ផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី២ នឹងត្រូវបានរៀបចំដោយគ្រប់ដណ្តប់លើការផ្តល់សេវាពាក់ព័ន្ធផ្សេងទៀត ព្រមទាំង ត្រូវពង្រីកការអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនានា | | 3,344,652 | |
| លទ្ធផលរំពឹងទុកទី២នៃ ផ.ស.ថ | 2.2.1.1 | ការអនុវត្តនូវសកម្មភាពគណនេយ្យភាពសង្គម និងការរៀបចំផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមរបស់ឃុំគោលដៅចំនួន៣០០ក្នុងស្រុកគោលដៅយ៉ាងតិចចំនួន៥១ដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិលនិងសហគមន៍មូលដ្ឋាននានា | | 3,344,652 | |
| សកម្មភាពនៃ ផ.ស.ថ | 2.2.1.1.1 | សិក្ខាសាលាផ្សព្វផ្សាយដល់ថ្នាក់ដឹកនាំស្រុកគោលដៅចាស់ និងខេត្តស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម | MEID | 0 | Basket |
| | 2.2.1.1.2 | សិក្ខាសាលាផ្សព្វផ្សាយដល់ថ្នាក់ដឹកនាំស្រុកគោលដៅថ្មី និងខេត្តស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមសម្រាប់ឆ្នាំ២០១៧ | MEID | 23,720 | Basket |
| | 2.2.1.1.3 | វគ្គបណ្តុះបណ្តាលថ្នាក់ជាតិដល់គ្រូឧទ្ទេសស្តីពីសេចក្តីណែនាំប្រតិបត្តិការគណនេយ្យភាពសង្គមសម្រាប់ផ្នែកផ្គត់ផ្គង់ និងប្រព័ន្ធទិន្នន័យតាមដាន និងត្រួតពិនិត្យ | MEID | 15,104 | Basket |
| | 2.2.1.1.4 | វគ្គបណ្តុះបណ្តាលថ្នាក់ជាតិដល់មន្ត្រីព័ត៌មានវិទ្យាថ្នាក់ខេត្តស្តីពីការអនុវត្តប្រព័ន្ធទិន្នន័យសម្រាប់តាមដាន និងត្រួតពិនិត្យការអនុវត្តការងារគណនេយ្យភាពសង្គម | MEID | 43,828 | Basket |
| | 2.2.1.1.5 | មណ្ឌលអភិវឌ្ឍធនធានមនុស្សរាជធានី ខេត្តរៀបចំវគ្គបណ្តុះបណ្តាលស្តីពីគណនេយ្យភាពសង្គម | CP | 41,000 | Basket |
| | 2.2.1.1.6 | គាំទ្រស្រុកគោលដៅសម្រាប់អនុវត្តសកម្មភាពគណនេយ្យភាពសង្គម | MDK | 200,000 | Basket |
| | 2.2.1.1.7 | ពង្រឹងការអនុវត្តសកម្មភាពរបស់គណកម្មាការតាមដាន និងត្រួតពិនិត្យផែនការសកម្មភាពគណនេយ្យភាពរួម | MEID | 0 | Basket |
| | 2.2.1.1.8 | តាមដាន និងគាំទ្រផែនការសកម្មភាពគណនេយ្យភាពរួម | MEID | 0 | Basket |
| | 2.2.1.1.9 | រៀបចំកិច្ចប្រជុំរបស់គណកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមៈ និងកិច្ចប្រជុំបច្ចេកទេសនានា | MEID | 3,000 | Basket |

| សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ និងសកម្មភាព | | | ស្ថាប័នអនុវត្ត | ថវិកា | ប្រភព |
|---|---|---|---|---|---|
| | 2.2.1.1.10 | សិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម | MEID | 0 | Basket |
| | 2.2.1.1.11 | រៀបចំ និងបោះពុម្ពនូវគោលការណ៍ និងសេចក្តីណែនាំនានា (កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ សេចក្តីណែនាំស្តីពីប្រតិបត្តិការគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ ផែនការអនុវត្ត៣ឆ្នាំ គណនេយ្យភាពសង្គម) | MEID | 13,000 | Basket |
| | 2.2.1.1.12 | ចុះតាមដាន និងត្រួតពិនិត្យការអនុវត្តការងារគណនេយ្យភាពសង្គមនៅមូលដ្ឋាន | MEID | 5,000 | Basket |
| | 2.2.1.1.13 | អនុវត្តសកម្មភាពគណនេយ្យភាពសង្គមផ្នែកតម្រូវការ រួមទាំងការសិក្សាវាយតម្លៃអំពីផលប៉ះពាល់ការប្រាស្រ័យទាក់ទង និងការសិក្សារៀនសូត្រ | CSOs | 3,000,000 | CSOs |
| យុទ្ធសាស្ត្រនៃផអ៣ទី២ | 2.2.3 | រៀបចំកែសម្រួល និងអនុវត្តយន្តការដោះស្រាយពាក្យបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | | 42,460 | |
| លទ្ធផលរំពឹងទុកទី៣នៃ ផ.ស.ថ | 2.2.3.1 | ការពិនិត្យ ការកែសម្រួល និងការអនុវត្តនូវយន្តការដោះស្រាយពាក្យបណ្តឹងមានលក្ខណៈជាប្រព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់នូវយន្តការនេះ | | 42,460 | |
| សកម្មភាពនៃ ផ.ស.ថ | 2.2.3.1.1 | រៀបចំ និងដាក់ឱ្យប្រើប្រាស់លិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំបង្កើតយន្តការសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងនៅថ្នាក់ក្រោមជាតិ | MOI | 9,940 | Basket |
| | 2.2.3.1.2 | ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំបង្កើតយន្តការសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងនៅថ្នាក់ក្រោមជាតិដល់ក្រុមបច្ចេកទេសនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត | MOI | 7,160 | Basket |
| | 2.2.3.1.3 | រៀបចំ និងដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីនីតិវិធីស៊ើបអង្កេត និងដោះស្រាយបណ្តឹងនៅថ្នាក់ក្រោមជាតិ | MOI | 9,940 | Basket |
| | 2.2.3.1.4 | បណ្តុះបណ្តាលដល់ក្រុមបច្ចេកទេសនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត អំពីសៀវភៅណែនាំស្តីពីនីតិវិធីស៊ើបអង្កេត និងដោះស្រាយបណ្តឹងនៅថ្នាក់ក្រោមជាតិ | MOI | 12,720 | Basket |
| | 2.2.3.1.5 | គាំទ្រ និងតាមដានយន្តការសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងនៅថ្នាក់ក្រោមជាតិ | MOI | 2,700 | Basket |
| លទ្ធផលរំពឹងទុកនៃផអ៣ទី២ | 2.3 | ប្រព័ន្ធអធិការកិច្ចប្រកបដោយតម្លាភាពលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឲ្យដំណើរការ | | 37,440 | |
| យុទ្ធសាស្ត្រនៃផអ៣ទី២ | 2.3.1 | រៀបចំ និងដាក់ឲ្យដំណើរការប្រព័ន្ធអធិការកិច្ច ដើម្បីត្រួតពិនិត្យទៅលើការអនុវត្តតាមក្របខ័ណ្ឌគតិយុត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រព័ន្ធនេះរួមមាន ការកំណត់អំពីវិសាលភាពនៃការត្រួតពិនិត្យ ការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្ត តម្រូវការអភិវឌ្ឍសមត្ថភាព និងបែបផែននៃការលើកទឹកចិត្ត និងការដាក់វិន័យ | | 37,440 | |
| លទ្ធផលរំពឹងទុកទី៤នៃ ផ.ស.ថ | 2.3.1.1 | ការរៀបចំតាក់តែង និងដាក់ឱ្យអនុវត្តសាកល្បងនូវយន្តការអធិការកិច្ចទៅលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យយន្តការនេះអាចអនុវត្តបានយ៉ាងពេញលេញនៅឆ្នាំ២០១៧ | | 37,440 | |
| សកម្មភាពនៃ ផ.ស.ថ | 2.3.1.1.1 | រៀបចំ និងដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីអធិការកិច្ចទៅលើការអនុវត្តក្របខ័ណ្ឌគតិយុត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | MOI | 21,940 | Basket |
| | 2.3.1.1.2 | បណ្តុះបណ្តាលដល់ក្រុមបច្ចេកទេសនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តអំពីសៀវភៅណែនាំស្តីពីអធិការកិច្ចទៅលើការអនុវត្តក្របខ័ណ្ឌគតិយុត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | MOI | 15,500 | Basket |
| លទ្ធផលរំពឹងទុកនៃផអ៣ទី២ | 2.4 | ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ព័ត៌មានវិទ្យា និងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង | | 110,790 | |

| **សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ និងសកម្មភាព** | | | **ស្ថាប័នអនុវត្ត** | **ថវិកា** | **ប្រភព** |
|---|---|---|---|---|---|
| យុទ្ធសាស្ត្រនៃផអ៣ទី២ | 2.4.3 | ពង្រឹងសមត្ថភាព និងប្រព័ន្ធព័ត៌មានវិទ្យានិងប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | 110,790 | |
| លទ្ធផលរំពឹងទុកទី៥នៃ ផ.ស.ថ | 2.4.3.1 | ការរៀបចំតាក់តែង និងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុងរបស់ក្រុង ស្រុក ខណ្ឌ តាមរយៈប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងរបស់ក្រុង ស្រុក សម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់ក៏ដូចជាដើម្បីប្រមូល និងផ្តល់នូវធាតុចូលនានាសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | | 110,790 | |
| សកម្មភាពនៃ ផ.ស.ថ | 2.4.3.1.1 | វាយតម្លៃលទ្ធផលការអនុវត្តសាកល្បងប្រព័ន្ធតាមដាន និងវាយតម្លៃរបស់ក្រុង ស្រុក ខណ្ឌ នៅក្រុង ស្រុក ខណ្ឌ ចំនួន១០ | MEID | 0 | Basket |
| | 2.4.3.1.2 | បណ្តុះបណ្តាលអំពីប្រព័ន្ធ M&E ក្រុងស្រុកខណ្ឌដល់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តទាំង២៥ | MEID | 28,500 | Basket |
| | 2.4.3.1.3 | គាំទ្រមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តក្នុងការបណ្តុះបណ្តាលក្រុង ស្រុក ខណ្ឌ គោលដៅអំពីប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃក្រុង ស្រុក ខណ្ឌ | MEID | 0 | Basket |
| | 2.4.3.1.4 | ចុះគាំទ្រការបណ្តុះបណ្តាលបន្តអំពីប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃក្រុង ស្រុក ខណ្ឌរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានីខេត្តដល់ក្រុង ស្រុក ខណ្ឌ (សម្រាប់ថ្នាក់ជាតិ) | MEID | 10,000 | Basket |
| | 2.4.3.1.5 | ការវាយតម្លៃលទ្ធផលអនុវត្តប្រព័ន្ធតាមដាននិងវាយតម្លៃរបស់ក្រុង ស្រុក ខណ្ឌ | MEID | 0 | Basket |
| | 2.4.3.1.6 | សរសេរកម្មវិធីប្រព័ន្ធគ្រប់គ្រងគម្រោងក្រុងស្រុកនៅលើគេហទំព័រ | MEID | 0 | Basket |
| | 2.4.3.1.7 | បណ្តុះបណ្តាលការអនុវត្តសាកល្បងអំពីប្រព័ន្ធគ្រប់គ្រងគម្រោងក្រុង ស្រុក | MEID | 9,240 | Basket |
| | 2.4.3.1.8 | ធ្វើការវាយតម្លៃលទ្ធផលសាកល្បងក្រុង ស្រុកនាឆ្នាំ២០១៥ | MEID | 0 | Basket |
| | 2.4.3.1.9 | ការចុះគាំទ្រលើការអនុវត្តប្រព័ន្ធទិន្នន័យក្រុង ស្រុក ខណ្ឌ និងការតាមដាន វាយតម្លៃនានា | MEID | 8,300 | Basket |
| | 2.4.3.1.10 | រៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្ត | MEID | 10,480 | Basket |
| | 2.4.3.1.11 | កម្មវិធីកម្មសិក្សា ឬស្ម័គ្រចិត្តសម្រាប់ប្រព័ន្ធព័ត៌មានវិទ្យា | MEID | 1,200 | Basket |
| | 2.4.3.1.12 | រៀបចំ និងដាក់ឱ្យប្រើប្រាស់លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងផ្សារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | MOI | 9,940 | Basket |
| | 2.4.3.1.13 | ផ្សព្វផ្សាយដល់ក្រុមបច្ចេកទេសនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត អំពីលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងផ្សារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | MOI | 7,160 | Basket |
| | 2.4.3.1.14 | សិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីការប្រើប្រាស់មូលនិធិ និងការអនុវត្តគម្រោងឃុំ សង្កាត់ និងក្រុង ស្រុក | MOI | 14,810 | Basket |
| | 2.4.3.1.15 | គាំទ្រ និងតាមដានត្រួតពិនិត្យការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (របៀបការងារ ការអនុវត្តតួនាទី ភារកិច្ច ការងារផែនការ ការងារថវិកា ការងារបុគ្គលិក ការរៀបចំនិងការអនុវត្តគម្រោង) | MOI | 11,160 | Basket |
| **សមិទ្ធផលរំពឹងទុកនៃផអ៣ទី២** | **3** | **រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនប្រកបដោយស្វ័យភាព និងប្រសិទ្ធភាព ដើម្បីសម្រេចបាននូវអាណត្តិ និងអាទិភាពនៃការផ្តល់សេវារបស់ខ្លួន** | | **13,061,329** | |
| លទ្ធផលរំពឹងទុកនៃផអ៣ទី២ | 3.1 | ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានធ្វើវិមជ្ឈការ និងពង្រឹង | | 664,700 | |
| យុទ្ធសាស្ត្រនៃផអ៣ទី២ | 3.1.2 | រៀបចំ និងដាក់ឲ្យអនុវត្តកិច្ចដំណើរការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការជាដំណាក់កាលៗ | | 110,000 | |

| សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ និងសកម្មភាព | | | ស្ថាប័នអនុវត្ត | ថវិកា | ប្រភព |
|---|---|---|---|---|---|
| លទ្ធផលរំពឹងទុកទី១នៃ ផ.ស.ថ | 3.1.2.1 | ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | 110,000 | |
| សកម្មភាពនៃ ផ.ស.ថ | 3.1.2.1.1 | រៀបចំបញ្ចប់ និងអនុម័តព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | MCS | 0 | Basket |
| | 3.1.2.1.2 | រៀបចំសិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | MCS | 27,300 | Basket |
| | 3.1.2.1.3 | រៀបចំសិក្ខាសាលាស្តីពីការរៀបចំលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | MCS | 18,900 | Basket |
| | 3.1.2.1.4 | សិក្ខាសាលាពិគ្រោះយោបល់នៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីប្រមូលធាតុចូលនិងបទពិសោធន៍ពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងគុណផល | MCS | 18,900 | Basket |
| | 3.1.2.1.5 | សិក្សាការធ្វើសមាហរណកម្មមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមមុខងារ និងធនធានដែលបានផ្ទេរ | MCS | 7,500 | Basket |
| | 3.1.2.1.6 | តាមដាន និងគាំទ្របច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក | MCS | 17,400 | Basket |
| | 3.1.2.1.7 | គាំទ្រប្រតិបត្តិការក្នុងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | MCS | 20,000 | Basket |
| | 3.1.2.1.8 | រៀបចំ និងអនុម័តយុទ្ធសាស្ត្រក្នុងការបង្កើនភាគរយស្ត្រីក្នុងមុខតំណែងដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | NCDDS | 0 | Basket |
| យុទ្ធសាស្ត្រនៃផអ៣ទី២ | 3.1.6 | រៀបចំវគ្គបណ្តុះបណ្តាលជារៀងរាល់ឆ្នាំអំពីការគ្រប់គ្រងធនធានមនុស្សពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ និងភាពផ្សេងៗគ្នានៃបុគ្គលិកដល់ថ្នាក់ដឹកនាំ និងអ្នកគ្រប់គ្រងទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | 554,700 | |
| លទ្ធផលរំពឹងទុកទី២នៃ ផ.ស.ថ | 3.1.6.1 | ការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | | 554,700 | |
| សកម្មភាពនៃ ផ.ស.ថ | 3.1.6.1.1 | អនុវត្តការអភិវឌ្ឍសមត្ថភាពសម្រាប់ថ្នាក់ដឹកនាំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីបរិយាប័ន្ន និងសមធម៌សង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ | MoWA | 43,900 | Basket |
| | 3.1.6.1.2 | រៀបចំសិក្ខាឆ្លុះបញ្ចាំប្រចាំឆ្នាំស្តីពីការអនុវត្តសេចក្តីសម្រេចរួម និងការរៀបចំផែនការសម្រាប់ឆ្នាំបន្ទាប់ | MoWA | 18,500 | Basket |
| | 3.1.6.1.3 | តាមដាន និងគាំទ្របច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបញ្ជ្រាបបរិយាប័ន្ន និងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | MoWA | 14,000 | Basket |
| | 3.1.6.1.4 | សិក្ខាសាលាស្តីពីការលើកកម្ពស់សមាមាត្របុគ្គលិកស្ត្រីឲ្យបំពេញការងារនៅក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបញ្ជ្រាបយេនឌ័រក្នុងកិច្ចដំណើរការគ្រប់គ្រង | PADD | 10,000 | Basket |
| | 3.1.6.1.5 | រៀបចំសិក្ខាសាលារបស់បណ្តាញក្រុមប្រឹក្សាស្ត្រីក្នុង២៤ខេត្ត | PADD | 35,000 | Basket |
| | 3.1.6.1.6 | រៀបចំចងក្រង ពិគ្រោះយោបល់ ផ្សព្វផ្សាយ និងតាមដានការអនុវត្តឯកសារបច្ចេកទេសស្តីពីការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម | PADD | 28,000 | Basket |
| | 3.1.6.1.7 | ពង្រឹងកិច្ចដំណើការរបស់ក្រុមការងារយេនឌ័រនៃលេខាធិការដ្ឋាន គ.ជ.អ.ប | PADD | 500 | Basket |
| | 3.1.6.1.8 | ពង្រឹងការអនុវត្តមុខងាររបស់ គ.ក.ស.ក. រាជធានី ខេត្តក្នុងការបញ្ជ្រាបបរិយាប័ន្ន និងសមធម៌សង្គមក្នុងផែនការ គម្រោង និងកម្មវិធីនានាក៏ដូចជាការសម្របសម្រួល និងស្វែងរកការគាំទ្ររបស់រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធនានាក្នុងការលើកកម្ពស់សេវាសង្គម | CP | 37,500 | Basket |
| | 3.1.6.1.9 | ពង្រឹងការអនុវត្តមុខងាររបស់ គ.ក.ស.ក. ក្រុង ស្រុក ខណ្ឌក្នុងការបញ្ជ្រាបបរិយាប័ន្ន និងសមធម៌សង្គមក្នុងផែនការ គម្រោង និងកម្មវិធីនានាក៏ដូចជាការសម្របសម្រួល និងស្វែងរកការគាំទ្ររបស់ក្រុង ស្រុក ខណ្ឌ និងស្ថាប័នពាក់ព័ន្ធនានាក្នុងការលើកកម្ពស់សេវាសង្គម | MDK | 177,300 | Basket |

| សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ និងសកម្មភាព | | | ស្ថាប័នអនុវត្ត | ថវិកា | ប្រភព |
|---|---|---|---|---|---|
| | 3.1.6.1.10 | រៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានាជាមួយមន្ទីរ ការិយាល័យ និងអង្គភាពជំនាញ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់សមភាពយេនឌ័រ ការពង្រឹងភាពអង់អាចដល់ស្ត្រី និងបរិយាប័ន្ន និងសមធម៌សង្គម | PDoWA | 30,000 | Basket |
| | 3.1.6.1.11 | អភិវឌ្ឍសមត្ថភាពអ្នកពាក់ព័ន្ធនានាអំពីការលើកកម្ពស់សមភាពយេនឌ័រ ការពង្រឹងភាពអង់អាចដល់ស្ត្រី បរិយាប័ន្ន និងសមធម៌សង្គមនៅថ្នាក់ក្រោមជាតិ | PDoWA | 62,500 | Basket |
| | 3.1.6.1.12 | រៀបចំ និងផ្សព្វផ្សាយឯកសារ និងស្ថិតិនានាស្តីពីសមភាពយេនឌ័រ ការពង្រឹងភាពអង់អាចដល់ស្ត្រី និងសមធម៌និងបរិយាប័ន្នសង្គមនៅថ្នាក់ក្រោមជាតិ | PDoWA | 12,500 | Basket |
| | 3.1.6.1.13 | តាមដាន និងផ្តល់គាំទ្របច្ចេកទេសសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនានាសម្រាប់ក្រុមប្រឹក្សាពាក់ព័ន្ធនឹងការបញ្ជ្រាប យេនឌ័រ ការពង្រឹងភាពអង់អាចរបស់ស្ត្រី និងការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម | PDoWA | 45,000 | Basket |
| | 3.1.6.1.14 | អនុវត្តសកម្មភាពនានាផ្អែកលើអនុសាសន៍របស់សវនកម្មយេនឌ័រ | PDoWA | 40,000 | Basket |
| លទ្ធផលរំពឹងទុកនៃផអ៣ទី២ | 3.2 | ប្រព័ន្ធគាំទ្រការអភិវឌ្ឍស្ថាប័នផ្អែកតាមតម្រូវការ និងប្រព័ន្ធគាំទ្រការប្រឹក្សាយោបល់សម្រាប់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យដំណើរការនៅថ្នាក់រាជធានី ខេត្ត | | 5,629,015 | |
